00777334



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance


ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 09-Feb-2012, 08:34
CMS/CFO: Kauv Keoratanak


# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១២**

**ម៉ោង ០៩:០២ នាទី**

**សវនាការលើកទី២៧**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍

*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន

*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តារ

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)

*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ម៉ាតេអូ គ្រីប៉ា

*(Mr.Matteo CRIPPA)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក ច័ន្ទ តារាស្មី

លោក សេង ប៊ុនឃាង

លោក ថារីក អាប់ឌុលឡាក់

*(Mr. Tarik ABDULHAK)*

កញ្ញា សារ៉ា អេនឌ្រូ

*(Miss.Sarah ANDREWS)*

លោក វេង ហ៊ត់

លោក ពេជ្រ សម្បត្តិ

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ម៉ៃខល ផេសមិន

*(Mr. Michiel PESTMAN)*

លោក ហ្សាស្ពើ ប៉ៅ*(Mr Jasper PAUW)*

លោក អេន្ទ្រូ អ៊ីនូហ្ស៊ី *(MrAndrew IANUZZI)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវាស

*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោក វ៉ែន ពៅ

លោក ហុង គីមសួន

លោក ឡោ ជុនធី

លោក សំ សុគង់

លោកស្រី ជេត វណ្ណលី

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| លោក ថារីក អាប់ឌុលឡាក់ | អង់គ្លេស |
| លោក សុន អរុណ | ខ្មែរ |
| លោក ហ្សាស្តេី ប៉ៅ | អង់គ្លេស |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |
| លោក ឆាំង យុ | ខ្មែរ |

# ឧបសម្ព័ន្ធ

## ការសួរសំណួរទៅលោក នាំង យុ

សួរដោយលោក ហ្សាស្តេី ប៉ៅ ផ្តើមពី៖ ............ ទំព័រ ០៤

សួរដោយលោក សុន អរុណ ផ្តើមពី៖ ............ ទំព័រ ៧៤

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០២:២៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការពិភាក្សាដេញដោល។ តាមកាលវិភាគដែលបានកំណត់ទុក គឺដល់ថ្ងៃនេះ អង្គជំនុំជម្រះនឹងបន្តស្តាប់សក្ខីកម្មរបស់សាក្សីឈ្មោះ ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលអង្គជំនុំជម្រះត្រូវបន្តកិច្ចពិភាក្សាដេញដោលអំពីបញ្ហាពាក់ព័ន្ធនឹងវិធីនៃការប្រគល់ ទទួល ឯកសារ ការរៀបចំឯកសារកាតាឡុក ការគ្រប់គ្រងឯកសារ និង/ឬប្រភេទឯកសារជាក់លាក់មួយចំនួនផ្សេងទៀត។ នេះជាគោលបំណងនៃកិច្ចដំណើរការសវនាការ។ ហើយសវនាការនៅក្នុងថ្ងៃនេះគឺដល់ពេលវេលាត្រូវបានវេទិកាទៅក្រុមមេធាវីការពារក្តី នួន ជា ដែលមានពេលវេលាមួយព្រឹកនេះទៀត ហើយរសៀលនេះយើងនឹងបន្តស្តាប់នូវការដេញដោលពីសំណាក់ក្រុមមេធាវីការពារក្តីរបស់លោក អៀង សារី ដែលជាភាគីសួរដេញដោលបញ្ចប់ចំពោះសាក្សីលោក ឆាំង យុ ដែលជាប្រធានមជ្ឈមណ្ឌលឯកសារកម្ពុជា។

មន្ត្រីតុលាការសូមអញ្ជើញសាក្សីចូលមកកាន់បន្ទប់សវនាការ។

*(សាក្សីចូលមកកាន់បន្ទប់សវនាការ)*

[០៩:០៥:២៤]

**ប្រធានអង្គជំនុំ៖**

សួស្តីលោក ឆាំង យុ! ថ្ងៃនេះអង្គជំនុំជម្រះបន្តស្តាប់សក្ខីកម្មរបស់លោកពាក់ព័ន្ធនឹងបញ្ហានានាជុំវិញការទទួលប្រគល់ការគ្រប់គ្រងឯកសារ កាតាឡុកឯកសារ និងការរក្សាទុកឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលកាលពីថ្ងៃព្រហស្បតិ៍កន្លងទៅបានដល់វេនក្រុមមេធាវីការពារក្តី នួន ជា ដែលគាត់មានពេលវេលាមួយថ្ងៃ គាត់បានប្រើពេលវេលាអស់មួយកន្លះថ្ងៃហើយ ហើយនៅសល់កន្លះថ្ងៃទៀត។ ហើយថ្ងៃនេះ ព្រឹកនេះ អង្គជំនុំជម្រះសូមផ្តល់វេទិកាទៅក្រុមមេធាវីការពារក្តី នួន ជា ដើម្បីបន្តការសួរដេញដោលចំពោះលោក ឆាំង យុ ដែលជាប្រធានមជ្ឈមណ្ឌលឯកសារកម្ពុជា ចំពោះបញ្ហានានាដែលអង្គជំនុំជម្រះបានកំណត់ទុកសម្រាប់ធ្វើសវនាការចំពោះសាក្សីរូបនេះ។

បាទ សូមអញ្ជើញ!

[០៩:០៦:៤១]

**លោក ហ្សាស្តេី ប៉ោ៖**

សូមអរគុណលោកប្រធាន សូមជម្រាបសួរលោក លោកស្រីចៅក្រម និងសវនាការទាំងមូល។

**អ្នកបកប្រែ៖**

លោកប្រធាន មីក្រូហ្វូនគាត់អត់បើក។ ដូច្នេះ អ្នកបកប្រែស្តាប់អត់ឮទេបាទ។

**លោក ហ្សាស្តេី ប៉ោ៖**

បាទ ជាពិសេសសូមឲ្យបំភ្លឺនូវពេលវេលា ខ្ញុំបាន-- ខាងមេធាវី អៀង សារី គាត់ថាមិនសួរសំណួរទៅសាក្សីនេះទេ។ ដូច្នេះ ក្រុមមេធាវីទាំងបីហ្នឹង គឺមានពេលពីរថ្ងៃ ហើយខ្ញុំសូមអនុញ្ញាត--

**អ្នកបកប្រែ៖**

បាទ មានផ្នែកមួយមិនបានបកប្រែដោយសារមីក្រូហ្វូនគាត់មិនបានបើក។ ដូច្នេះ សូមឲ្យគាត់និយាយត្រង់ហ្នឹងម្តងវិញ។ បាទ លោកប្រធាន នេះពីអ្នកបកប្រែបាទ។

[០៩:០៧:២៧]

**ប្រធានអង្គជំនុំ៖**

សូមលោកមេធាវី និយាយសាឡើងវិញ សាជាថ្មីម្តងទៀត ពីព្រោះលោកនិយាយពីដំបូង លោកអត់បានបើកក្បាលមេក្រូទេ ក្នុងការនិយាយ។ អ៊ីចឹងអ្នកបកប្រែស្តាប់ភាសាលោកនិយាយមិនបានទេ មិនអាចបកប្រែជាភាសាផ្សេងៗសម្រាប់អង្គសវនាការស្តាប់បានទេ។ សូមលោកនិយាយសាជាថ្មីឡើងវិញ។

**លោក ហ្សាស្តេី ប៉ោ៖**

សូមអរគុណលោកប្រធាន។ ចំណុចសំខាន់ដែលខ្ញុំចង់ជម្រាបតុលាការនោះ គឺមេធាវីការពារលោក អៀង សារី គាត់បញ្ជាក់ថា គាត់មិនតាំងសំណួរទៅសាក្សីរូបនេះទេ។ ហើយជាពិសេសនៅក្នុងការសួរដេញដោលនេះ។ សំណួររបស់ខ្ញុំនេះ ដោយហេតុថាក្រុមទាំងបីនោះ គឺមានមេធាវីពីរថ្ងៃ ដូច្នេះ តើតុលាការនឹងអនុញ្ញាតឲ្យក្រុមរបស់ខ្ញុំនូវពេលដែលបានចែកទៅឲ្យមេធាវីលោក អៀង សារី ទាំងស្រុងបានដែរឬទេ? ដោយពិចារណាលើសំណួរជាច្រើនដែលយើងខ្ញុំមាននោះ។ ហើយមួយព្រឹកសម្រាប់យើងខ្ញុំនោះ គឺដូចខ្លីពេកដើម្បីសួរទៅសាក្សីរូបនេះ។ បាទ សូមអរគុណ។

[០៩:០៨:៤២]

**ប្រធានអង្គជំនុំ៖**

ក្រុមមេធាវីការពារក្តី អៀង សារី តើប្រាកដទេនូវការលើកឡើងរបស់ក្រុមមេធាវីការពារក្តី នួន ជា អម្បាញ់មិញនេះ?

**លោក ម៉ៃខល កាណាវាស៖**

សូមជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម ហើយនិងអង្គសវនាការទាំងមូល។ ទាក់ទងទៅនឹងសំណួរដែលបានតាំងទៅសាក្សីរូបនេះ ដូចជាមានស្តាប់ពីសក្ខីកម្មរបស់លោក យុ ឆាំង នោះគឺដូច្នេះ គឺថាគាត់មកបង្ហាញនូវភស្តុតាង ហើយជាការសម្រេចរបស់យើងទាក់ទងទៅនឹងការទទួលយកនូវភស្តុតាងនេះ គឺយើងចង្អុលបង្ហាញថា មានៗសេចក្តីសន្និដ្ឋានថា ឯកសារទាំងអស់ពិនិត្យមើលទៅ ហើយអាចនឹងយកចិត្តទុកដាក់បាន ឬក៏អាចជឿជាក់បានដោយសហចៅក្រមស៊ើបអង្កេតនោះ គឺថាវាទំនងជាករណីមួយ ប៉ុន្តែភាគីនៅតែមានសិទ្ធិក្នុងការដេញដោលឯកសារមួយៗនោះ ទាក់ទងទៅនឹងយថាភាព ឬក៏ភាពពាក់ព័ន្ធ និងភាពអាចជឿជាក់បាន។

[០៩:០៩:៥២]

ដូច្នេះ ចំពោះខ្ញុំ ខ្ញុំមិនចង់តាំងសំណួរអ្វីតទៀតទៅលើលោក ឆាំង យុ នោះទេ។ គឺថាយើងមិនអាចនឹងបានតម្លៃអ្វីបន្ថែមទេក្នុងការតាំងសំណួរទេ ដោយសារថាគាត់បានឆ្លើយមួយចំនួនច្រើនហើយ។ ក្នុងនាមមេធាវី អាង ឧត្តម ហើយនិងមេធាវី អៀង សារី ទាំងមូល ហើយខ្ញុំសូមអរគុណនូវអង្គជំនុំជម្រះផងដែរ ដែលអនុញ្ញាតឲ្យយើងខ្ញុំនៅមានពេលគ្រប់គ្រាន់ក្នុងការតាំងសំណួរនូវដល់លោក យុ ឆាំង នោះ។ បាទសូមអរគុណ។ មេញ្លូល

[០៩:១១:២៧]

**ប្រធានអង្គជំនុំ៖**

លោកមេធាវីការពារក្តី នួន ជា! អង្គជំនុំជម្រះបានស្តាប់នូវសំណើសុំរបស់លោកហើយ ៗអង្គជំនុំជម្រះកត់សម្គាល់នូវសំណើសុំរបស់លោកដែលបានធ្វើរួចហើយនេះ ហើយអង្គជំនុំជម្រះមិនទាន់សម្រេចបញ្ហានេះនាពេលនេះទេ។

ឥឡូវនេះសូមប្រគល់វេទិកាជូនទៅលោកមេធាវី ដើម្បីតាំងសំណួរជាក់លាក់ចំពោះបញ្ហាដែលបានកំណត់នៅក្នុងការដេញដោលចំពោះសាក្សីរូបនេះ។

**លោក ហ្សាស្តើ ប៉ៅ៖**

សូមអរគុណលោកប្រធាន ដូច្នេះខ្ញុំនឹងអនុញ្ញាតសូមបន្ត។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក ហ្សាស្តើ ប៉ៅ៖**

**ស៖** សូមជម្រាបសួរលោក ឆាំង យុ! សំណួរទីមួយរបស់ខ្ញុំគឺទាក់ទងទៅនឹង*មេញ្ញូល* មួយ ដែលយើងបានឃើញនៅក្នុងវែបសាយរបស់ ឌី.ស៊ី.ខេម ដែលនិយាយអំពីមេញ្ញូល ដើម្បីដាក់នៅក្នុងព័ត៌មានទាក់ទងទៅនឹងឯកសារទាំងឡាយនៅមជ្ឈមណ្ឌលឯកសារកម្ពុជា។ ហើយយើងគិតថា យើងឃើញមេញ្ញូល នេះនៅក្នុងវែបសាយ ហើយយើងសូមឲ្យលោកបញ្ជាក់ថា តើនេះជា មេញ្ញូល ដែលលោកបានប្រើនៅពេលដែលបញ្ចូលនូវព័ត៌មានទាក់ទងទៅនឹងឯកសារ ព័ត៌មានទាក់ទងទៅនឹងឯកសារដែលលោកបានរកឃើញ។ ដូច្នេះសូមអនុញ្ញាតទៅលោកប្រធាន ដើម្បីសូមដាក់បង្ហាញ មេញ្ញូល នេះនៅក្នុងអេក្រង់ ដើម្បីឲ្យសាក្សីលោកបញ្ជាក់ថា តើនេះពិតជា មេញ្ញូល ដែលមជ្ឈមណ្ឌលឯកសារបានប្រើដែរឬទេបាទ?

[០៩:១៣:១៥]

ហើយយើងក៏បង្វិលទៅទំព័រទី១០ ដើម្បីឲ្យឃើញចំណងជើងមួយនៅទីនោះ។ បាទ នេះហើយ។ ដូច្នេះនេះចំណងជើងមួយដែលនិយាយថា "ទិន្នន័យដេតាបេស និយាយអំពីប្រល័យពូជសាសន៍នៅកម្ពុជា ដែលហៅ ស៊ី.ប៊ី.អាយ.ប៊ី" តើពិតជាមេញ្ញូលមួយរបស់ ឌី.ស៊ី.ខេម ដែរឬទេ? បាទ លោកសាក្សីសូមឆ្លើយ។ បាទ ខ្ញុំស្តាប់ចម្លើយលោកមិនទាន់ សូមលោក ឆាំង យុ អញ្ជើញឆ្លើយម្តងទៀតបាទ។

[០៩:១៣:៥៨]

**លោក ឆាំង យុ៖**

**ឆ៖** សូមទោសអំមិញ ខ្ញុំអត់ទាន់បានឆ្លើយផងបាទ។ នេះគឺជាមេញ្ញូលដែលយើងប្រើប្រាស់ ហើយយើងហៅវា *ស៊ីប៊ីប* "ស៊ី.ប៊ី.អាយ.ប៊ី" យើងហៅថា *ស៊ីប៊ីប* បាទ។

**ស៖** អរគុណណាស់ យើងនឹងដាក់នៅលើអេក្រង់ម្តងទៀត ខ្ញុំនឹងសួរសំណួរម្តងទៅទៀត ទាក់ទងនឹងឯកសារមួយនេះ។ ខ្ញុំមិនដឹងថា លោកសាក្សីអាចអានច្បាស់ដែរឬទេ នៅលើអេក្រង់នេះ? ហើយយើងចូលទៅដល់ទំព័រលេខ១៣ ហើយយើងឃើញនៅក្នុងប្រអប់ពណ៌ក្រហម។ ព័ត៌មានមួយចំនួនទាក់ទងទៅនឹងកំណត់សម្គាល់៣១៧ ដែលបញ្ជាក់ថាប្រភពនៃឯកសារផ្អែកទៅសេចក្តីអធិប្បាយនេះ គឺប្រើដើម្បីកត់ត្រាព័ត៌មានស្តីពី ប្រភពនៃព័ត៌មាន អំពី-- បាទគឺអ្នកម្ចាស់ដើមបច្ចុប្បន្ន ឬក៏ពីមុន។

តើត្រូវដែរឬទេ? បើខ្ញុំពិនិត្យមើលប្រអប់នេះ ដែលលោកបានដាក់ព័ត៌មានទាក់ទងទៅនឹងពី បញ្ជាក់ពី *ប្រូវើណិន* គឺតម្លៃនៃឯកសារដែលបញ្ជាក់ពីប្រវត្តិនៃការប្ដូរពីម្ចាស់ដើមមកអ្នកទីមួយទីពីរជាដើមនោះបាទ។

**ឆ៖** ដូចលោកស្រាប់ហើយថា នៅក្នុងលេខ ឧទាហរណ៍ យើងប្រើពាក្យឧទាហរណ៍ *អ៊ិច ហ្សាមផ្លល* គឺហ្នឹងនៅក្នុង B17 មានន័យថា KHTSL2 បានន័យថា គឺជាឯកសារមកពីទួលស្លែង នៅក្នុងប្រអប់លេខពីរ។

[០៩:១៥:៤៨]

**ស៖** សូមអភ័យទោស សំណួររបស់ខ្ញុំហ្នឹងប្រហែលជាលោកស្ដាប់មិនទាន់។ សំណួរខ្ញុំ គឺដូចត ទៅនេះ តើត្រូវដែលទេ បើសន្និដ្ឋានថានៅពេលខ្ញុំមើលសេចក្ដីពណ៌នា៣១៧ នេះ តើគឺជាប្រអប់ដែលលោកបានបញ្ចូននូវព័ត៌មានទាក់ទងទៅនឹងឯកសារដែលលោកបានទទួលនូវ ឌី.ស៊ី.ខេម ហើយខ្ញុំនិយាយអំពីព័ត៌មានដែលទាក់ទងទៅនឹងពីលទ្ធភាពដែលរកឃើញនេះ នៃឯកសារហ្នឹង ហើយអ្នកកាន់កាប់ពីមុននៃឯកសារហ្នឹងបាទ។

**ឆ៖** ឯកសារនេះ គឺនៅក្នុងប្រអប់មួយដែលមានថា "លេខពីរ" គឺជាឯកសារមកពីទួលស្លែង ហើយនៅក្នុង៣១៧ ហ្នឹងគឺនិយាយអំពីឯកសារដែលមានឈ្មោះថា រស់ សុខា ខែធ្នូ ឆ្នាំ១៩៨០។ ហ្នឹងជាឧទាហរណ៍បាទ យើងដាក់ខាងលើហើយជាឧទាហរណ៍ ដើម្បីអ្នកធ្វើ ចុះបញ្ជីហ្នឹងយល់ ១ថាកន្លែងនេះចង់និយាយអំពីស្អី។

[០៩:១៦:៥៧]

**ស៖** លោក ឆាំ យុ ខ្ញុំយល់ថា ឧទាហរណ៍នេះ គឺប្រអប់លេខពីរគឺព័ត៌មាន សុខា នេះប្រើជាឧទាហរណ៍សម្រាប់ឲ្យអ្នកដាក់បញ្ចូលព័ត៌មាន។ ខ្ញុំសូមសួរលោកម្ដងទៀត។ តើត្រូវដែលឬទេថា នៅពេល ឌី.ស៊ី.ខេម ទទួលឯកសារ ហើយលោកបានបញ្ចូលនូវព័ត៌មានទាក់ទងទៅនឹងឯកសារនេះ? អ្នកដែលដាក់បញ្ចូលឯកសារ គឺដាក់ខ្លឹមសារមួយចំនួនគឺត្រូវបញ្ចូលនូវព័ត៌មាននៅក្នុងប្រអប់នេះ លេខ៣១៧ ទាក់ទងទៅ*ប្រូវើណិន* របស់ឯកសារ គឺមានន័យថា "ដំណើរ" គឺបញ្ជាក់ថាអ្នកណាជាអ្នកកាន់កាប់ពីមុនមកនោះបាទ។

**ឆ៖** ត្រឹមត្រូវបាទ។

[០៩:១៧:៥២]

**ស៖** ដូច្នេះចំពោះឯកសារទាំងអស់នៅក្នុងមជ្ឈមណ្ឌលឯកសារកម្ពុជានៅក្នុងទិន្នន័យ *ដេតាបេស* តើប្រអប់៣១៧នោះ គឺត្រូវបានបំពេញនូវព័ត៌មានទាក់ទងទាំងអស់ដែលលោកបាន *ប្រូសេស* បានន័យលោកពិនិត្យនោះដែរឬទ?

**ឆ៖** នៅក្នុងឯកសារនីមួយៗ បាទមានលក្ខណៈខុសគ្នាពេលយើងយកមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជា។ ឯកសារណាដែលមានព័ត៌មានទាំងអស់នេះ គឺបុគ្គលិកទាំងអស់តម្រូវបញ្ចូលទៅគ្រប់យើងហៅថា *ហ្វៀល* នៅគ្រប់ចំណុចទាំងអស់ដែលមាននៅក្នុងទិន្នន័យនេះ។ អ៊ីចឹងបើសិនជាឯកសារនេះ មានដាក់ថាប្រអប់លេខពីរ យើងច្បាស់ជាបញ្ចូលក្នុងប្រអប់លេខពីរ។ សូមបញ្ជាក់ថា ប្រអប់លេខពីរនេះ គឺជាសំណុំឯកសារដែលយើងមិនបានពង្រាយចេញ វានៅក្នុងស្ថិតក្នុងប្រអប់មួយ ហើយក្រោយមកឯកសារទាំងអស់នេះត្រូវបានពង្រាយចេញ មកចុះលេខទៅតាមទ្រង់ “D” *ស៊ីរីប* គឺសម្រាប់ “D” ហើយនៅក្នុងប្រអប់ពីរនេះ គឺជាដំបូងឡើងដែលយើងឃើញនៅក្នុងប្រអប់។

[០៩:១៨:៥៥]

អ៊ីចឹងនៅក្នុងនេះ បើសិនលោកមើលតទៅទៀត អាចថាអត់មានដាក់ *បកស័ណាំប៊ឺធូ* ទៀតទេ អាចថាជា TSL001 ឬក៏ D150 ជាដើម។ នេះគឺជាដំបូងឡើងដែលយើងបានប្រមូល ហើយតាមដែលខ្ញុំចាំ *ម៉ានញូល* នេះធ្វើតាំងពីឆ្នាំ៩៥ នៅពេលដែលនោះយើងមានសំណុំឯកសារជាច្រើន ដែលមកដល់កន្លែងយើង ហើយយើងក៏ចាប់ផ្ដើមធ្វើ *ម៉ានញូល*នេះ។ អ៊ីចឹងយើងមានបានលើកជាឧទាហរណ៍ ដើម្បីពន្យល់ទៅបុគ្គលិក ដែលយើងបានបង្វឹកហាត់ឲ្យស្គាល់ឯកសារ មុននឹងធ្វើកាតាឡុក។ ក្រោយមកទៀត បាទក្រោយមកទៀតនៅក្នុងប្រអប់នេះត្រូវបានដកចេញ ត្រូវបានហ្វូតូកូពី ត្រូវបានធ្វើ *ម៉ៃក្រូហ្វីម* ត្រូវបានស្កេន ត្រូវបានចុះលេខ ត្រូវបានបញ្ចូលទៅក្នុងទូ ត្រូវបានហ្វឹកហាត់បុគ្គលិកឲ្យចេះចុះលេខបញ្ជីទៅក្នុងកន្លែងនេះ។ អ៊ីចឹង អានេះគឺជាពីដំបូងឡើង។ មូលហេតុហ្នឹងហើយបានជាយើងដាក់ជាឧទាហរណ៍។

[០៩:២០:០២]

**ស៖** សូមអរគុណលោក ឆាំង យុ ហើយខ្ញុំមិនធ្វើពុតថា ខ្ញុំ អ្វីយល់ចម្លើយរបស់លោកទាំងអស់នោះទេ ពីព្រោះថាវាបច្ចេកទេសពេក។ ដូច្នេះ វាស្មុគស្មាញណាស់។ ខ្ញុំនឹងព្យាយាមសួរនូវសំណួរសាមញ្ញជាងហ្នឹងតទៅទៀត។ ចំពោះឯកសារគ្រប់ទាំងអស់ដែលចូលមកដល់ ឌី.ស៊ី.ខេម តើលោកកត់ត្រាចូលនូវព័ត៌មានទាក់ទងទៅនឹងប្រភពនៃឯកសារទាំងនោះ ហើយនិងថាតើម្ចាស់ដើមនោះជា

នរណា ត្រូវកត់ត្រាដែរទេ តើមែន ឬមិនមែន?

[០៩:២០:៤៩]

**ឆ៖** ដូចខ្ញុំជម្រាបកាលពីសប្តាហ៍មុនហើយ គ្រប់ឯកសារចូលមកទាំងអស់យើងមានទម្រង់ណែនាំ សាកសួរអំពីប្រភពឯកសារដែលមានបួនចំណុច។ បាទ លោកមេធាវី សំអុន ខាងមេធាវីលោកអ៊ីហែម បានសួរខ្ញុំពីបញ្ហាហ្នឹងដែរ។ អ៊ីចឹងវាអាស្រ័យទៅលើឯកសារដែរ។ ខ្ញុំបានលើកជាឧទាហរណ៍អំពីរូបថត ដែល លោក ខៀវ កូឡា មកឲ្យខ្ញុំ។ អ៊ីចឹង ពេលដែលឯកសារចូលមកខ្ញុំសួរ ខ្ញុំសួរថាឯកសារនេះមកពីកន្លែងណា? អ្នកណាយកមកឲ្យ ហើយយើងកំណត់ចំណាំទុក ប៉ុន្តែមិនមែនជាលក្ខណៈមួយផ្លូវការទេ ដោយសារថាឯកសារខ្លះវាមកទម្រង់ខុសៗគ្នា ប៉ុន្តែយើងបានធ្វើជាកំណត់ហេតុតូចៗ ដើម្បីសម្គាល់ដូចជាឧទាហរណ៍ នៅពេលដែលលោក ខៀវ កូឡា បានយករូបថតមកខ្ញុំៗទុកលេខទូរស័ព្ទគាត់ ខ្ញុំទុកអ៊ីម៉ែល ឬក៏ទុកឯកសារផ្សេងៗ ដើម្បីឲ្យបុគ្គលិកយកមកបញ្ចូលនៅក្នុងកន្លែងនេះ។ អ៊ីចឹងយើងបានធ្វើ។ យើងបានធ្វើទៅតាមប្រភេទឯកសារដែលយើងបានទទួល។ ឧទាហរណ៍ ឯកសារមកពីក្រសួងមហាផ្ទៃ មានចំនួនច្រើនមែនទែន មានទៅដល់ជាងរាប់ម៉ឺនរាប់សែន។ អ៊ីចឹង យើងមិនបានធ្វើវាជាគ្រប់ឯកសារទេ យើងធ្វើជារួមតែម្តង ពីព្រោះយកមកពីកន្លែងតែមួយ ហើយព័ត៌មាននេះ ខ្ញុំបានជម្រាបពីសប្តាហ៍មុនហើយ ខ្ញុំបានប្រគល់ជូនសហចៅក្រមស៊ើបអង្កេតរួចហើយ ថាអ្នកណាខ្លះជាអ្នកឃើញឯកសារនេះដំបូង។ ហើយយើងបានព្យាយាម ៗអស់ពីលទ្ធភាពទៅរកមនុស្សទីមួយដែលបានឃើញ ដែលបានប៉ះឯកសារនេះ ទៅតាមលទ្ធភាពដែលយើងអាចធ្វើបាន។

[០៩:២២:២១]

**ស៖** សូមអរគុណ។ តាមពិតនោះគឺថា ច្បាស់ហើយតាមសក្ខីកម្មរបស់ពីសប្តាហ៍មុន។ ចំពោះថ្ងៃនេះ ខ្ញុំចង់ដឹងថាព័ត៌មានដែលលោកបានទទួលអំពីប្រភពនៃឯកសារនោះ ហើយម្ចាស់ដើម ម្ចាស់ដំបូងនោះ គឺថានៅពេលដែលលោកបញ្ចូលព័ត៌មានទាំងអស់នៅទៅក្នុងទិន្នន័យ *ដេតាបេស* តើកំណត់សម្គាល់ ៣១៧ គឺជាកន្លែងមួយនៅក្នុងដេតាបេស ដែលទុកនូវព័ត៌មានទាំងអស់ហ្នឹង។ តើមែនឬទេ?

**ឆ៖** ខ្ញុំគិតថា ប្រហែលជានៅកន្លែងហ្នឹងដែរ ដោយសារថា ខ្ញុំមិនមែនជាអ្នកធ្វើកិច្ចការនេះប្រចាំថ្ងៃ។ ជាទូទៅយើងដាក់វាជារួម ដូចជាថា ក្រសួងមហាផ្ទៃ បាទ ហើយកន្លែង *ស្វហ្វ* កន្លែង *ប្រមើលមើល* នេះ គឺជាកន្លែងដែលយើងដាក់ព័ត៌មាននេះ។

**ស៖** ដូច្នេះតើលោកបញ្ជាក់ថា លោកមិនជាអ្នកអានរាល់ថ្ងៃទេ។ តើបុគ្គលណាមួយដែលយើង

គួរសួរ ដែលជាអ្នកដឹងច្បាស់អំពីកំណត់សម្គាល់ ៣១៧ នៅក្នុងដេតាបេស នេះបាទ?

**ឆ៖** លោកយល់ច្រឡំហើយ។ ខ្ញុំអានឯកសាររាល់ថ្ងៃគ្រប់ឯកសារទាំងអស់ ដែលចូលមកមជ្ឈមណ្ឌលឯកសារកម្ពុជា។ នេះគឺជាដំណើរការបញ្ចូលទិន្នន័យលក្ខណៈបច្ចេកទេស ដែលក្រុមឯកសារនេះមានលោក វ៉ាន់ថាន់ ពៅដារ៉ា ជាប្រធាន។ ចំពោះឯកសារទាំងអស់ ខ្ញុំអានទាំងអស់តែម្តង ខ្ញុំអានទាំងអស់ ហើយបើសិនជាលោកនិយាយទៅលើឯកសារមួយៗ ឧទាហរណ៍ឯកសារក្រសួងមហាផ្ទៃដែលយើងលើកឡើងជាច្រើនលើកសា ខ្ញុំមានក្រដាសស្នាមដែលខ្ញុំបានទទួល ស៊ីញ៉េ ទទួលប្រគល់ខ្ញុំមាន។ បាទ ប្រសិនជាលោកត្រូវការ ដើម្បីបញ្ជាក់ថាអ្នកនេះ អ្នកណាឲ្យខ្ញុំ ពេលណា ថ្ងៃណា ខែណា ឆ្នាំណា ក៏យើងមានដែរ ប៉ុន្តែនេះគឺជាបញ្ហាបច្ចេកទេសរបស់ក្រុមឯកសារ។ អ៊ីចឹង ខ្ញុំមិនទៅបញ្ចូលទិន្នន័យរាល់ ថ្ងៃទេ តែខ្ញុំអានឯកសារ។ អានហើយថតចម្លង ម៉ៃក្រូហ្វីម ចុះលេខ បានប្រគល់ទៅឲ្យលោក វ៉ាន់ថាន់ ពៅដារ៉ា និងក្រុមរបស់គាត់ ដើម្បីបញ្ចូលទៅក្នុងទិន្នន័យទាំងអស់នេះ។ បាទនេះជាលក្ខណៈបច្ចេកទេស បាទ ហើយព័ត៌មានណាដែលទាក់ទងទៅហ្នឹងប្រភព គឺច្បាស់ជាដាក់នៅកន្លែងហ្នឹងតែម្តងបាទ។

[០៩:២៤:៥៤]

**ស៖** សូមអរគុណ លោក ឆាំង យុ។ ហើយខ្ញុំមិនសួរសំណួរដែលបច្ចេកទេសពេកទេ ដោយហេតុថា យើងពិនិត្យមើលឃើញថា លោកអនុប្រធានរបស់លោកហ្នឹងបានជាអ្នកទទួលបន្ទុក ការបញ្ចូលទិន្នន័យនេះ ក៏ប៉ុន្តែខ្ញុំគិតថា លោកអាចឆ្លើយបាននូវសំណួរដូចខាងក្រោមនេះ។ ការិយាល័យសហព្រះរាជអាជ្ញា បានផ្តល់ឲ្យភាគីនូវបញ្ជីឯកសារទាំងអស់ដែលខ្លួនបានពឹងផ្អែក ដែល ឌី.ស៊ី.ខេម បានផ្តល់ឲ្យទៅគាត់។ សំណួររបស់ខ្ញុំ ចំពោះលោកគឺថា តើអាចទៅរួចដែរទេថា ក្នុងការផ្តល់ឲ្យយើងនូវព័ត៌មានមួយចំនួនដែលរក្សាទុកនៅក្នុងប្រអប់នេះ ៣១៧ នេះចំពោះឯកសារនីមួយៗទាំងអស់នោះៗបាទ។ ខ្ញុំសន្និដ្ឋានជា នេះគឺជាបញ្ហា អាយ.ធី ដោយត្រង់ដែលថា លោកអាចនឹងផ្តល់ព័ត៌មានជូនតុលាការ និងភាគីទាំងអស់នៅទីនេះថ្ងៃនេះបានបាទ។

[០៩:២៥:៥៦]

**ឆ៖** លោកចង់និយាយថា ខ្ញុំអាចផ្តល់ប្រភពព័ត៌មានដែលទាក់ទងនឹងឯកសារដែលខ្ញុំឲ្យទៅសហចៅក្រមស៊ើប-- សហព្រះរាជអាជ្ញា? បាទ ខ្ញុំអាចជូនបានបើសិនជាលោកចង់ដឹងថា អ្នកណាឲ្យខ្ញុំពេលណា? ថ្ងៃណា? ខែណា? ឆ្នាំណា? ខ្ញុំមានហ្វូតូកូពីទុកបាទ។

**សៈ** លោក ឆាំង យុ ដើម្បីឲ្យច្បាស់ ខ្ញុំមិនសួរលោកអំពីការពន្យល់ជាព័ត៌មានទូទៅ ដែលលោកប្រើទេ ដែលថា លោកអាច ដែលថាឯកសារមួយៗលោកបានផ្តល់ទៅឲ្យសហព្រះរាជអាជ្ញា តើលោកអាចផ្តល់ព័ត៌មានដែលមានចែងនៅក្នុងប្រអប់ ៣១៧ ទាក់ទងអំពីប្រភពនៃឯកសារនីមួយៗ ថាតើប្រភពហ្នឹងចេញមកពីណា? ម្ចាស់ដើមជានរណា? ឯកសារមួយហ្នឹងតើលោកអាចបញ្ជាក់ជូនតុលាការបានទេបាទ?

**ឆៈ** ខ្ញុំគិតថា មានរួម ប៉ុន្តែមិនលម្អិត ដូចឧទាហរណ៍ក្រសួងមហាផ្ទៃច្បាស់ជាមាន ទួលស្លែងច្បាស់ជាមាន ប៉ុន្តែមិនលម្អិតដល់ថា ឈ្មោះណា ថ្ងៃណា ខែណាឆ្នាំណា។

[០៩:២៧:២១]

**សៈ** ប្រហែលជាលោកមិនមែនជាបុគ្គលដែលអាចនឹងឆ្លើយសំណួរខ្ញុំនេះបានទេ ដោយហេតុថាលោកមិនស៊ីជម្រៅទៅដល់បច្ចេកទេសនោះទេ ប្រហែលជាលោក អនុប្រធានរបស់លោកច្បាស់លោកចំណុចនេះមើលទៅ។ តើលោកគិតថាអាចទៅរួចទេដែលនៅពេលដែលយើងដកស្រង់ព័ត៌មានចេញពីដេតាបេស នោះ អាចយើងព័ត៌មាននៅក្នុងប្រអប់ ៣១៧ ទាក់ទងទៅនឹងប្រភពឯកសារហើយនិង អាចនិង អាចជាម្ចាស់ពីមុន ឬក៏ម្ចាស់បច្ចុប្បន្ន នៃឯកសារដែលលោកបានទទួលនោះបាទ។

**ឆៈ** ខ្ញុំគិតថាអាចមានបាទ ពីព្រោះឯកសារខ្លះមកជាបុគ្គល ក៏យើងដាក់ឈ្មោះជាបុគ្គលដែរ។ ឯកសារខ្លះមកជារួម មកជាស្ថាប័ន យើងដាក់ជាស្ថាប័ន។ ខ្ញុំសូមបញ្ជាក់លោកម្តងទៀត វាមិនលម្អិត ហើយបើសិនជាលោកចង់បានលម្អិត ខ្ញុំមាន ត្រង់ថានៅក្នុងទិន្នន័យនេះយើងដាក់ជារួម ប៉ុន្តែយើងមិនដាក់ឈ្មោះ ដូចជាឧទាហរណ៍ ខ្ញុំឲ្យកាលពីលើកមុន មានម្នាក់ឲ្យរូបថតខ្ញុំមកពីប្រទេសជប៉ុនអ៊ីចឹងគាត់មិនចង់ដាក់ឈ្មោះគាត់ទេ។ អ៊ីចឹង ខ្ញុំដាក់ថា មកពីប្រទេសជប៉ុនអ៊ីចឹងទៅ ប៉ុន្តែបើលោកដេញដោលចង់បានលម្អិត ខ្ញុំមានឯកសារនៅលើតុខ្ញុំហ្នឹង អាចប្រគល់ជូនបាន។

[០៩:២៨:៣៨]

**សៈ** បាទ អរគុណ។ ខ្ញុំគិតថា អាចបំភ្លឺបញ្ហានេះបានមួយកម្រិត ហើយខ្ញុំសូមអនុញ្ញាតពិនិត្យមើលទំព័រដដែលនៅលើ *មេញួល* ដដែលហ្នឹង។ សូមអនុញ្ញាតតុលាការបង្ហាញលើអេក្រង់ គឺនៅក្នុងប្រអប់ ៣១៦។ បាទ ៣១៦ គឺប្រអប់ពណ៌*ប្លូ* --ពណ៌ខៀវ។ ឥឡូវនេះ ខ្ញុំអានដើម្បីឲ្យអ្នកដែលមិនអាចអាននោះគឺថា កំណត់សម្គាល់ទាក់ទងទៅនឹងការថតចម្លងឯកសារ ដែលបានធ្វើកាតាឡុក គឺថា ដែលគេអាចប្រើហើយមានវាយជាអង្គុយលីលេខ មានសរសេរដៃ ហើយយើងបានចម្លងសរសេរដៃ ហើយក៏

បានថតចម្លង ឬក៏បានព្រីន បានបោះពុម្ពចេញ។ សំណួរខ្ញុំចំពោះលោកគឺថា តើត្រូវទេបើខ្ញុំសន្និដ្ឋានថា នេះជាវិធីដែលលោកធ្វើចំណាត់ថ្នាក់ ដែលឯកសារលោកមាននៅក្នុង ឌី.ស៊ី.ខេម ទាំងឯកសារទាំងអស់ ដែលវាច្បាប់ដើមរបស់សម័យកម្ពុជាប្រជាធិបតេយ្យហ្នឹងដែរ អ៊ីចឹងដែរឬទេបាទ?

**ឆៈ** ខ្ញុំថាត្រឹមត្រូវបាទ នៅក្នុងពាក្យថា *ស៊ីប៊ីប-ប៊ីប្លអូក្រាហ្វី* ជាគន្លងនិទ្ទេស ជាភាសាខ្មែរ។ អ៊ីចឹងគន្លងនិទ្ទេសនេះវាទូលំទូលាយណាស់ វាមានជាឯកសារបោះពុម្ព ឯកសារសរសេរ ឯកសារព្រីនជាដើម ហើយយើងព្យាយាមៗ ដាក់ឱ្យបានច្រើនទៅតាម ដែលយើងអាចធ្វើទៅបាន ហើយសូមលោកថា នៅក្នុងប្រព័ន្ធទិន្នន័យនេះ គឺយើងយកមកពីអង្គការសហប្រជាជាតិឈ្មោះថា *ស៊ីឌីអេសអាយស៊ីស* អ៊ីចឹងនៅក្នុងកាឡោនវាមួយៗហ្នឹងមានកំណត់តួអក្សរដែលអាចដាក់ចូលទៅបាន និងទម្រង់ដែលអាចដាក់ចូលទៅបាន។ អ៊ីចឹងយើងព្យាយាម យកភាគច្រើនៗដែលយើងអាចដាក់ចូលទៅបាន ពីព្រោះថានៅក្នុងគន្លងនិទ្ទេសនីមួយហ្នឹង វាមានរូបរាងច្រើន។ អ៊ីចឹងនេះ ខ្ញុំគិតថាជាព័ត៌មានដែលយើងដាក់ចូលទៅដែរ ប្រសិនជាមាន ឬអាចដាក់ចូលទៅបាន។

**សៈ** សូមអរគុណ។ ដូច្នេះ ខ្ញុំនឹងសួរសំណួរដដែល ការិយាល័យសហព្រះរាជអាជ្ញាបានផ្តល់ឱ្យយើងខ្ញុំនូវឯកសារ បញ្ជីឯកសារមួយចំនួនដែលពួកគាត់បានពឹងផ្អែក ហើយគាត់បញ្ជាក់ថាមជ្ឈមណ្ឌលរបស់លោកបានឱ្យទៅពួកគាត់។ ថាតើ ឌី.ស៊ី.ខេម អាចផ្តល់ឱ្យព័ត៌មានទាំងឡាយដែលលោកបានដាក់បញ្ចូលនៅក្នុងប្រអប់ ៣១៦ ទាក់ទងទៅនឹងប្រភព ឬក៏ថាឯកសារហ្នឹងជាឯកសារដើម ឬក៏ឯកសារប្រភេទណាបានដែរឬទេ?

[០៩:៣១:១៥]

**ឆៈ** លិខិតស្នើសុំពីការិយាល័យសហព្រះរាជអាជ្ញាជាទូទៅ លេខឯកសារ ឧទាហរណ៍ដូចជាលោក វីញ្ញៀម ស្មីត គាត់ផ្ញើបញ្ជីឯកសារវែងមួយមកឱ្យខ្ញុំ មានលេខ“D” ហូរហែអ៊ីចឹងមក។ ហើយជាទូទៅគឺជាអ្វីជាសំណើរបស់គាត់។ អ៊ីចឹងយើងបានសួរគាត់ថា គាត់ចង់បានជាយ៉ាងដូចម្តេច? ចង់បានជាស្កេន ឬក៏ហ្វូតូកូពី អ៊ីចឹងបើគាត់ថាចង់បានស្កេន យើងក៏ស្កេនទៅ បើគាត់ចង់បានថា ហ្វូតូកូពី យើងក៏ហ្វូតូកូពីទៅ។ អ៊ីចឹងយើងឱ្យទៅតាមសំណើរបស់គាត់ បើសិនជាគាត់សួរទាំងអស់នេះ ប្រហែលខ្ញុំឱ្យដែរ។ ប៉ុន្តែជាទូទៅគឺវិធីសាស្ត្រ គឺរបៀបដែលគាត់ស្នើសុំហ្នឹងគឺទូលំទូលាយ ហើយសាមញ្ញ គាត់ប្រាប់ថា យុ ខ្ញុំត្រូវការឯកសារ៤០ លេខនេះៗ ហើយខ្ញុំក៏ប្រគល់ទៅឱ្យលោក ដារ៉ា ហើយគាត់ធ្វើហ្វូតូកូពីជូនគាត់ទៅ។ មានតែប៉ុណ្ណឹងជាមួយខាង អូ.ស៊ី.ភី បាទ។

[០៩:៣២:១៨]

**ស៖** ហាក់បីដូចជាមានការយល់ច្រឡំគ្នា ដោយសារតែការបកប្រែ។ ប៉ុន្តែខ្ញុំមិនចង់សួរអំពីការបញ្ជូនឯកសាររវាង ឌី.ស៊ី.ខេម និង អ.វ.ត.ក នេះទេ។ ខ្ញុំសួរលោក សួរអំពីព័ត៌មានដែលលោកបានរក្សាទុកនៅឯ ឌី.ស៊ី.ខេម។ ដោយសារថានៅក្នុងប្រអប់ ៣១៦នេះ គឺលោកបានរក្សាទុកនៅព័ត៌មានថាតើឯកសារនេះ ជាឯកសារដើម ឬក៏ជាឯកសារថតចម្លង ឬក៏ជាឯកសារប្រភេទណាមួយទៀតនោះ។ សំណួររបស់ខ្ញុំថា តើលោកអាចផ្តល់មកឲ្យយើងខ្ញុំនូវឯកសារនីមួយៗទាក់ទងទៅនឹងព័ត៌មានដែលមាននៅក្នុងប្រអប់ ៣១៦នេះបានឬទេ?

[០៩:៣៣:០៦]

**ឆ៖** លោកចង់ថា ក្រុមលោកចង់សុំពីខ្ញុំឥឡូវ? បើសិនជាលោកចង់សុំ ខ្ញុំអាចជូនលោកបានបាទ។

**ស៖** ខ្ញុំសូមអធ្យាស្រ័យមិនចង់ឲ្យព័ត៌មានទាំងអស់ទេ គេសុំត្រឹមតែថាតើ ឌី.ស៊ី.ខេម អាចពន្យល់អំពីព័ត៌មាននៅក្នុងប្រអប់នេះទៅតាមពេលវេលាសមស្របណាមួយដល់យើងខ្ញុំបានទេ?

**ឆ៖** ឧទាហរណ៍បើ “T” បាទ នៅក្នុង *សាប់ហ្វៀល T* នេះ វាអាចជា *ត្រេនស្ក្រីប* វាអាជាបទសម្ភាសន៍ណាមួយ ហើយប្រហែលជាចូលទៅក្នុងប្រភេទ ដេវីដ ហក *ខូឡិចស៊ិន* ពីព្រោះ ដេវីដ ហក គាត់ច្រើនធ្វើជាសម្ភាស *ហេនរ៉ាយធីង* នេះប្រហែលវាទាក់ទងទៅនឹងឯកសារខ្លះ សរសេរដោយដៃតាមដែលខ្ញុំចាំ លោក ប៉ែន យៀរនិន ធ្លាប់បានសម្ភាសន៍បានសរសេរដោយដៃ។ មានឯកសារខ្លះជាហ្វូតូកូពី ខ្ញុំគិតថាមកពីប្រទេសស៊ុយអែត។ ឯកសារខ្លះជាសរសេរដៃហើយ ហ្វូតូកូពី គឺប្រហែលជាទាក់ទងទៅនឹងកំណត់អចិន្ត្រៃយ៍នៃបក្ស-- មជ្ឈិមបក្សនៃបក្សកុម្មុយនីស្តកម្ពុជា ដែលនៅលើនោះមាន លោក ដេវីដ ឆេនដ័ល័រ មាន ប៉ែន យៀរនិន មាន ហ្វូលីយ៉ូ ហៀលជ្រេស ដែលគាត់បានឲ្យហ្វូតូកូពីមកឲ្យខ្ញុំ ហើយមានសរសេរអក្សរខ្លួនគាត់នៅលើហ្នឹង។ *ខូបព្លីខេត* ដែលថាឯកសារខ្លះមានពីរ បាទដូចជាទង់បដិវត្តអ៊ីចឹងវាមានស្ទួន មានច្រើន។ ឯកសារ *ព្រីន* គឺទាក់ទងទៅនឹងទស្សនាវដ្តី បាទទស្សនាវដ្តីនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យមានច្រើនលើពីទង់បដិវត្តទៅទៀត មានទស្សនាវដ្តីកម្ពុជា ទស្សនាវដ្តីកម្ពុជាប្រជាធិបតេយ្យ ហើយទស្សនាវដ្តីខ្លះជាភាសាបារាំងក៏មានដែរ។

នេះជាប្រភេទដែលយើង-- ដែលខ្ញុំអាចផ្តល់ជូនលោកតាមការដែលខ្ញុំមើលឃើញភ្លាមៗបាទ។

[០៩:៣៥:០១]

**ស៖** ជាការត្រឹមត្រូវហើយ។ ដូច្នេះព័ត៌មានប្រភេទនេះ គឺថាលោកបានកត់ត្រានូវព័ត៌មានប្រភេទនេះនៅក្នុងទិន្នន័យរបស់លោក។ តើត្រឹមត្រូវទេ គឺមានន័យថាលោកផ្ទុកទិន្នន័យសម្រាប់ឯកសារនីមួយៗអ៊ីចឹងមែនទេ?

**ឆ៖** ខ្ញុំថាអាចៗមាន ដោយសារវាតម្រូវឲ្យបុគ្គលិកចុះធ្វើឯកសារទាំងអស់នេះ។

**ស៖** អ៊ីចឹងតើត្រឹម-- ខ្ញុំថានេះត្រឹមត្រូវ តែលោកអាចនឹងផ្ដល់ព័ត៌មាននេះមកឲ្យយើងខ្ញុំប្រសិនណាជាអង្គជំនុំជម្រះបង្គាប់ឲ្យលោកធ្វើការពន្យល់ ឬក៏ផ្ដល់ព័ត៌មាននេះមកឲ្យខាងយើងខ្ញុំ?

**ឆ៖** បាទ ខ្ញុំអាចប្រគល់ជូនបាន លោកប្រធាន។

**ស៖** លើគេហទំព័ររបស់លោក យើងបានរកឃើញនូវ*ប្រូតូកូល* ពិធីសារមួយសម្រាប់កាលៈទេសៈទាំងឡាយ ដែលថាបើសិនណាអាចចង់បានមើលការពិនិត្យ *ហ្វ័រេនស៊ិក* ជាកោសល្យវិច័យនោះខ្ញុំចង់បង្ហាញ វាមិនពាក់ព័ន្ធទេ អ៊ីចឹងខ្ញុំមិនទាន់ចង់បង្ហាញឯកសារហ្នឹងទេ។ សំណួរខ្ញុំ ថាតើលោកបានដឹងអំពីប្រូតូកូល ពិធីសារ ដែល ឌី.ស៊ី.ខេម បានធ្វើឡើងប្រសិនណាអ្នកណាចង់សុំឲ្យមានការពិនិត្យផ្នែកខាងកោសល្យវិច័យទៅលើឯកសារណាមួយនោះ?

[០៩:៣៦:៣៦]

**ឆ៖** កាលពីសប្ដាហ៍មុន ខ្ញុំបានជម្រាបរួចហើយ យើងបានព្យាយាមធ្វើកិច្ចព្រមព្រៀងមួយជាមួយ អ.វ.ត.ក តាំងពីឆ្នាំ២០០៥។ ខ្ញុំបានធ្វើដំណើរទៅញូវយក ជួបអ្នកស្រី មីសែលលី ខ្ញុំបានជួបជាមួយលោក ស៊ាន វិសុទ្ធ ខ្ញុំបានជួបជាមួយ-- អំធ្វើសំបុត្រមក ឃ្នុត មក តូនី ក្រាញ់។ ព្រោះយើងបានដឹងរំពឹងគិតថា ថ្ងៃណាមួយ ប្រហែលជាតុលាការត្រូវការមើលឯកសារដើម។ អ៊ីចឹង ខ្ញុំក៏បានឲ្យទីប្រឹក្សារបស់ខ្ញុំរៀបចំជាវិធីសាស្ត្រមួយ ក្នុងករណីណាដែលតុលាការចង់ផ្ទៀងផ្ទាត់អំពីឯកសារហ្វូតូកូពីនិងឯកសារដើម។ ប៉ុន្តែសំណើទាំងអស់នេះមិនត្រូវបាន អ.វ.ត.ក យល់ព្រម ឬក៏ឆ្លើយតបទេបាទ។ ខ្ញុំធ្វើសំបុត្រមក តូនី ហើយ ឃ្នុត ហ្នឹងច្រើនដង តែមិនឆ្លើយទាល់តែសោះ។ ហើយខ្ញុំចាត់ទុកថាជាការព្រងើយកន្តើយនឹងភាពចាំបាច់របស់ឯកសារ។ អ៊ីចឹងយើងបានគ្រោងទុកបញ្ហានេះយូរមកហើយៗខ្ញុំចង់ឲ្យមានកិច្ចព្រមព្រៀងមួយដើម្បីស្រួលធ្វើការងារក្នុងការបញ្ជូនឯកសារ ក្នុងការផ្ទៀងផ្ទាត់ឯកសារ ក្នុងការផ្សេងៗទាក់ទងទៅនឹងឯកសារ។ ប៉ុន្តែគ្មានចម្លើយទាល់តែសោះពី អ.វ.ត.ក។

[០៩:៣៧:៣៣]

អ៊ីចឹងបើសិនជាលោកត្រូវការមើលបញ្ហានេះ យើងអាចពិនិត្យសាឡើងវិញ យើងអាចរៀបចំជា

កន្លែង យើងអាចរៀបចំជាសម្ភារៈផ្សេងៗដែលចាំបាច់សម្រាប់ឲ្យលោកអញ្ជើញទៅធ្វើការផ្ទៀងផ្ទាត់រវាងឯកសារថតចម្លង និងឯកសារដើម។

**ស៖** បញ្ហាមួយដែលគួរឲ្យចាប់អារម្មណ៍ណាស់ ប្រហែលជាខ្ញុំនឹងបកមកចម្លើយរបស់លោកពេលក្រោយ ប៉ុន្តែសំណួររបស់ខ្ញុំពេលនេះ គឺទាក់ទងទៅនឹងការធ្វើកោសល្យវិច័យជាទូទៅនៅខាងក្រៅផ្នែកខាងជំនាញ ឧទាហរណ៍នៅពេលមក ឌី.ស៊ី.ខេម ខ្ញុំចង់បានឯកសារមួយ ដើម្បីពិនិត្យទៅតាមបច្ចេកទេសកោសល្យវិច័យ ថាតើឯកសារនេះវាមកពី៧៥ ទៅដល់ឆ្នាំ៧៩ ចន្លោះពេលហ្នឹង ឬក៏អត់? ដូច្នេះខ្ញុំសួរថាតើលោកនៅចងចាំអំពីវិធីសាស្ត្ររបស់លោកក្នុងពេលដែលគេស្នើសុំបែបនេះទេ? លោកនៅចាំបានទេ?

[០៩:៣៨:៤១]

**ឆ៖** ខ្ញុំជម្រាបពីសប្តាហ៍មុនហើយ យើងអត់មានការធ្វើកោសល្យវិច័យជាលក្ខណៈវិទ្យាសាស្ត្រទេ គឺយើងសំអាងទៅលើបុគ្គលិកដែលមានជំនាញ ធ្វើការជាច្រើនឆ្នាំ ហើយយើងសហការជាមួយបណ្ណសារស្ថានជាតិ បណ្ណាល័យជាតិ និងសារមន្ទីរទួលស្លែង ដែលមានបុគ្គលិកជំនាញធ្វើការដប់-ម្ភៃឆ្នាំមកហើយ។ អ៊ីចឹងវិធីមួយដែលយើងសម្គាល់ថា តើឯកសារនេះជាឯកសាររបបកម្ពុជាប្រជាធិបតេយ្យដូចខ្ញុំជម្រាបលោកកាលពីសប្តាហ៍មុនអ៊ីចឹង គឺយើងមើលពណ៌ មើលកាលបរិច្ឆេទ មើលសាច់រឿងមើលអ្នកនិពន្ធ មើលៗទំហំរូបរាងរបស់វា។ ហើយឯកសារទាំងអស់នេះ វាប្រស្រាក់ទាក់ទងគ្នា វាមិនអាចមើលតែមួយហើយ កំណត់បានទេ ពីព្រោះមានឯកសារផ្សេងទៀត វាឆ្លើយឆ្លងគ្នា។ អ៊ីចឹងទាំងអស់នេះជាកត្តាមួយដែលយើងកំណត់សម្គាល់ថា ឯកសារនេះគឺមកពីរបបកម្ពុជាប្រជាធិបតេយ្យ។

ទីពីរទៀត គឺខ្ញុំសូមបញ្ជាក់នៅមជ្ឈមណ្ឌលឯកសារកម្ពុជាគ្មានសម្ភារៈបច្ចេកទេស *ហ្វ៊័រវិនស៊ិក* ដូចដែលថាយើងយកទៅ មានម៉ាស៊ីនមួយដើម្បីស្កេន គឺបញ្ជាក់ថាឯកសារនេះមានអាយុប៉ុន្មានៗនុ៎ងគឺយើងអត់មានទេ។ យើងមិនដែលមានទាល់តែសោះ។

**ស៖** សូមអរគុណលោក ឆាំង យុ។ សូមអធ្យាស្រ័យដែលខ្ញុំបង្អាក់លោកត្រឹមនេះ។ បើទោះបីលោកកំពុងតែឆ្លើយទៅនឹងសំណួរដ៏គួរឲ្យចាប់អារម្មណ៍នេះក៏ដោយ។ ខ្ញុំគិតថា ខ្ញុំប្រើប្រាស់ពេលវេលានេះឲ្យមានប្រយោជន៍ច្រើនទៀត។ អ៊ីចឹងខ្ញុំអធ្យាស្រ័យដែលរំខានលោកដោយមិនមានការគួរសមនោះ។

ទាក់ទងទៅនឹងការធ្វើកោសល្យវិច័យខ្ញុំសូមលើកឡើងបន្ថែមបន្តិចទៀត។ ថាតើលោកអាចជម្រាបខ្ញុំបានទេ អ្នកណាម្នាក់ដែលមកពីខាងក្រៅ ឌី.ស៊ី.ខេម អ្នកណាម្នាក់ដែលមិនមែនជាអ្នកជំនាញ ឬដែល

ស្នើសុំឲ្យ ឌី.ស៊ី.ខេម ឲ្យផ្តល់ការធ្វើកោសល្យវិច័យទៅលើឯកសារមួយណាដែរឬទេ? ដែលមានទេ?

**ឆ៖** ខ្ញុំគិតថា ដូចជាមានម្នាក់ ឈ្មោះលោក ទូច បូរ៉ា មកពីប្រទេសអូស្ត្រាលី ជាមិត្តភក្តិដែរ។ គាត់ច្រើនតែនិយាយជាមួយខ្ញុំថា ធ្វើម៉េចបញ្ជាក់យ៉ាងម៉េចឲ្យដឹងថា ឯកសារនេះមកពីសម័យខ្មែរក្រហមបាន? លោក ទូច បូរ៉ា សព្វថ្ងៃគាត់រស់នៅប្រទេសអូស្ត្រាលី។

**សះ** ដូច្នេះតើគាត់មានបានទទួលការធ្វើកោសល្យវិច័យទៅលើឯកសារណាមួយដូចដែលគាត់ស្នើសុំនោះទេ?

[០៩:៤១:២២]

**ឆ៖** គាត់បានស្នើមកខ្ញុំ ប៉ុន្តែគាត់មិនបាន *ហ្វូឡូ អាប់* មិនបានមកសួរបន្ថែមទៀត ឬក៏មិនមានការសួរជាលើកទីពីរ។ ប៉ុន្តែគាត់ជាមនុស្សម្នាក់ដែលខ្ញុំចាំ គាត់ធ្លាប់សួរខ្ញុំ។

**សះ** ក្នុងឋានៈលោកជានាយកមជ្ឈមណ្ឌលឯកសារកម្ពុជា តើលោកមានស្គាល់ឈ្មោះអ្នកជំនាញកោសល្យវិច័យណាម្នាក់ ដែលអាចនឹងមកធ្វើយថាភាពទៅលើឯកសារណាមួយនោះបានឬទេ?

**ឆ៖** លោកចង់និយាយអំពី *ហ្វ័រវិនស៊ិក* ក្រដាស ឬក៏ព័ត៌មាន?

**សះ** ខ្ញុំនិយាយអំពីការធ្វើកោសល្យវិច័យបែបរូបវន្តតែម្តង មើលក្រដាសតែម្តង។

**ឆ៖** យើងបានរំពឹងទៅលើបណ្ណសារដ្ឋានជាតិ ដែលមានជំនាញកិច្ចការនេះរយៈពេល៣០ឆ្នាំហើយបាទ។

**សះ** ខ្ញុំសូមបន្តសួរ បង្ហាញឯកសារជាក់លាក់មួយចំនួនទៀត ជាពិសេសឯកសារដែលខ្ញុំចង់លើកឡើងបញ្ហាសំខាន់ៗសង្ខេប រួចហើយខ្ញុំនឹងសួរជាសំណួរ។ សហការីរបស់ខ្ញុំ លោក សុន អរុណ គាត់បាននិយាយអំពីសៀវភៅខ្មៅ ជាមួយនឹងអនុប្រធានរបស់លោកនោះ។ អ៊ីចឹងសំណួររបស់ខ្ញុំពេលនេះ លោកឆាំង យុ តាមដែលលោកដឹង តើមានឯកសារដើមនៃសៀវភៅខ្មៅនេះដែរឬទេ គឺជាសៀវភៅខ្មៅដែលបានបង្កើតឡើងនៅក្នុងរបបសម័យកម្ពុជាប្រជាធិបតេយ្យនោះ?

[០៩:៤៣:២៤]

**ឆ៖** ខ្ញុំបាននិយាយជាមួយលោក អរុណ ដែរ ពេលសម្រាកប្រាប់គាត់ខ្លះៗដែរ។ ពីព្រោះខ្ញុំបានដឹងថាគាត់ចាប់អារម្មណ៍រឿងសៀវភៅខ្មៅនេះ ហើយខ្ញុំដឹងថា អនុប្រធានរបស់ខ្ញុំច្រឡំជាមួយសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ដែលពណ៌ខ្មៅដែរ។ ខ្ញុំដឹង។ សៀវភៅខ្មៅដែលលោក សុន អរុណ មាននៅក្នុងដៃជាភាសាអង់គ្លេសនេះ គឺជាឯកសារបកប្រែទេ ដែលបោះផ្សាយឡើងដោយក្រសួងព័ត៌មាន

នៃរបបកម្ពុជាប្រជាធិបតេយ្យឆ្នាំ៧៨ នៅទីក្រុងញូវយ៉ក សហរដ្ឋអាមេរិក។ ឯកសារដើមនៃសៀវភៅខ្មៅនេះ គឺជាភាសាបារាំង មានចំណងជើងថា *"លីវរ៍ណ័រ"*។ ឯកសារខ្មៅជាភាសាបារាំងនេះ គឺលោកអាចរកជាមួយលោក ហ្គុនណា បឺយស្ត្រម គឺជាសកម្មជនម្នាក់ដែលគាំទ្ររបបកម្ពុជាប្រជាធិបតេយ្យរស់នៅប្រទេសស៊ុយអែត ឬក៏លោកអាចសួរទៅអ្នកស្រី ឡូរ៉ា សាំម៉ី ដែលបច្ចុប្បន្ននេះជាសាស្ត្រាចារ្យនៅសាកលវិទ្យាល័យហុល ប្រទេសអង់គ្លេស។ ហើយយើងមានឯកសារមួយទៀតដែរ ដែលខ្ញុំប្រាប់លោក អរុណ ជាភាសាបារាំង ហើយជាឯកសារដើមក៏យើងមានដែរ។ ហើយឯកសារដើមនេះ សូមលោកចាំថា មានទម្រង់ខុសពីឯកសារដែលបោះពុម្ព ហើយមានផែនទីមួយ។ ខ្ញុំចាំមានផែនទីមួយនៅខាងក្រោយ ផែនទីនេះគឺជាផែនទីប្រហែលជាឆ្នាំ៧២-៧៣ ដែលក្រសួងព័ត៌មានរបស់កម្ពុជាប្រជាធិបតេយ្យបានប្រើប្រាស់បង្ហាញអំពីសមត្ថភាពដែលខ្លួនបានចាប់ផ្តើមគ្រប់គ្រងតំបន់ទាំងអស់ មុនពេលដែលកាន់កាប់អំណាចនៅក្នុងឆ្នាំ១៩៧៥។ អ៊ីចឹងបើសិនជាលោកចង់បានជាភាសាបារាំងខ្ញុំអាចកូពីជូន ហើយអាចប្រគល់ជូនថ្ងៃណាក៏បាននៅក្នុងស្រុកខ្មែរ។ ប៉ុន្តែបើលោកចង់បានអាដើមមួយទៀត ហើយសូមបញ្ជាក់ថា សៀវភៅ *"លីវរ៍ណ័រ"* នេះមានបកប្រែជាភាសាស៊ុយអ៊ែត ទៀតផង។ បាទ មានជាភាសាផ្សេងទៀត ក្រៅពីភាសាបារាំង និងភាសាអង់គ្លេស។

[០៩:៤៥:១៥]

**ស៖** ដូច្នេះតាមដែលខ្ញុំយល់ គឺឯកសារដើម គឺជាភាសាបារាំង។ អ៊ីចឹងមែនទេលោក?

**ឆ៖** ត្រឹមត្រូវ បាទជាភាសាបារាំង។

**ស៖** តើលោកអាចជម្រាបខ្ញុំបានទេ តាមដែលលោកដឹងនោះ អំពីឯកសារដើមជាភាសាបារាំងនេះ ថាតើខ្ញុំអាចរកនៅទីណាបាន?

**ឆ៖** ខ្ញុំមានមួយដែរ បើសិនជាលោកចង់បាន ខ្ញុំកូពីជូន ហើយលោក ហ្គុនណា បឺយស្ត្រម មានដែរ បើសិនជាលោកចង់បានប្រភពផ្សេងទៀត ក្រៅពីមជ្ឈមណ្ឌលឯកសារកម្ពុជា ឬក៏លោកស្រី ឡូរ៉ា សាំម៉ី នៅប្រទេសអង់គ្លេស បាទ។

**ស៖** ប្រភពទីពីរលោកទើបលើកឡើងអម្បាញ់មិញនៅទីណា លោកសូមបញ្ជាក់ម្តងទៀត?

**ឆ៖** អឺ! ខ្ញុំនិយាយលឿនបន្តិច។ បាទ ទីមួយខ្ញុំមានជាភាសាបារាំងក៏មាន នៅមជ្ឈមណ្ឌលឯកសារកម្ពុជា។ ទីពីរមាននៅជាមួយលោក ហ្គុនណា បឺយស្ត្រម។ បាទ ហ្គុនណា បឺយស្ត្រម គឺជាសកម្មជនមួយរូបដែលគាំទ្ររបបកម្ពុជាប្រជាធិតេយ្យ ហើយធ្លាប់មកទស្សនកិច្ចនៅក្នុងឆ្នាំ៧៨ ខែ

សីហា។ ប្រភពមួយទៀត គឺលោកអាចសួរទៅលោកស្រី ឡូរ៉ា សាំម៉ឺ គាត់ជាសាស្ត្រាចារ្យនៅសកលវិទ្យាល័យ ហុល “H-U-L-L” នៅប្រទេសអង់គ្លេស។

[០៩:៤៦:៣៥]

**ស៖** សូមបញ្ជាក់ម្តងទៀតលោក ដោយសារជាភាសាអង់គ្លេសមិនបានបកឈ្មោះឲ្យបានគ្រប់ទាំងអស់នោះទេ។ សូមបញ្ជាក់ម្តងទៀត។ សូមអរគុណច្រើនលោក ឆាំង យុ-- សូមសួរបន្តទៅទៀតចុះ លោកបានជម្រាបមកយើងខ្ញុំ អំពីប្រភពនៃឯកសារដើម សំណួររបស់ខ្ញុំ ថាតើចាប់តាំងពីពេលណាមក ដែលលោកបានដឹងអំពីទីតាំងនៃឯកសារដើមនេះ លោកបានដឹងពីពេលណាមក?

**ឆ៖** ចំពោះ-- សុំទោសខ្ញុំចង់ឆ្លើយទៅសំណួរមុនលោកបន្តិចអំពីរឿងអ្នកបកប្រែ។ ការពិតអ្នកបកប្រែ គ្នាធ្វើការហត់នឿយណាស់។ ហើយឈ្មោះភាសាបរទេសមកភាសាខ្មែរនេះ គឺពិបាកតែម្តងជាពិសេស គឺឈ្មោះពួក*យូរ៉ុបអៀន* បាទ ពិបាកចាំ ហើយពិបាក*ស្ពែល* ហើយជាពិសេសអ្នកខ្លះឈ្មោះជាអេស្បាញ៉ុល បាទ។ អ៊ីចឹងសូមកុំមេត្តាប្រកាន់គ្នា ហើយខ្ញុំគិតថា អ្នកបកប្រែគឺប្រឹងប្រែងសម្បើមណាស់ហើយឈ្មោះនេះ សូមមេត្តាអធ្យាស្រ័យផង។

ចំពោះឯកសារ “*លីវរ៉ើស ណ័រ*” នេះ ខ្ញុំចាប់ផ្តើមដឹងនៅពេលដែលខ្ញុំទៅកាន់ប្រទេសស៊ុយអែតអង្កាល់ណោះ បុគ្គលិករបស់ខ្ញុំម្នាក់រៀននៅទីនោះ កញ្ញា សាន់ កល្យាណ គឺយើងទាំងពីរនាក់បានធ្វើដំណើរទៅផ្ទះលោក ហ្គុនណា បឺយស្ត្រម ហើយប្រមូលឯកសារទាំងអស់នេះ។ ហើយខ្ញុំបានសួរគាត់ពីព្រោះគាត់ឲ្យខ្ញុំសុទ្ធតែឯកសារដើមទាំងអស់ ពីព្រោះប្រពន្ធគាត់មិនចង់ទុកទេ ព្រោះគាត់ថាទុកយូរហើយចង្អៀតផ្ទះគាត់ អ៊ីចឹងប្រពន្ធគាត់ប្រាប់ថាប្រមូលទៅទាំងអស់។ អ៊ីចឹងខ្ញុំ ហើយនិង កល្យាណហ្នឹង ស្ពាយជិះរទេះភ្លើងពីផ្ទះគាត់មក ស្តុកខូម បាទ ជាមួយគ្នាកាន់ទាំងកណ្តាលយប់។

[០៩:៤៨:០៦]

ហើយអ៊ីចឹង ខ្ញុំក៏សួរគាត់ថា ឯកសារនេះមកពីណា ពីណាអ៊ីចឹង។ សួរតាមដែលអាចខ្ញុំសួរទៅបាន។ អ៊ីចឹងខ្ញុំដឹងរឿងឯកសារ “*លីវរ៉ើស ណ័រ*” នេះ តាំងពីពេលដែលខ្ញុំយកឯកសារពីលោកហ្គុនណា។ ហើយខ្ញុំគិតថាប្រហែលជាឆ្នាំដូចជា២០០៤ ឬក៏២០០៥ នៅពេលដែលខ្ញុំទៅហ្នឹង។ ហើយក្រោយមកទៀត ឯកសារទាំងអស់នេះត្រូវបានដឹកមកស្រុកខ្មែរតាមយន្តហោះ ពីព្រោះវាច្រើនពេក។ ហើយអ៊ីចឹងទៅក៏វាមានឯកសារថតចម្លងនៅក្នុងហ្នឹង ហើយប្រហែលជាឯកសារនោះហើយ ដែលខាងក្រុមរបស់លោកស្នើសុំហ្នឹង វាជាភាសាអង់គ្លេស។ ប្រហែលជាលោកមិនមើល មិនចេះភាសាបារាំង

លោកមើលតែជាភាសាអង់គ្លេស សុំតែភាសាអង់គ្លេសទៅ។ តាមពិតនៅក្នុងបញ្ជីឯកសាររបស់ខ្ញុំហ្នឹងក៏មានជាភាសាបារាំងដែរ។ តាមដែលខ្ញុំចាំ “D” ជាងបួនម៉ឺន ពីព្រោះឯកសារនេះដាក់នៅក្នុងក្រោយពេលដែលយើងបានមកពីប្រទេសស៊ុយអែត។

[០៩:៤៨:៥៦]

អ៊ីចឹងបើសិនជាក្រុមរបស់លោកចាប់អារម្មណ៍រឿង *“លីវវ្រ៍ស ណ័រ”* ជាភាសាបារាំង ឬអានភាសាបារាំង ច្បាស់ជាសុំឯកសារហ្នឹងតែម្តង។ ប៉ុន្តែដោយសារក្រុមលោកអានជាភាសាអង់គ្លេស សុំតែជាភាសាអង់គ្លេស លោកក៏បានតែការ *“លីវវ្រ៍ស ណ័រ”* ជាភាសាអង់គ្លេសទៅវិញ បាទ។

**ស៖** ដូច្នេះ តាមការបញ្ជាក់របស់លោក គឺលោកដឹងអំពីទីតាំងនៃឯកសារដើមដែលជាភាសាបារាំង ដែលយើងហៅថាសៀវភៅខ្មៅនេះ គឺចាប់តាំងពីឆ្នាំ២០០៥មកម្ល៉េះ អ៊ីចឹងមែនទេ?

**ឆ៖** ខ្ញុំសូមអធ្យាស្រ័យដែរ ព្រោះមិនច្បាស់ឆ្នាំ ព្រោះខ្ញុំទៅស៊ុយអែតច្រើនដងណាស់។ នៅមានម្នាក់ទៀតឈ្មោះ មូដ អេនគ្រីស “M-A-U-D” បាទ ហើយគាត់បានស្លាប់បាត់ទៅហើយ គាត់គឺជាអ្នកសកម្មជនមែនទែនដែលគាំទ្ររបបនេះ ហើយគាត់បានកំពុងសរសេរសៀវភៅមួយ អំពីតើ ប៉ុល ពត ជាអ្នកណា? ហើយគាត់ក៏ធ្លាប់បានប្រាប់ខ្ញុំដែរ ហើយគាត់បានសរសេរអត្ថបទមួយទៀតចុះនៅភ្នំពេញប៉ុស្តិ៍ ដែលមានចំណងជើងថា “ហេតុអ្វីបានជាមនុស្សច្រើននាក់ត្រូវបានសម្លាប់?” អ៊ីចឹងឆ្នាំនេះ ខ្ញុំសូមអធ្យាស្រ័យ ព្រោះមិនច្បាស់ មិនដឹងជា២០០៤ ឬក៏២០០៥ បាទ។

[០៩:៥០:០៧]

**ស៖** លោក ឆាំង យុ បន្ទាប់ពីលោក ដារ៉ា បានមកបំភ្លឺនៅតុលាការនៅក្នុងបន្ទប់សវនាការនេះរួចហើយថា តើសម្រាប់អ្នកដែលមកពីខាងក្រៅ ឌី.ស៊ី.ខេម នោះ តើគេអាចនឹងមានលទ្ធភាពដឹងអំពីទីតាំងនៃឯកសារដើមឈ្មោះថា “សៀវភៅខ្មៅ” នេះដែរឬទេ?

**ឆ៖** នេះដូចថាខ្ញុំថាអ៊ីចឹង នៅក្នុងសៀវភៅនេះមាននៅក្នុងបញ្ជី បាទក្នុងបញ្ជីរួចហើយ ប៉ុន្តែដោយសារវាជាភាសាបារាំង មនុស្សភាគច្រើនមិនចាប់អារម្មណ៍ ដោយសារភាសានេះគេមិនសូវប្រើប្រាស់។ អ៊ីចឹងគេមើលតែឃើញនៅក្នុងតែជាភាសាអង់គ្លេសបាទ។ ឯកសារនេះលែងមាននៅមជ្ឈមណ្ឌលឯកសារកម្ពុជា។ លោកមើលខ្ទង់បួនម៉ឺនទៅឃើញហើយ ជាងឯកសារបាទ។

**ស៖** សូមអរគុណ លោក ឆាំង យុ។ សំណួររបស់ខ្ញុំអ៊ីចេះ បន្ទាប់ពីលោក ដារ៉ា បានមកផ្តល់ចម្លើយនៅក្នុងបន្ទប់សវនាការនេះក៏គាត់មានលើកឡើងអំពីសៀវភៅខ្មៅនេះដែរ។ ថាតើលោកមានបាន

សួរអ្នកណាខាងណាម្នាក់ដែលមកពីខាងក្រៅ ឌី.ស៊ី.ខេម ដើម្បីឲ្យដឹងថា តើសៀវភៅខ្មៅហ្នឹងវាមានទីតាំងនៅទីណាដែរឬទេ?

**ឆ៖** សូមទោស ខ្ញុំដូចជាអត់ច្បាស់បន្តិច។ លោកចង់សួរថា សូមបើករង្វង់ក្រចកបន្តិច ព្រោះ ដារ៉ា ច្រឡំ ពេលដែលនិយាយគ្នាហ្នឹង ច្រឡំសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យកម្ពុជាប្រជាធិបតេយ្យ។ អ៊ីចឹងពេលហ្នឹង ខ្ញុំគិតថាច្របូកច្របល់បន្តិច ហើយលោកចៅក្រមក៏បានធ្វើអន្តរាគមន៍ដែរ តែ ដារ៉ា ច្រឡំស្មានថា សៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ។ អ៊ីចឹងបើសិនជាលោក សំណួររបស់លោកចង់សួរថាតើមាននរណាម្នាក់ដែលបានសួរខ្ញុំថា សៀវភៅខ្មៅនៅកន្លែងណាដែរឬទេ? លោកចង់សួរអ៊ីចឹង?

[០៩:៥២:០១]

**ស៖** បាទ ជាការត្រឹមត្រូវហើយ គឺលោកដែលធ្វើបែបនេះទេ បន្ទាប់ពីបានស្តាប់សវនាការស្តាប់ចម្លើយរបស់លោក ដារ៉ា នៅក្នុងតុលាការនេះរួចហើយ។

**ឆ៖** អត់មានអ្នកណាសួរអំពីរឿង "សៀវភៅខ្មៅ" នៅកន្លែងណាទេ តាំងពីខ្ញុំធ្វើការមក អត់មានដែលសួរទាល់តែសោះ។ ពីព្រោះសៀវភៅនេះ គឺយើងក៏បានបោះពុម្ពដែរ នៅក្នុងទស្សនាវដ្តីស្វែងរកការពិតជាភាសាខ្មែរ។

**ស៖** សូមអរគុណលោក ឆាំង យុ ប៉ុន្តែនៅតែមិនទាន់ជាចម្លើយមកកាន់សំណួរខ្ញុំនៅឡើយទេ បន្ទាប់ពីលោក ដារ៉ា មកឆ្លើយជូនតុលាការ។ តើលោកមានបានទៅជួបអ្នកណាម្នាក់ ឬក៏សួរអ្នកណាម្នាក់ដើម្បីឲ្យដឹងអំពីទីកន្លែងបច្ចុប្បន្ន ទីកន្លែងសព្វថ្ងៃនៃសៀវភៅខ្មៅនេះ ឬក៏អ្វីក៏ដោយដែលលោកហៅនោះដែរឬទេ? គឺសំដៅទៅលើសៀវភៅដែលលោកបានឆ្លើយអង្កាល់ពីសប្តាហ៍មុនជាភាសាបារាំងដែលមានថា *ឡឺដូស្សេ ឡឺណ័រ* នេះ។

**ឆ៖** ឯកសារនេះខ្ញុំមាននៅខ្លួនឯងហើយបាទ ខ្ញុំមាន "លីវរ៍ស ណ័រ" នៅខ្លួនឯង។ ខ្ញុំមានមួយ ខ្ញុំប្រាប់លោក សុន អរុណ ដែរ ថាបើចង់បានខ្ញុំក្ធពីជូន។ ហើយខ្ញុំបញ្ជាក់ទៀតថា នៅខាងក្រោយមានរូបផែនទី។ ខ្ញុំមានមួយខ្លួនឯង។

[០៩:៥៣:៥៤]

**ស៖** លោក ឆាំង យុ លោកមានបានផ្ញើអ៊ីម៉ែល ទាក់ទងទៅនឹងសៀវភៅខ្មៅនេះ ក្រោយពេលដែលលោក ដារ៉ា បានមកកាន់ទីនេះ ទាក់ទងទៅនឹងទីតាំងនៃឯកសារដើម តើលោកបានផ្ញើអ៊ីម៉ែល

ទាក់ទងរឿងនេះទេ?

**ឆ៖** ខ្ញុំបានសួរបញ្ជាក់ទៅលោក ហ្គុនណា បឺយស្ត្រម ហើយនិង ឡូរ៉ា សាំម៉ឺ បញ្ជាក់បន្ថែមទៀត ថាតើគាត់ច្បាស់ដែរឬក៏អត់? គាត់មានឯកសារទាំងអស់នេះ។ ខ្ញុំបាត់។

**ស៖** តើពាក្យពេចន៍នៅក្នុងអ៊ីម៉ែលហ្នឹង លោកសួរថាម៉េចដែរ សួរចំៗថាម៉េចដែរ?

[០៩:៥៤:៣២]

**ឆ៖** ខ្ញុំអាចជូនអ៊ីម៉ែលហ្នឹងក៏បាន បើសិនជាលោកត្រូវការ។ ខ្ញុំបានសួរលោក ហ្គុនណា បឺយស្ត្រម ថា តើលោកចាំទេ ឯកសារសៀវភៅខ្មៅដែលលោកមាននៅកន្លែងណាឥឡូវនេះ? ពីព្រោះលោកសុន អរុណ បានសួររក។ ហើយខ្ញុំបានសួរទៅអ្នកស្រី ឡូរ៉ា សាំម៉ឺ ថាតើអ្នកស្រីចាំទេ? ថាតើឯកសារនេះឥឡូវវាដល់ណាទៅហើយ? ហើយខ្ញុំក៏មានរបស់ខ្ញុំមួយដែរ ដើម្បីបញ្ជាក់ឲ្យបានច្បាស់ឲ្យមានបីប្រភព។ ខ្ញុំអាចជូនអ៊ីម៉ែលជូនលោកក៏បានដែរ បើសិនជាលោកត្រូវការបាទ។ ពីព្រោះយើងចង់ជួយតុលាការលោក សុន អរុណ គាត់ត្រូវការ អ៊ីចឹងខ្ញុំស្ទះស្វែងភ្លាមៗ។ បាទ ខ្ញុំបានទាក់ទងទៅលោក ហ្គុនណា ឲ្យច្បាស់បញ្ជាក់ ឡូរ៉ា ឲ្យច្បាស់ ហើយខ្ញុំមានខ្លួនឯងមួយទៀត មានដល់ទៅបីកន្លែង បាទឲ្យច្បាស់។

**ស៖** សូមសួរឲ្យចំទៅចុះ សូម្បីតែខ្លួនលោកផ្ទាល់ក៏លោកមានឯកសារដើមជាភាសាបារាំងនៃសៀវភៅខ្មៅនេះដែរ។ ហើយលោកនៅតែផ្ញើអ៊ីម៉ែលទៅប្រភពពីរផ្សេងទៀត ដើម្បីចង់ដឹងថាតើពួកគាត់នោះ កំពុងតែកាន់កាប់សៀវភៅខ្មៅនេះដដែលដែរឬទេ? នេះគឺជាអ៊ីម៉ែលរបស់លោកអ៊ីចឹងរបស់លោកអ៊ីចឹងមែនទេ?

[០៩:៥៥:៤៨]

**ឆ៖** ត្រឹមត្រូវ បាទត្រឹមត្រូវ។

**ស៖** ចុះហេតុអ្វីបានជាលោកមិនគ្រាន់តែពិនិត្យមើលទៅសំណុំឯកសាររបស់លោកទៅ ហើយផ្តល់ឯកសារដើមនៃសៀវភៅខ្មៅនេះមកឲ្យលោក សុន អរុណ ពីសំណុំឯកសារនៅកន្លែងលោកតែម្តងទៅ?

**ឆ៖** តាមពិតខ្ញុំប្រាប់លោក សុន អរុណ រួចហើយ ហើយមួយទៀត ដូចខ្ញុំជម្រាបលោកអ៊ីចឹងភាសានេះមានបកប្រែ មានច្រើនភាសា។ អ៊ីចឹងខ្ញុំចង់ឲ្យច្បាស់ថាតើភាសាណាមួយដែលគាត់មាន? ហើយនៅក្នុងកន្លែងណា? ហើយនៅក្នុងឯកសារដែលខ្ញុំមាននេះ ខ្ញុំបានមកពីគាត់ បានមកពីលោក

ហ្កុនណា បឺយស្រ្តុម អ៊ីចឹងខ្ញុំចង់បញ្ជាក់អំពីខ្សែចង្វាក់ ថាលោកមានចាំទេ លោកធ្លាប់ឲ្យខ្ញុំឯកសារហ្នឹង? ក្នុងករណីដែលលោកសួរអំពីខ្សែចង្វាក់ ថាអ្នកណាជាអ្នកឲ្យខ្ញុំ? មកពីកន្លែងណា? ថ្ងៃណា ខែណា ឆ្នាំណា?

[០៩:៥៦:៣៤]

អ៊ីចឹង ខ្ញុំសូមបញ្ជាក់សាឡើងវិញ។ ពីព្រោះជួនកាលវាមានការភ្លេចភ្លាំងដែរចំពោះអ្នកដែលផ្តល់ឯកសារមកឲ្យយើង។ អ៊ីចឹង ខ្ញុំសួរគាត់ចង់បញ្ជាក់ដើម្បីបង្ហាញអំពីខ្សែចង្វាក់នៃឯកសារដែលខ្ញុំបានទទួល។ ខ្ញុំមាននៅក្នុងដៃរួចហើយៗ បញ្ជីហ្នឹងខ្ញុំប្រាប់លោកទៀត នៅក្នុងខ្ទង់លេខបួនម៉ឺន ខ្ញុំបានឆែករកភ្លាមៗ ឃើញភ្លាមៗតែម្តង។ ទាំងនេះគឺដើម្បីជួយសម្រួលដល់ការទាមទាររបស់លោក បង្ហាញអំពីខ្សែចង្វាក់ យថាភាពនៃឯកសារដែលលោកតែងតែចង់ដឹង។ ខ្ញុំរកមនុស្សដែលធ្លាប់ឲ្យខ្ញុំ ហើយបញ្ជាក់ទៀតថា មានចាំទេ ធ្លាប់ឲ្យឯកសារខ្ញុំមួយ? តើមានចាំទេ ឯកសារនេះមានបកប្រែជាភាសាស៊ុយអែតជាភាសាបារាំង ជាភាសាអង់គ្លេស? នេះបើសិនជាអ្នកស្រី មួង នៅរស់ ខ្ញុំសួរគាត់ទៀត តែគាត់ស្លាប់បាត់ទៅហើយនៅប្រទេសស៊ុយអែតបាទ។

[០៩:៥៧:១៧]

**ស៖** តើហេតុអ្វីបានជាលោកព្យាយាមសួរព័ត៌មានអំពីលោកសាស្ត្រាចារ្យ សាំម៉ឺ?

**ឆ៖** សាំម៉ឺ ហើយនិងខ្ញុំជាមិត្តជិតស្និទ្ធនឹងគ្នា គាត់ជាមនុស្សដែលខ្ញុំគោរព ហើយខ្ញុំធ្លាប់បកប្រែអ៊ំហែម សៀវភៅអ៊ំហែម ជាភាសាខ្មែរកាលខ្ញុំនៅរៀនបាទ អំពីនិក្ខេបបទរបស់អ៊ំហែម ដែលបានសរសេរនៅស្រុកបារាំង។ អ៊ីចឹង ខ្ញុំគោរពគាត់ណាស់ ហើយគាត់ក៏ជាអ្នកជួយដល់ការបង្រៀននៅកន្លែងខ្ញុំដែរ។ អ៊ីចឹងឲ្យតែទាក់ទងទៅនៅក្នុងតំបន់អឺរ៉ុប គាត់ដឹងច្រើន ឲ្យតែទាក់ទងនៅក្នុង*យូរ៉ុបកៀន* សហគមន៍ ហ្នឹង គឺគាត់ដឹងច្រើនណាស់។

អ៊ីចឹង ឲ្យតែទាក់ទងនៅតំបន់ហ្នឹង ខ្ញុំសួរគាត់មុនគេ អ្នកស្រី ឡូរ៉ា សាំម៉ឺ។ សូមបញ្ជាក់ថា គាត់ជាជនជាតិអាមេរិកកាំងទេ ប៉ុន្តែគាត់ទៅនៅប្រទេសអង់គ្លេសបាទ។

[០៩:៥៨:០៨]

**ស៖** សូមអរគុណច្រើន តែនេះមិនមែនជាចម្លើយទៅនឹងសំណួរខ្ញុំទេ។ សំណួរខ្ញុំថា តើលោកមានសួរទៅលោកសាស្ត្រាចារ្យ សាំម៉ឺ ថាតើឯកសារសៀវភៅខ្មៅដើមហ្នឹង វាអាចមានទីតាំងនៅទីណាដែរ? លោកមានបានសួរអ៊ីចឹងទេ?

**ឆ៖** ខ្ញុំអាចមើលអ៊ីម៉ែលខ្ញុំម្តងទៀត ប៉ុន្តែសំណួររបស់ខ្ញុំហាក់ដូចជាសួរថា គាត់មានសៀវភៅខ្មៅដែរឬក៏អត់ នៅកន្លែងណារាល់ថ្ងៃ? គាត់មានការចងចាំដែរឬទេអត់អំពីសៀវភៅនេះ ពីព្រោះខ្ញុំហើយនិងគាត់ធ្លាប់ពិភាក្សាគ្នា។

[០៩:៥៨:៤៧]

**ស៖** សំណួរខ្ញុំថា តើហេតុអីក៏លោកសួរសំណួរហ្នឹងទៅកាន់គាត់?

**ឆ៖** ដើម្បីបញ្ជាក់ទៅតាមលទ្ធភាពដែលអាចធ្វើទៅបាន អំពីយថាភាពនៃឯកសារចំពោះអ្នកទីមួយដែលឲ្យមកខ្ញុំ។ អ៊ីចឹងខ្ញុំព្យាយាមឲ្យអស់ពីលទ្ធភាពដើម្បីកុំឲ្យមានការមន្ទិលសង្ស័យចំពោះ សុន អរុណ ដែលចង់បានឯកសារនេះ។ ដូចខ្ញុំប្រាប់អ៊ីចឹង បើសិនជាខ្ញុំអាចរកមនុស្សផ្សេងទៀត ខ្ញុំសួរទៀតឲ្យច្បាស់ ថាមានច្រើនកន្លែងណាឯកសារនេះ មានភាសានេះៗ។ អ៊ីចឹងខ្ញុំសួរគាត់មុនគេ ដោយសារគាត់ហាក់ដូចជាមនុស្សប្រចាំនៅតំបន់យូរ៉ុប គាត់ដឹងខ្សែចង្វាក់នៅក្នុងអឺរ៉ុបហ្នឹងទាំងអស់។ អ៊ីចឹងគាត់ គឺជាមនុស្សទីមួយ ឲ្យតែទាក់ទងនៅក្នុង ដេនម៉ាក, ហ្វីនឡែន, ស្វីតឌិន ខ្ញុំសួរគាត់ជារៀងរហូត ហើយអ្នកផ្សេងៗទៀត គឺជាមនុស្សបន្ទាប់បន្សំ។

[០៩:៥៩:៣៩]

**ស៖** ខ្ញុំសូមផ្អាកសួរចំណុច “B” នេះទៅចុះ ខ្ញុំសួរទាក់ទងទៅដំណាក់កាលបន្តបន្ទាប់ទៀត។ គឺទាក់ទងទៅនឹងទស្សនាវដ្តីរបស់កម្ពុជាប្រជាធិបតេយ្យ ដែលមាននៅមជ្ឈមណ្ឌលឯកសារកម្ពុជា គឺមានទស្សនាវដ្តីខ្មែរក្រហមនៅទីនោះ។ តើត្រឹមត្រូវទេ? លោកអាចជម្រាបខ្ញុំអំពីប្រភពឯកសារនៃទស្សនាវដ្តីរបស់កម្ពុជាប្រជាធិបតេយ្យ ដែលមាននៅ ឌី.ស៊ី.ខេម នេះដែរទេ? ថាតើទស្សនាវដ្តីនេះ ជាទស្សនាវដ្តីដើម ឬក៏ទស្សនាវដ្តីថតចម្លងទេ?

**ឆ៖** យើងមានទាំងពីរបាទ។ យើងមានទាំងដើមនិងចម្លង ហើយសូមបញ្ជាក់ថា របបកម្ពុជាប្រជាធិបតេយ្យ ប្រហែលជាមិនបានហៅថា ជាទស្សនាវដ្តីទេ អ៊ីចឹងកុំឲ្យប៉ះពាល់ដល់ អំនួន ប្រហែលជាគាត់មិនហៅថាជាទស្សនាវដ្តីទេបាទ ប៉ុន្តែយើងហៅជាទស្សនាវដ្តីសូមបញ្ជាក់កន្លែងហ្នឹងបន្តិច។ យើងមានទង់បដិវត្ត យើងមានយុវជន យុវនារីកម្ពុជា យើងមានកម្ពុជា យើងមានកម្ពុជាប្រជាធិបតេយ្យ យើងមាន*ប៊ូឡឺតាំង* បាទជារបៀបព្រឹត្តិបត្រ ដែលបោះផ្សាយដោយខ្មែរ ដែលគាំទ្ររបបកម្ពុជាប្រជាធិបតេយ្យនៅស្រុកបារាំងក៏យើងមាន យើងមានជា*ប៊ូឡឺតាំង* មានចំណងជើងថា “សេរីការ” ក៏មានយើងមានច្រើនណាស់ ច្រើនប្រភេទ ដែលកាលនុំងខាងកម្ពុជាប្រជាធិបតេយ្យ និងអ្នកដែលគាំទ្ររបប

នេះបានចេញជាឯកសារផ្សេងៗ ហើយនៅក្នុងនោះយើងមានទាំងថតចម្លងក៏មាន មានទាំងដើមក៏មានដែរ។

[១០:០១:១៩]

**ស៖** តើត្រូវដែរឬទេ លោកបាននូវឯកសារទាំងអស់នោះ គឺមានទាំង*ម៉ៃក្រូហ្វីម* ផងដែរអំពីឯកសារទស្សនាវដ្ដីកម្ពុជាប្រជាធិបតេយ្យ ដែលបានមកពីអឺរ៉ុប តើលោកនៅចាំទេ?

**ឆ៖** អឺ! មកជាម៉ៃក្រូហ្វីម? មកជាដុំម៉ៃក្រូហ្វីមតែម្ដង? លោកចង់សួរថា ខ្ញុំបានឯកសារនេះជាដុំហ្វីល ឬក៏ជារូបរាង?

**ស៖** ខ្ញុំនឹងសួរជាថ្មីម្ដងទៀត តើលោកបានទទួលច្បាប់ចម្លង ឬក៏ម៉ៃក្រូហ្វីម នៃឯកសារដែលហៅថា ទស្សនាវដ្ដីកម្ពុជាប្រជាធិបតេយ្យ មកពីប្រភពណាមួយនៅអឺរ៉ុបនោះដែរឬទេ?

**ឆ៖** ខ្ញុំបានទទួលឯកសារថតចម្លងពីលោក ហ្គុនណា ប៊ីយស្រ្គម សាកលវិទ្យាល័យលូនដ៍ គឺជាហ្វូតូកូពី ហើយខ្ញុំបានទទួលឯកសារដើមមកពីស្រុកបារាំង តាមរយៈអ្នកដាក់ដើមបណ្ដឹងរដ្ឋប្បវេណី និងមនុស្សមួយចំនួនបាទ។

[១០:០២:៤៥]

**ស៖** ដូច្នេះលោកបានបញ្ជាក់ថា លោក ប៊ីយស្រ្គម បានផ្ដល់ឲ្យលោកនូវឯកសារ ហើយនិងច្បាប់ដើមមួយចំនួនមកពីបារាំង តើមានអ្នកណាផ្សេង ដែលបានផ្ដល់ជូនលោកនូវទស្សនាវដ្ដីរបស់កម្ពុជាប្រជាធិបតេយ្យដែរឬទេ?

**ឆ៖** ខ្ញុំមិនចាំឈ្មោះ បាទតែមានដោយសារថាវាមានច្រើនសណ្ឋាន។ មានម្នាក់ទៀត ឈ្មោះគាត់ឈ្មោះត្រកូលគាត់ដូចជា ក្រូស គាត់ធ្លាប់ធ្វើការនៅញូវយ៉កថែមស៍ គាត់បានឲ្យព្រឹត្តិបត្រខ្ញុំមួយដែរ-- អ៎ រ៉ូហ្សាណា ក្រូស តាមដែលខ្ញុំចាំ គាត់ធ្លាប់ឲ្យខ្ញុំដែរ គឺជាព្រឹត្តិបត្រមួយនិយាយអំពីរបបកម្ពុជាប្រជាធិបតេយ្យ ជាទស្សនាវដ្ដីមួយដែរ។ យើងធ្លាប់បានមកពីបុគ្គលបាទ បុគ្គលផ្សេងទៀត ប៉ុន្តែខ្ញុំមិនចាំឈ្មោះអស់តែមានបាទ។ ខ្ញុំចូលចិត្តទស្សនាវដ្ដី អ៊ីចឹងខ្ញុំអាន ហើយខ្ញុំក៏ធ្លាប់បានយកមកប្រើប្រាស់នៅក្នុងសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យដែរ។ ខ្ញុំចូលចិត្តទស្សនាវដ្ដីបាទ។

[១០:០៣:៤៦]

**ស៖** បាទ អរគុណ។ នៅសហាថៅក្រុមស៊ើបអង្កេតនោះ លោកបានធ្វើនូវសម្ភាសនូវចម្លើយ ហើយលោកបានបញ្ជាក់ថា នៅឯកសារច្បាប់ដើមកម្ពុជាប្រជាធិបតេយ្យខ្លះ ហើយមានចំណារដែល

និយាយពីជនជាតិវៀតណាម។ តើលោកអាចជម្រាបតុលាការបានទេថាតើឯកសារនោះប្រភេទអី ដែលរកពិនិត្យឃើញថា មានចំណារជាអក្សរវៀតណាមនោះ? ដើម្បីបំភ្លឺ ខ្ញុំនឹងចូលទៅឯកសារមួយទៀត ដែលថាជាឯកសារកម្ពុជាធិបតេយ្យដែរ ដើម្បីឱ្យតុលាការជ្រាបច្បាស់បាទ។

**ឆ៖** តាមដែលខ្ញុំចាំឯកសារនេះ គឺសរសេរនៅលើគម្រប ហើយគម្របនេះអាចជាគម្របរបស់ចម្លើយសារភាពរបស់បុគ្គលណាមួយ។

**ស៖** តើប្រភេទឯកសារនោះជាឯកសារអ្វីដែរបាទ?

**ឆ៖** ឯកសារនេះ បើសិនជាយោងតាមការពិចារណារបស់លោកសាស្ត្រាចារ្យ ប៉ែន យៀរនិន គឺជាឯកសារសន្តិបាល ដែលខ្ញុំបាននិយាយកាលពីសប្តាហ៍មុនបាទ។

[១០:០៥:០៩]

**ស៖** លោកក៏បានបញ្ជាក់ជូនចៅក្រម សហចៅក្រមស៊ើបអង្កេតដែរនៅពេលដែលសម្ភាសនោះ ថានៅឆ្នាំ១៩៧៩ វៀតណាមបានត្រួតត្រាភ្នំពេញ ហើយមានអ្នកជំនាញវៀតណាម ជំនាញការវៀត-ណាមគ្រប់ក្រសួងទាំងអស់ ជាពិសេសអ្នកជំនាញខាងឯកសារផងដែរ។ វៀតណាមគឺអាចមានលទ្ធភាពចូលគ្រប់ទីកន្លែងនៅភ្នំពេញ ហើយពួកគេបានប្រមូលឯកសារ ហើយក៏បានចាប់ផ្តើមធ្វើការចងក្រងឯកសារ។ តើលោកអាចជម្រាបតុលាការបានទេ នូវការប៉ាន់ប្រមាណអំពីថាតើរយៈពេលប៉ុន្មានឆ្នាំដែលវៀតណាមបានការគ្រប់គ្រងនៅលើឯកសារ ដែលកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខ្ញុំចង់និយាយថា មួយឆ្នាំ ពីរឆ្នាំ បីឆ្នាំ ឬក៏យូរជាងនេះបាទ?

[១០:០៦:០២]

**ឆ៖** ចំនួនឆ្នាំ ខ្ញុំមិនប្រាកដដែរ ប៉ុន្តែខ្ញុំបានស្រាវជ្រាវសួររកនៅពេលដែលខ្ញុំឃើញឯកសារនេះ ខ្ញុំចាប់អារម្មណ៍ ព្រោះខ្ញុំឃើញមានអក្សរវៀតណាម ហើយខ្ញុំក៏បានសួរទៅក្រុមរៀបចំឯកសាររបស់ក្រសួងមហាផ្ទៃ។ ក្រុមរៀបចំឯកសាររបស់ក្រសួងមហាផ្ទៃបានប្រាប់ខ្ញុំថា នៅកាលពីជំនាន់នោះ គឺនៅគ្រប់ក្រសួងទាំងអស់គឺមានជំនាញការវៀតណាម ទៅកន្លែងណាក៏មានដែរ។ អ៊ីចឹងគេមានដាក់មនុស្សម្នាក់ឱ្យជួយរៀបចំប្រមូលឯកសារវៀតណាម។ តាមដែលខ្ញុំចាំជំនាញការវៀតណាមមួយនេះ មិនចេះជាភាសាខ្មែរច្បាស់លាស់ទេ។ ហើយខ្ញុំបានស្រាវជ្រាវរកគាត់រហូតទៅដល់ទីក្រុងហាណូយណោះ! តែគាត់បានស្លាប់បាត់ទៅហើយ ខ្ញុំចង់ដឹងថា គាត់ឃើញឯកសារដំបូងនៅកន្លែងណា? អ៊ីចឹងចំពោះរយៈពេល ខ្ញុំគិតថាប្រហែលជារយៈពេលខ្លី ហើយខ្ញុំក៏មិនបានសួរបញ្ជាក់ថា តើប៉ុន្មានឆ្នាំគាត់នៅទីនេះ? ប៉ុន្តែ

លោកអាចសួរទៅក្រុមរៀបចំឯកសាររបស់ក្រសួងមហាផ្ទៃបាន។ ព្រោះសព្វថ្ងៃនៅក្នុងចំណោមក្រុមប្រាំនាក់នេះ តាមខ្ញុំដែលខ្ញុំដឹងពីរនាក់នៅធ្វើការនៅឡើយ ហើយប្រហែលជាពីរនាក់ទៀតទៅរស់នៅប្រទេសអូស្ត្រាលី។ អ៊ីចឹងការរៀបចំនេះ គឺរៀបចំឡើងដោយបុគ្គលិកខ្មែរ ហើយការទៅប្រមូលអីនេះហាក់ដូចជាមានការសហការគ្នា ដោយសារនៅក្នុងរយៈពេលនោះខ្ញុំគិតថាមានភាពអសន្តិសុខ ស្រុករបស់យើង អ៊ីចឹងហើយមានការធ្វើការរួមគ្នារវាងវៀតណាម និងបុគ្គលិកកម្ពុជាជាមួយគ្នា។ អ៊ីចឹងខ្ញុំមានការសង្ស័យៗ ថាតើមកពីកន្លែងណា? អ៊ីចឹងខ្ញុំបានសួរៗដើម្បីបញ្ជាក់ថា អ្នកណាជាមនុស្សទីមួយដែលបានឃើញ។ ហើយគេបានប្រាប់ឈ្មោះមកខ្ញុំ ហើយខ្ញុំបានទៅតាមរកគាត់បាទ តែរកមិនឃើញ។ ហើយក្រោយមកយើងបានដំណឹងថា គាត់សម្លាប់បាត់ទៅហើយ។

[១០:០៧:៤១]

**ស៖** សូមអរគុណ។ លោកបានបញ្ជាក់ថា លោកមិនដឹងថាមានប៉ុន្មានឆ្នាំទេ ដែលវៀតណាមកាន់កាប់ឯកសារទាំងស្រុងលើៗឯកសារដែលមាននៅក្នុងភ្នំពេញ ក៏ប៉ុន្តែយើងពិចារណាមើលថា ដោយការកាន់កាប់នូវឯកសាររបស់កម្ពុជាប្រជាធិបតេយ្យដោយវៀតណាមនោះ តើលោកគាត់ទេ ថាអាចទៅរួចទេ ដែលថាមន្ត្រីវៀតណាមអាចបំផ្លាញ ឬក៏អាចដកចេញនូវភស្តុតាងមួយចំនួន ឯកសារមួយចំនួនដែលអាចឆ្លើយដាក់ ឬក៏បញ្ជាក់ពីអំពើឃោរឃៅរបស់វៀតណាមលើកម្ពុជានោះ?

**លោក អាប់ឌុលឡាក់ ថាវីក៖**

តុលាការយើងខ្ញុំ សូមជំទាស់នូវសំណួរនេះ ដោយហេតុថាមេធាវីបានសួរទៅសាក្សីដែលហួសពីសមត្ថភាពសាក្សីដែលត្រូវបំភ្លឺតុលាការបាទ។

[១០:០៨:៤៤]

**ប្រធានអង្គជំនុំ៖**

ជំទាស់មានប្រសិទ្ធភាព ហើយសាក្សីមិនបាច់ឆ្លើយតបនឹងសំណួរនេះទេ។

**សួរដោយលោក ហ្សាស្តេ ប៉ោ៖**

**ស៖** សូមអរគុណលោកប្រធាន។ ខ្ញុំសូមអនុញ្ញាតបន្តទៅទៀត ហើយខ្ញុំនឹងនិយាយបន្តិចអំពីការជំនុំជម្រះនៅឆ្នាំ១៩៧៩ ដែលកាត់ទោស ប៉ុល ពត និង អៀង សារី ថាតើពិតដែរឬទេ តាមអ្វីដែលលោកបានដឹងថា ឯកសារជាច្រើនត្រូវបានប្រមូលនៅមន្ទីរស-២១ ដើម្បីរៀបចំ ហើយនិងត្រៀមដើម្បីការជំនុំជម្រះនៅក្នុងឆ្នាំ១៩៧៩នោះ?

**លោក ឆាំង យុះ**

**ឆ៖** ខ្ញុំបានតាមរកឯកសារនេះបាទ។ ទីបំផុតខ្ញុំបានដឹងថា ឯកសារនេះត្រូវបានបញ្ជូនចេញពីអតីតក្រសួងព័ត៌មានវប្បធម៌ដែលមានលោក កែវ ចិន្តា ជាប្រធាន បញ្ជូនមកទុកនៅបណ្ណសារស្ថានជាតិ។ អ៊ីចឹងខ្ញុំបានទៅបណ្ណសារស្ថានជាតិ ហើយឃើញមានដូចជា៤០ប្រអប់ អ៊ីចឹងខ្ញុំបានមើលគ្រប់ប្រអប់ទាំងអស់នៅក្នុងឯកសារហ្នឹង ហើយសព្វថ្ងៃមាននៅកន្លែងហ្នឹងដដែល។ អ៊ីចឹងនៅក្នុងឯកសារនេះគឺមានឯកសារផ្សេងៗទៀត មានជាដីកា មានជាចម្លើយសារភាពអីផ្សេងៗ ហើយមានបោះជាសៀវភៅមួយផងបាទ។ មានបោះជាសៀវភៅមួយនិយាយអំពីតុលាការបដិវត្តន៍ប្រជាជនកម្ពុជា ហើយសៀវភៅនេះគឺក្មួយស្រីខ្ញុំម្នាក់ឈ្មោះ ម៉ូនិក បានយកមកឲ្យខ្ញុំ ពេលខ្ញុំមកដល់ស្រុកខ្មែរដំបូង ព្រោះឮសួរថាពូ ហៅខ្ញុំជាពូ ដែលរករឿងឯកសារខ្មែរក្រហម ខំយកសៀវភៅហ្នឹងមកឲ្យខ្ញុំ។ សៀវភៅហ្នឹងលោកអាចរកបាននៅក្នុងទីផ្សារក៏បាន ហើយមានជាភាសាអង់គ្លេស ដែលធ្វើឡើងដោយលោក ឃ្វីនលី-- ចនឃ្វីនលី ហើយបោះជាភាសាដែលវិភាគអំពីឯកសារទាំងអស់ដែលប្រើប្រាស់នៅក្នុងតុលាការនេះទៀតផង។ ខ្ញុំមានសៀវភៅហ្នឹង បើសិនជាលោកត្រូវការ នៅមជ្ឈមណ្ឌលឯកសារកម្ពុជាបាទ។

[១០:១០:៣៩]

**ស៖** លោកមិនឆ្លើយសំណួរខ្ញុំនោះទេ ក៏ប៉ុន្តែខ្ញុំនឹងសួរឡើងវិញ ដែលថាឲ្យមានន័យទូលាយ។ តើលោកបានដឹងឬទេ អំពីរបៀបដែលគេប្រើឯកសារហ្នឹងសម្រាប់ការជំនុំជម្រះឆ្នាំ៧៩នោះ គេប្រមូលដោយវិធីណា? ថាតើឯកសារហ្នឹងដោយវៀតណាម ដែរឬទេ?

**ឆ៖** ខ្ញុំមិនបានដឹងទេ ពីព្រោះពេលខ្ញុំអត់នៅស្រុកខ្មែរទេ បាទ ខ្ញុំចេញទៅហើយ។

**ស៖** នៅឆ្នាំ១៩៧៩ ការជំនុំជម្រះនោះ គឺថាគេចាត់ទុកថាជាការជំនុំជម្រះគួរឲ្យខ្មាសអៀនដោយថាគេបានសន្និដ្ឋានពីពិរុទ្ធភាពជនជាប់ចោទជាមុន ហើយគេបង្ហាញតែភស្តុតាងដែលដាក់ពិរុទ្ធភាពតែប៉ុណ្ណោះ គឺមិនបានប្រើភស្តុតាងដោះបន្ទុកនោះទេ។ ហើយការរៀបចំសាលាក្តីនោះ គឺថាអាចនឹងដោយក្រុមជនដែលមិនមានអព្យាក្រឹត។

**លោក អាប់ឌុលឡាក់ ថារីក៖**

គឺយើងខ្ញុំសូមជំទាស់ទៅនឹងសំណួរនេះ ដោយហេតុថា មេធាវីបានសួរទៅឲ្យសាក្សីធ្វើការសន្និដ្ឋាន ហើយអាចនឹងប្រាសចាកពីអង្គហេតុនេះ បាទ។

[១០:១១:៥៧]

**លោក ហ្សាស្ទើ ប៉ោ៖**

ខ្ញុំសូមបញ្ជាក់ឲ្យច្បាស់ថា ហើយសុំឲ្យតុលាការបញ្ជាក់ប្រាប់ខ្ញុំ ហើយខ្ញុំចង់ នៅទទួចសួរដើម្បីថាជាពិសេសគឺយើងអាចនឹងចង់បញ្ជាក់ថា ការជំនុំជម្រះឆ្នាំ១៩៧៩ នោះ គេចាត់ទុកថាជាការជំនុំជម្រះដែលមិនយុត្តិធម៌នោះទេ ហើយព្រះរាជអាជ្ញាក៏មិនអាចបញ្ជាក់ថា ខ្ញុំមិនអាចនិយាយពីរឿងហ្នឹងនេះបាន ប៉ុន្តែខ្ញុំនឹងស្តាប់បង្គាប់របស់អង្គជំនុំជម្រះសាលាដំបូង ប្រសិនបើមានការណែនាំទៅតាមអ្វីដែលនីតិវិធីអនុញ្ញាតនោះបាទ។

**ប្រធានអង្គជំនុំ៖**

ជំទាស់មានប្រសិទ្ធភាព។ សាក្សីមិនចាំបាច់ឆ្លើយនឹងសំណួរនេះទេ។ មេធាវីមិនអាចសំណួរតាំងសំណួរឯណា សំដៅគោលបំណងឲ្យសាក្សីបញ្ចេញនូវគំនិតយោបល់ធ្វើសេចក្តីសន្និដ្ឋាន ឬមតិផ្ទាល់ខ្លួនលើបញ្ហាអ្វីមួយបានឡើយ។ បញ្ហានេះយើងបានធ្វើការសម្រេចច្រើនលើកច្រើនសារួចហើយ។ យើងសង្ឃឹមថាមេធាវីប្រកបដោយវិជ្ជាជីវៈខ្ពស់ដូចនេះ ទំនងជាមិនបន្តតាំងសំណួរប្រភេទនេះតទៅទៀតទេនៅក្នុងអំឡុងពេលដេញដោល ពិភាក្សាដេញដោលសំណុំរឿងនេះ ពីពេលនេះតទៅរហូតដល់ចប់នោះ។

**លោក ហ្សាស្ទើ ប៉ោ៖**

សូមអរគុណលោកប្រធាន ខ្ញុំនឹងព្យាយាមគោរពទៅតាមការសម្រេចនេះ។

**សួរដោយលោក ហ្សាស្ទើ ប៉ោ៖**

**ស៖** លោក ឆាំង យុ តាមអ្វីដែលលោកដឹង តើពិតដែរឬទេ ហេឡែន ចាវីស បានទៅវៀត-ណាម ដើម្បីរកឯកសារមួយចំនួនដែលយើងសង្ស័យថា ត្រូវបានគេយកចេញទៅពីស្រុកខ្មែរ ដោយវៀតណាមក្រោយពីពួកគេបានឈ្លានពានទឹកដីកម្ពុជាមកនោះ?

**ឆ៖** ខ្ញុំអាចឆ្លើយជំនួសគាត់បាន បើសិនជាលោកចៅក្រមអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

សំណួរតែ គ្រាន់តែសួរថាដឹងឬអត់ប៉ុណ្ណោះ។ ការងាររបស់គាត់ របស់អ្នកណាអ្នកនុំងជាអ្នកឆ្លើយ មិនមានសាក្សីឆ្លើយនឹងគេទេ។ បញ្ហាសំណួរគ្រាន់តែសួរថាដឹងឬអត់ តែប៉ុណ្ណោះ។

[១០:១៤:២៤]

**លោក ឆាំង យុ៖**

**ឆ៖** សូមអរគុណលោកប្រធាន។ បាទ ខ្ញុំដឹងថាគាត់ធ្លាប់បានទៅ។

**សួរដោយលោក ហ្សាស្ដើ ប៉ៅ៖**

**ស៖** ថាតើលទ្ធផលនៃការងារហ្នឹង បេសកកម្មហ្នឹងមានលទ្ធផលអ្វី? តើគាត់ត្រឡប់មកវិញមាន-- គាត់បានយកឯកសារអ្វីខ្លះមកទេ? បើមានៗឯកសារអ្វីខ្លះ?

**ឆ៖** ខ្ញុំមិនសូវរំពឹងអំពីសមត្ថភាពរបស់គាត់ក្នុងស្រាវជ្រាវឯកសារទេ។ បាទ និយាយតាមត្រង់។ ខ្ញុំនឹងគាត់មិនសូវត្រូវគ្នាទេ។ ជាមិត្តជាភក្តិមែន ប៉ុន្តែខ្ញុំមិនសូវត្រូវ អំមិនសូវត្រូវគ្នាជាមួយគាត់ ហើយគាត់ជាទូទៅ គាត់មានគំនិតមួយផ្សេងខុសពីខ្ញុំ។ អ៊ីចឹង តាមដែលខ្ញុំចាំ គាត់ដូចជាធ្លាប់យកឯកសារបោះពុម្ពមួយចំនួនមកដែរជាភាសាវៀតណាម បាទ តាមដែលខ្ញុំចាំ។

**ស៖** ហើយខ្ញុំគ្រាន់តែសួរថា តើលោកផ្ទាល់លោកដឹងដែរឬទេ ថាតើគាត់បានប្រមូលឯកសារមួយចំនួនោះ នៅក្នុងប្រទេសវៀតណាមបាទ?

**ឆ៖** ខ្ញុំដឹងថាគាត់ទៅ ប៉ុន្តែត្រង់ថាគាត់ប្រមូលបានប៉ុនណា ខ្ញុំអត់ដឹងទេបាទ។

**ស៖** ថាតើគាត់ទៅបេសកកម្មហ្នឹងក្នុងកិច្ចការរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែរឬទេ តាមអ្វីដែលលោកដឹង? ឬក៏គាត់ទៅជាក្រៅផ្លូវការរបស់គាត់ទេ?

**ឆ៖** អ្នកស្រី ហេឡែន មានកិច្ចការច្រើន មានតួនាទីច្រើន។ បាទ មូលហេតុហ្នឹងហើយដែលខ្ញុំនិងគាត់មិនសូវត្រូវគ្នា។ ហើយជាទូទៅគាត់មានចិត្តថ្លើមស្រឡាញ់ការងាររបស់កន្លែងយើង ហើយលោកសាស្ត្រាចារ្យ ប៊ែន ឃៀរនិន បានជួលគាត់ធ្វើជាទីប្រឹក្សារៀបចំ*ម៉ានញូល* ដែលលោកបានឃើញឈ្មោះគាត់ និង នេឡា ក្រូស។ នេះគឺជាតួនាទីរបស់គាត់ ប៉ុន្តែគាត់មានចិត្ត មានថ្លើម គាត់ទៅកន្លែងណាឲ្យតែឃើញឯកសារ គាត់ជួយយកមកឲ្យខ្ញុំ ឬក៏គាត់ជួយប្រាប់អ៊ីចឹង ប្រាប់យកមកឲ្យខ្ញុំអ៊ីចឹង។ ប៉ុន្តែគាត់មានតួនាទីត្រឹមតែជា*ខន់សាល់ថិន* ទេ។ ជា*ខន់សាល់ថិន* របស់ ស៊ី.ដី.ភី គឺឲ្យគាត់មកធ្វើដេតាបេសបង្រៀនបុគ្គលិកឲ្យចេះធ្វើ*ដេតាអ៊ិនទ្រី*។ បាទនេះគឺជាដែនកំណត់តួនាទីរបស់គាត់។ ប៉ុន្តែគាត់ធ្វើការច្រើនណាស់។ គាត់ធ្វើការច្រើន គាត់សរសេរផង គាត់ដើររកផង គាត់ហូបកាហ្វេផង គាត់ទៅវៀត-ណាមផង គាត់ទៅណាណើផង ឲ្យតែទាក់ទងរឿងហ្នឹងគឺគាត់ប្រាប់មកខ្ញុំបាទ។ អ៊ីចឹងអាចថា គាត់ទៅហ្នឹងមិនមែនជាក្នុងនាមរបស់យើង ឬក៏គាត់ប្រើប្រាស់ជានាមរបស់យើង។ ប៉ុន្តែនៅក្នុងគោលការណ៍រចនាសម្ព័ន្ធរបស់យើង គាត់ជា*ខន់សាល់ថិន*។ បាទ ជាទីប្រឹក្សាផ្នែកគន្ថនិទ្ទេស ផ្នែកកាតាឡុកឯកសារ។

[១០:១៧:១៤]

**ស៖** តាមអ្វីដែលលោកដឹង ថាតើគាត់ទៅម្ដង ឬក៏ទៅច្រើនដងទៅវៀតណាមនោះបាទ? បាទគឺ

ដើម្បីទៅប្រមូលឯកសារក្នុងសម័យកម្ពុជាប្រជាធិបតេយ្យបាទ?

**ឆ៖** រឿងទៅប្រមូលខ្ញុំមិនដឹងទេ តែខ្ញុំដឹងថាគាត់ទៅច្រើនដងបាទ។ មិនដឹងជាគាត់ទៅធ្វើស្អីផ្សេងទៀតពីហ្នឹងក៏ខ្ញុំមិនដឹងដែរ។

**សៈ** តើលោកធ្លាប់សួរគាត់ទេ ថាតើគាត់បានរកឃើញឯកសារកម្ពុជាប្រជាធិបតេយ្យអ្វីមកពីប្រទេសវៀតណាមដែរឬទេ?

**ឆ៖** គាត់ មិនបាច់សួរ គាត់ប្រាប់តែម្តងបាទ។ គាត់មកគាត់ថា គាត់បាននេះ បាននោះអីអ៊ីចឹងបាទ គាត់ធ្លាប់ប្រាប់ខ្ញុំ។

[១០:១៨:១៨]

**សៈ** តើលោកប្រាប់ខ្ញុំបានទេ ប្រភេទឯកសារអ្វីខ្លះដែលគាត់បានប្រមូលយកមកពីវៀតណាមវិញនោះ?

**ឆ៖** ខ្ញុំគិតថា ដូចជាឯកសាររបៀបបោះពុម្ព របៀបជាសៀវភៅជាអីអ៊ីចឹងបាទ។ ខ្ញុំគិតថាសៀវភៅហ្នឹងក៏ខ្ញុំនៅមានបណ្ណាល័យខ្ញុំដែរ បាទគាត់យកមកឲ្យខ្ញុំ។

**សៈ** តើគាត់យកមកតែឯកសារបោះពុម្ព ដូចជាសៀវភៅ ឬក៏យកមកវិញនូវឯកសារប្រភេទផ្សេងជាឯកសារភស្តុតាងនោះបាទ?

**ឆ៖** និយាយឲ្យខ្លីទៅ អត់មានជាឯកសារភាសាខ្មែររបស់របបកម្ពុជាប្រជាធិបតេយ្យ គាត់យកមកឲ្យខ្ញុំទេ មានតែឯកសារជាភាសាវៀតណាម ជាឯកសារបោះពុម្ព ឬក៏ដូចជាខិត្តប័ត្រៗ។ តាមដែលខ្ញុំចាំ មានដូចជាខិត្តប័ត្រមួយនិយាយអំពីការដែលកម្ពុជាប្រជាធិបតេយ្យវាយលុកទៅវៀតណាម។ នេះជាខិត្តប័ត្រមួយ ជារបៀបជា*ប្រូស្វ* ប៉ុន្តែឯកសារកម្ពុជាប្រជាធិបតេយ្យជាភាសាខ្មែរគាត់មិនដែលរកឃើញ ឬក៏រកបាន ឬក៏ឲ្យខ្ញុំមួយសន្លឹកទាល់តែសោះ។

**សៈ** បាទ សូមអរគុណលោកឆាំង យុ ខ្ញុំនឹងសួរបន្តនៅដំណាក់កាលក្រោយទៀត។ ឥឡូវនេះខ្ញុំចូលទៅដល់ចំណុចមួយដែលលោកបញ្ជាក់ថា ពីពេលមួយទៅពេលមួយ គេបានយកឯកសារកំណត់ត្រាមកឲ្យ ឌី.ស៊ី.ខេម ជាមពិសេសតាំងពីដំណើរការនីតិវិធី ហើយនិងសេចក្តីដកស្រង់នៃឯកសារកម្ពុជាប្រជាធិបតេយ្យ ហើយនិងចម្លើយរបស់សាក្សីផងដែរនៅក្នុងការជំនុំជម្រះឆ្នាំ១៩៧៩នោះ។ តើលោកដឹងទេថា តើអ្នកណាជាអ្នកមានឯកសារនេះភ្លាមៗ ក្រោយពីដំណើរការនីតិវិធីឆ្នាំ១៩៧៩ ចប់មកនោះ?

**ឆ៖** ខ្ញុំថាលោកមេធាវីច្រឡំបន្តិច។ ខ្ញុំចង់និយាយថា ពេលដែលខ្ញុំចាប់ផ្ដើមកិច្ចការនេះដំបូង ឆ្នាំ៩៥ ខ្ញុំមានក្មួយស្រីម្នាក់ ហើយបងស្រីខ្ញុំដែលធ្លាប់រស់នៅសម័យខ្មែរក្រហមនៅទីក្រុងភ្នំពេញ។ ហើយក្មួយខ្ញុំហ្នឹង វាអាយុប្រហែលជាប្រាំបួនដណ្ដប់ ឬម្ភៃឆ្នាំទេ។ វាឮសួរថាពូវារករៀបចំឯកសាររឿងខ្មែរក្រហមហ្នឹង ក៏យកអាសៀវភៅកាត់ទោសនេះ សំណុំរឿងកាត់ទោសយកមកឲ្យខ្ញុំ។ ក្មួយខ្ញុំឈ្មោះ ម៉ុយនិក វាយកមកឲ្យ។

[១០:២០:៥៩]

ក្រៅពីហ្នឹង ខ្ញុំគិតថា អត់មានអ្នកណាមួយមានឯក-- ខ្ញុំតាមរកដែរថា តើអ្នកណាមានឯកសារនេះចេញមកពីតុលាការ៧៩។ មូលហេតុហ្នឹងហើយបានខ្ញុំតាមស្រាវជ្រាវរក ហើយទីបំផុត ខ្ញុំឃើញ រកឃើញនៅក្នុងបណ្ណសារដ្ឋានជាតិ។ ហើយអ្នកស្រី លឹម គី គាត់បានប្រាប់ខ្ញុំ បើខ្ញុំត្រូវការមើល ក៏មើលទៅ។ ខ្ញុំធ្លាប់បាននាំជំនាញការអង្គការសហប្រជាជាតិ ឆ្នាំ៩៨ ទៅមើលឯកសារខ្លួនឯង។ លោកមើលខ្លួនឯងទៅ នេះគឺជាប្រភេទឯកសារ៧៩ លោកយល់ថាយ៉ាងណា ក៏ពិចារណាខ្លួនឯងទៅ។

អ៊ីចឹងឯកសារទាំងអស់ តាមដែលខ្ញុំចាំ បន្ទាប់ពីមានការកាត់ទោសហើយ គឺត្រូវបានប្រមូលយកទៅទុកនៅនាយកដ្ឋាន ផ្សព្វផ្សាយព័ត៌មាននិងឃោសនាការ ក្រោមការគ្រប់គ្រងរបស់លោក កែវ ចិន្ដា ដែលក្រោយមកត្រូវបញ្ជូនមកបណ្ណសារដ្ឋានជាតិទាំងស្រុង។ ហើយឯកសារទាំងអស់នេះ គឺមាននៅដដែលកន្លែងហ្នឹង។ អ៊ីចឹងអត់មានអ្នកណាម្នាក់យកឯកសារសម័យនោះយកមកឲ្យខ្ញុំទេ ក្រៅពីក្មួយស្រីរបស់ខ្ញុំគឺសៀវភៅ ហើយសៀវភៅនេះ លោកអាចរកបានផ្សារថ្មី គឺមានលក់ មានជាភាសាបារាំង ជាភាសាខ្មែរ និងជាភាសាអង់គ្លេស។

[១០:២២:១៤]

**ស៖** ខ្ញុំចង់ឲ្យលោកបញ្ជាក់ឲ្យច្បាស់ ខ្ញុំដូចជាមិនយល់ច្បាស់នូវចម្លើយរបស់លោកសោះ។ តើលោកប្រាប់ខ្ញុំថា ក្មួយបានឲ្យឯកសារមកលោកអំពីការជំនុំជម្រះក្ដីនៅឆ្នាំ១៩៧៩ គឺមានតែក្មួយរបស់លោកទេ មិនមែនអ្នកផ្សេងទេឬ?

**ឆ៖** បាទ ក្មួយខ្ញុំឲ្យសៀវភៅ បាទ សៀវភៅហ្នឹង គេចងក្រងស្ដីអំពីការកាត់ទោស សៀវភៅដាក់លក់ពេញផ្សារក៏មាន។ សព្វថ្ងៃ តាមដែលខ្ញុំចាំ មានប្រហែលជា១០០ក្បាលទៀតនៅបណ្ណសារដ្ឋានជាតិ។ ហើយសៀវភៅនេះ មានជាភាសាបារាំង ជាភាសាខ្មែរ។ គ្មាននរណាមួយដែលយកឯកសារចេញពីតុលាការយកមកឲ្យខ្ញុំទេ ក្រោយពេលដែលខ្ញុំបានទៅរកនៅទីនោះខ្លួនឯង។ ខ្ញុំបានទៅរក ទៅ

តាមរកខ្លួនឯង។ ខ្ញុំចង់ដឹងថាមានព័ត៌មានអីខ្លះ ហើយឯកសារទាំងអស់ហ្នឹង គឺទុកនៅបណ្ណសារដ្ឋានជាតិទាំងស្រុងសព្វថ្ងៃនេះ បាទ។

[១០:២៣:២១]

**សៈ** លោក ឆាំង យុ លោកជាអ្នកនិពន្ធរួមនូវអត្ថបទសារព័ត៌មានមួយ ដូចដែលលោកបញ្ជាក់នៅក្នុងសក្ខីកម្មច្រើនកន្លែងដែលហៅថាអត្ថបទ មាននិយាយថា ការចងក្រងឯកសារបទឧក្រិដ្ឋកម្មប្រជាធិបតេយ្យ។ លោកបានសរសេររួមជាមួយ ចន ឆរឈីអារី តើពិតដែរឬទេ លោកជាអ្នកនិពន្ធរួមនូវអត្ថបទសារព័ត៌មាននេះ?

**ឆៈ** ជាការពិត បើសិនជាលោកមើលទៅក្នុងអ្នកនិពន្ធ គឺប្រើពាក្យ *វីតស៍* (with) បានន័យថាខ្ញុំមានជាអ្នកនិពន្ធតូចមួយ មិនមែនស្មើភាពជាមួយលោក ចន ឆរឈីអារី ទេ។ បើសិនជាលោកប្រើពាក្យថា ចន ឆរឈីអារី *អេន* យុ ឆាំង អាហ្នឹងបានយើងមានជាអ្នកនិពន្ធស្មើគ្នា។ អ៊ីចឹងនៅក្នុងនេះយើងប្រើពាក្យ វីតស៍។ បានន័យថាខ្ញុំគ្រាន់តែប្រាប់លោក ចន ថាមានស្អីខ្លះ ហើយគាត់ជាអ្នកសរសេរទាំងស្រុង។ នៅក្នុង *ស្កូឡាស៊ីប* យើងលុប-- លោកយល់ថា "វីតស៍" ហ្នឹងមានន័យថាយ៉ាងម៉េច? ពាក្យ "អេន" មានន័យថាយ៉ាងម៉េច បាទ។

**សៈ** ខ្ញុំសូមអនុញ្ញាតបន្តទៅទៀត ដោយខ្ញុំមើលនាឡិកាទៅដូចកៀកម៉ោងហើយ។ សំណួររបស់ខ្ញុំមិនបង្ហាញនូវទំព័រជាក់លាក់នោះទេ ប៉ុន្តែខ្ញុំគ្រាន់តែអាននូវទំព័រ២៣១ នៃអត្ថបទសារព័ត៌មាននេះនៅទំព័រនេះ លោកបាននិយាយថា"ជាគោលការណ៍ ដោយសារមានការខ្វះខាតនៅក្នុងឯកសារតុលាការឆ្នាំ១៩៧៩ គឺដោយហេតុថាមានការលម្អៀងខាងនយោបាយ"។ តើលោកអាចពន្យល់បានទេ តើលោកមានន័យថាម៉េចនៅពេលដែលលោកនិយាយសេចក្តីសង្កេតបែបនេះនោះ? គឺថាមានកង្វះនូវឯកសារសំខាន់ហ្នឹង គឺដោយសារតែមានការលម្អៀងខាងនយោបាយនៅក្នុងការជំនុំជម្រះនោះ?

**ឆៈ** ខ្ញុំមិនចង់ទាមទារមើលអត្ថបទហ្នឹងទេ ប៉ុន្តែទីមួយសូមជម្រាបថា នេះមិនមែនជាអត្ថបទកាសែត គឺជាអត្ថបទមួយនៅក្នុងសៀវភៅដែលនិពន្ធឡើងដោយអ្នកច្បាប់ពីរូបគឺអ្នកស្រី អេលីហ្សាបេត វ៉ានស្កាក់ និងអ្នកស្រី ចាយ៉ា រ៉ាមជី គឺជា*ឆាបទ័រ*មួយនៅក្នុងសៀវភៅមួយគឺជាឯកសារជាសាធារណៈ។ ហើយខ្ញុំបានឱ្យមកសហព្រះរាជអាជ្ញា បានផ្សព្វផ្សាយជាទូទៅ ពីព្រោះចេះតែមានសំណួរចោទសួរ។

[១០:២៥:៥៣]

ទីពីរទៀត យើងដឹងថានៅពេលដែលក្រោយពេល ខ្ញុំធ្លាប់ធ្វើការនៅអង្គការសហប្រជាជាតិជាអ្នករៀបចំការបោះឆ្នោតនៅស្រុកខ្មែរយើងឆ្នាំ៩២ ឆ្នាំ៩៣។ ពេលដែលខ្ញុំមកដល់ ខ្ញុំដឹងថាឯកសារជាច្រើនត្រូវបានបំផ្លាញចោល ហើយពេលដែខ្ញុំតាមរកឯកសារទាំងអស់នេះ ឧទាហរណ៍ដូចនៅខេត្តស្ទឹងត្រែងមានឯកសារមួយចំនួនត្រូវបានពន្លិចទៅក្នុងទឹកទន្លេមេគង្គទៀតផង។ អ៊ីចឹង ឯកសារជាច្រើនត្រូវបានបំផ្លាញ ហើយឯកសារមួយចំនួនទៀត នៅមុនពេលដែលរបបកម្ពុជាប្រជធិបតេយ្យបានដួលរលំទៅនេះគឺបានបំផ្លាញឯកសារខ្លួនឯងទៀត។ អ៊ីចឹងឯកសារជាច្រើនត្រូវបានខ្ចាត់ខ្ចាយ បែកខ្ញែក ឬក៏ដុតចោល ឬក៏បំផ្លាញ។ ហើយខ្ញុំគិតថាទាំងអស់នេះ គឺជាហេតុផលនយោបាយ ពីព្រោះម្នាក់ៗមានការព្រួយបារម្ភថា ហេតុអីបានជាមនុស្សពីរលាននាក់ស្លាប់បាត់បង់ជីវិត? អ៊ីចឹងម្នាក់ៗព្យាយាមបំផ្លាញឯកសាររៀងៗខ្លួន ហើយខ្ញុំបានតាមរកឯកសារ ហើយយើងខ្ញុំបានរកឃើញថាមានឯកសារខ្លះត្រូវបានដុតចោលមុនពេលដែលអង្គការសហប្រជាជាតិបានចូលមកក៏មាន។ មានឯកសារខ្លះទៀត ត្រូវបានដុតចោលមុនពេលរបបកម្ពុជាប្រជាធិបតេយ្យរត់ទៅទល់ដែនថៃក៏មាន។ មានឯកសារខ្លះទៀត ទើសកន្លែងទើសអ៊ីចឹងគឺថាប្រជាជននៅខេត្តស្ទឹងត្រែង គាត់ពន្លិចចូលទៅក្នុងទឹកទន្លេមេគង្គ វាចង្អៀតកន្លែងក៏មានដែរ។ អ៊ីចឹងឯកសារជាច្រើនដែលបានបាត់បង់ ហើយម្លោះហើយខ្ញុំសុំតាមរកមកវិញ ហើយបើសិនជាលោកអនុញ្ញាត ខ្ញុំតែងតែគិតថា ឯកសារមួយស្មើនឹងដុំថ្មអង្គរវត្តមួយដុំ។ ខ្ញុំចង់បានមកវិញ ទៅកន្លែងណាក៏ខ្ញុំតាមរកដែរ។ អ៊ីចឹងឯកសារចំពោះខ្ញុំគឺមានតម្លៃណាស់។ យើងខ្ញុំដឹងរឿងរ៉ាវទាំងអស់នេះ មិនមែនតែមានក្រុមមួយ បក្សមួយទេ គឺគ្រប់គ្នាបានបំផ្លាញឯកសារ។ ជាឯកសាររបស់ជាតិ ឯកសាររបស់ប្រជាជន កម្មករ កសិករ ដែលរស់នៅវេទនា។ យើងចង់ដឹងថាហេតុអីបានជារបបនេះកើតឡើង? ប៉ុន្តែយើងបានបំផ្លាញឯកសារ អ៊ីចឹងបានន័យថា អ្នកដែលបានបំផ្លាញឯកសារនេះ គឺមានហេតុផលនយោបាយ។ ខ្ញុំគិតអ៊ីចឹង ដូចខ្ញុំជម្រាបលោកអ៊ីចឹង។

[១០:២៧:៣២]

អត្ថបទនេះ គឺសរសេរឡើងជាមួយលោក ចន ឆរឈីអារី អ៊ីចឹងនៅក្នុងន័យជាភាសាអង់គ្លេសដែលនៅក្នុង *ស្តូឡាស៊ីប* ខ្ញុំមិនមែនជាអ្នកនិពន្ធស្មើនឹងគាត់ទេ ព្រោះយើងប្រើពាក្យ "វីតស៍" បានន័យថាគាត់សម្ភាសខ្ញុំ សួរខ្ញុំ ហើយសេចក្តីសន្និដ្ឋានរបស់គាត់ ខ្ញុំឯកភាពជាមួយគាត់ដែរ។ ប៉ុន្តែសំណេរទាំងអស់គឺគាត់ជាអ្នកសរសេរ។ ខ្ញុំអត់បានសរសេរសូម្បីតែមួយពាក្យ ប៉ុន្តែខ្ញុំជាអ្នកផ្តល់ព័ត៌មានទៅជូនគាត់ដើម្បីសរសេរអត្ថបទនេះ ហើយសូមបញ្ជាក់ថា មិនមែនអត្ថបទកាសែតទេ គឺជាអត្ថបទ *ស្តូឡាស៊ីប* គឺ

មានតម្លៃជាស្លូឡាស៊ីប នៅក្នុងសៀវភៅមួយដែលមានចំណងជើងថា៖ “នាំអ្នកដែលទទួលខុសត្រូវអំពីការ បទឧក្រិដ្ឋធ្ងន់ធ្ងរមកធ្វើការវិនិច្ឆ័យទោស” គឺនិពន្ធឡើងដោយលោកស្រី អេលីហ្សាបេត វ៉ាន់ស្ពាក់ និង អ្នកស្រី ចាយ៉ា វ៉ាមជី។

[១០:២៨:២០]

**ស៖** តើលោកយល់ស្របជាមួយទៅនឹងខ្លឹមសារនៃអត្ថបទនៃសៀវភៅនេះដែលលោកបាននិយាយខាងដើមនេះដែរឬទេ?

**ឆ៖** ដូចខ្ញុំជម្រាបលោកអ៊ីចឹង គឺខ្ញុំឯកសារភាព ហើយប៉ុន្តែអ្នកដែលសរសេរច្រើនគឺលោក ចន ហើយខ្ញុំជាអ្នកផ្ដល់ព័ត៌មាន។

**ស៖** តើពិតដែរឬទេ លោកបានចូលរួមក្នុងការសរសេរអត្ថបទនេះ ប្រហែលជាពីរ ឬបីសប្ដាហ៍កន្លងទៅនេះ គឺថានៅក្នុងសប្ដាហ៍ដែលលោក ដាវ៉ា បានមកផ្ដល់សក្ខីកម្មនេះ តើលោកបានចូលរួមបែបនោះទេ?

**ឆ៖** បាទ អត្ថបទនេះសរសេរតាំងពី២០០៤ នោះបាទ យូរណាស់ហើយ។ ខ្ញុំដឹងថាហេតុអីបានជាអ្នកស៊ើបអង្កេតអីហាក់ដូចជាភ្ញាក់ផ្អើល អត្ថបទនេះបោះតាំងពីឆ្នាំ២០០៤-២០០៥។ យូរតាំងពីមុនតុលាការកើតទៅទៀត យូរមកហើយ។ ហើយសៀវភៅនេះ គឺខ្ញុំធ្លាប់បានឲ្យខាងសហព្រះរាជអាជ្ញាទិញយកខ្លួនឯង ហើយខាងព្រះរាជអាជ្ញាថាគ្មានលុយទេ។ អ៊ីចឹង ខ្ញុំក៏ហ្វូតូកូពីឲ្យទៅ ព្រោះខ្ញុំជាម្ចាស់ចំណែកនៅក្នុង *ឆាបទ័រ* ហ្នឹងដែរ។ ខ្ញុំថាទិញសៀវភៅខ្លួនឯង មើលខ្លួនឯងទៅ។ ហើយខាង-- មីសែលលី ថាគ្មានលុយទេ។ អ៊ីចឹងខ្ញុំក៏កូពីឲ្យទៅ សៀវភៅនេះសរសេរយូរហើយ តាំងពី២០០៤ (និយាយជាភាសាអង់គ្លេស៖) *ឡុងថាមអ៊ីហ្គោ*។

[១០:២៩:៥៣]

**ស៖** មេធាវី សូមអរគុណលោក ឆាំង យុ។ ខ្ញុំមិនភ្ញាក់ផ្អើលទៅនឹងអត្ថបទនោះទេ ប៉ុន្តែសំណួររបស់ខ្ញុំថាតើលោកនៅតែចូលរួមក្នុងការសរសេរ ហើយបញ្ជូនទៅប្រភពណាមួយទៅតាមអ៊ីម៉ែល ដើម្បីឲ្យគេចុះផ្សាយបែបនេះទេក្នុងរយៈពេលប៉ុន្មានខែ ឬប៉ុន្មានអាទិត្យៗចុងក្រោយនេះនោះ?

**ឆ៖** ខ្ញុំផ្ញើអ៊ីម៉ែលសឹងចេញតែរាល់ថ្ងៃ បើសិនអ្នកណានៅក្នុង*ម៉ែលលីងលីស*របស់ខ្ញុំ លោកកាណាវាស ក៏មាន លោក អាង ឧត្ដម ក៏មាន ផេសមិន ក៏មាន អេនឌ្រូ ក៏មាន។ ខ្ញុំផ្ញើរាល់ថ្ងៃដើម្បីឲ្យប្រជាជនបានដឹង ឲ្យយើងទាំងអស់គ្នាបានតាមដានសភាពការណ៍ មានឯកសារផ្សេងៗដើម្បីវិនិច្ឆ័យ

តុលាការនេះថា តើអង្គចៅក្រមទាំងអស់នេះន៎ែ មានយុត្តិធម៌ដែរឬក៏អត់ ចំពោះអ្វីដែលបានកើតឡើង?

អ៊ីចឹង ឲ្យតែមានឯកសារ ខ្ញុំចង់ផ្សព្វផ្សាយគ្រប់ពេលវេលាទាំងអស់។ ទាំងពីចម្រៀងខ្មែរក្រហមក៏មាន ទាំងពីរូបថត ទាំងពីសំណេរផ្សេងៗជាច្រើន ច្រើនណាស់ៗ។ ខ្ញុំផ្សាយនេះ ហើយអ្នកដែលទទួលអ៊ីម៉ែលរបស់ខ្ញុំ គឺមានបួនពាន់នាក់ រួមទាំងសមាជិកជាច្រើននៅក្នុងអ្នកការពារកូនក្ដីៗនៅទីនេះដែរ។

[១០:៣០:៥៨]

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី អរគុណសាក្សី ដែលបានប្រឹងប្រែងផ្ដល់សក្ខីកម្មក្នុងអំឡុងពេលមកនេះ។ ឥឡូវនេះ ដល់ពេលសមល្មមសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកត្រឹមនេះរហូតដល់ម៉ោងដប់មួយខ្វះដប់នាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយមន្ត្រីរដ្ឋបាលតុលាការសូមជួយសម្របសម្រួលផ្ដល់កន្លែងសម្រាកសមរម្យដល់សាក្សីរូបនេះ នៅក្នុងអំឡុងពេលឈប់សម្រាក និងសុំអញ្ជើញគាត់មកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះឲ្យបានមុនពេលអង្គជំនុំជម្រះចូលមកកាន់អាសនៈ។

សូមអញ្ជើញលោក អាង ឧត្ដម!

[១០:៣១:៤១]

**លោក អាង ឧត្ដម៖**

សូមអរគុណ និងសូមគោរពលោកប្រធាន! សូមគោរពលោក លោកស្រីចៅក្រម។ ដោយសារមូលហេតុសុខភាព ជាពិសេសលោក អៀង សារី លោកមានបញ្ហាឈឺចង្កេះមិនអាចទ្រាំទ្រអង្គុយនៅទីនេះបាន។ លោកបាន ស្នើសុំលះបង់សិទ្ធិមិនចូលរួមសវនាការផ្ទាល់នៅបន្ទប់សវនាការនេះសម្រាប់មួយថ្ងៃនេះពេញ ក៏ប៉ុន្តែសុំចូលរួមតាមដានសវនាការនេះនៅបន្ទប់រង់ចាំខាងក្រោម។ អាស្រ័យហេតុនេះសូមលោកប្រធានមេត្តាអនុញ្ញាត។ សូមអរគុណ។

[១០:៣២:១៥]

**ប្រធានអង្គជំនុំ៖**

បាទ បានស្ដាប់សំណើសុំរបស់ជនជាប់ចោទ អៀង សារី ហើយបានធ្វើឡើងតាមរយៈមេធាវីការពារក្ដីរបស់គាត់ស្នើសុំមិនចូលរួមតាមដានកិច្ចដំណើរការសវនាការដោយផ្ទាល់នៅបន្ទប់សវនាការនេះសម្រាប់ថ្ងៃនេះ ដោយសុំទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយតាមប្រព័ន្ធសោតទស្សន៍ដោយ

មានបញ្ហាសុខភាពមិនអាចអង្គុយតាមដានកិច្ចដំណើរការសវនាការដោយផ្ទាល់បានយូរ។ អង្គជំនុំជម្រះប្រកាសយល់ព្រមតាមសំណើសុំរបស់ជនជាប់ចោទ អៀង សារី ដែលបានស្នើសុំតាមរយៈមេធាវីរបស់គាត់ក្នុងការលះបង់សិទ្ធិមិនចូលរួមនៅក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់នៅក្នុងសវនាការនេះ ដោយទៅបន្តការតាមដាននូវកិច្ចដំណើរការសវនាការពីចម្ងាយនៅបន្ទប់មួយស្ថិតនៅក្រោយបន្ទប់សវនាការនេះ តាមរយៈប្រព័ន្ធសោតទស្សន៍។ តែអង្គជំនុំជម្រះតម្រូវឲ្យក្រុមមេធាវីការពារក្ដីលោក អៀង សារី ប្រគល់មកអង្គជំនុំជម្រះនូវលិខិតលះបង់សិទ្ធិក្នុងការចូលរួមផ្ទាល់នៅក្នុងបន្ទប់សវនាការដោយចុះហត្ថលេខា ឬផ្ដិតស្នាមម្រាមដៃយ៉ាងជាក់ច្បាស់ពីជនជាប់ចោទ អៀង សារី។

បង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សំឡេង រូបភាព សម្រាប់ជនជាប់ចោទរូបនេះតាមដានកិច្ចដំណើរសវនាការពីចម្ងាយនៅក្នុងអំឡុងពេលធ្វើសវនាការសម្រាប់ថ្ងៃនេះ។ ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ អៀង សារី ទៅកាន់បន្ទប់ខាងក្រោម ដែលបានរៀបចំទុកសម្រាប់គាត់តាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១០:៣៣ នាទី ដល់ម៉ោង ១០:៥២ នាទី)*

[១០:៥២:០៩]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើការនីតិវិធីសវនាការ។ មុននឹងប្រគល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដី នួន ជា ក្នុងការបន្តតាំងសំណួរចំពោះសាក្សី អង្គជំនុំជម្រះសូមរំឭកលោក ឆាំង យុ ថា នៅក្នុងអំឡុងពេលនៃការផ្ដល់សក្ខីកម្ម ប្រសិនបើលោកនិយាយទៅដល់ឈ្មោះជនជាប់ចោទ នោះគឺសូមលោកនិយាយឲ្យចំឈ្មោះគាត់ មិនគប្បីប្រើឈ្មោះហៅក្រៅនោះទេ ដើម្បីជាប្រតិចារឹក ដើម្បីត្រឹមត្រូវតាមនីតិវិធី ហើយក៏ដើម្បីសាធារណជនដែលគាត់តាមដានហ្នឹង គឺបានយល់ច្បាស់អំពីគោលដៅដែលលោកប្រើពាក្យក្នុងការនិយាយទៅដល់នោះ។ ឧទាហរណ៍ ខៀវ សំផន ឬក៏ នួន ជា លោក អៀង សារី ជាដើម។សូមអរគុណ។

[១០:៥៣:១៤]

សូមអង្គជំនុំជម្រះសូមផ្តល់វេទិកា ជូនទៅក្រុមមេធាវីការពារក្តី នួន ជា ដើម្បីបន្តតាំងសំណួរផ្សេងៗ ប្រសិនបើមានក្នុងការសួរដេញដោលចំពោះសាក្សី។

សូមអរញ្ជើញ!

**លោក ហ្សាស្តើ ប៉ោ៖**

សូមអរគុណលោកប្រធាន។

លោក ឆាំ យុ មុននឹងខ្ញុំសួរទៅកាន់លោក គឺថាខ្ញុំបានលើកឡើងបញ្ហានេះតាំងពីខាងដើមមក ហើយខ្ញុំក៏ក្រឡេកទៅមើលទៅនាឡិកា ដើម្បីឲ្យខ្ញុំត្រៀមរៀបចំសម្រាប់ពេលម៉ោងបន្តបន្ទាប់សួរលោកតទៅទៀត។ ដោយសារខ្ញុំមានពេលនៅរសៀលនេះទៀតដូច្នេះទេ បើមិនអ៊ីចេះទេ គឺថាសំណួររបស់ខ្ញុំហ្នឹងវាអាចនឹងមិនមានលក្ខណៈច្បាស់លាស់គ្រប់គ្រាន់ ប្រសិនណាជាខ្ញុំត្រូវការពេលវេលានៅថ្ងៃរសៀលទៀតនេះ។ តើលោកមានអ្វីដែលអាចនឹងបញ្ជាក់ជូនមកខ្ញុំបានទេ?

[១០:៥៤:២៩]

**ប្រធានអង្គជំនុំ៖**

បាទ ដើម្បីជាក់ច្បាស់លើបញ្ហាពេលវេលាក្នុងការតាំងសំណួរចំពោះសាក្សីរូបនេះ ដោយក្រុមមេធាវីការពារក្តីលោក នួន ជា។ អង្គជំនុំជម្រះសម្រេចផ្តល់ពេលវេលាមួយពេលទៀតនៅរសៀល គឺចាប់ផ្តើមត្រឹមពេលម៉ោងមួយសាមសិបនាទី ពេលចូល រហូតដល់ពេលឈប់សម្រាក គឺម៉ោងពីរសែសិបនាទី។

[១០:៥៥:១០]

**លោក ហ្សាស្តើ ប៉ោ៖**

សូមអរគុណលោកប្រធាន ជាប្រយោជន៍មួយដល់យើងខ្ញុំយ៉ាងច្រើនចំពោះពេលវេលានេះ។

**សួរដោយលោក ហ្សាស្តើ ប៉ោ៖**

**ស៖** មុនយើងឈប់សម្រាកអម្បាញ់មិញនេះ គឺយើងបាននិយាយគ្នាអំពីអ៊ីម៉ែលរបស់លោក។ លោកថា លោកបានផ្ញើអ៊ីម៉ែលទៅកាន់មនុស្សជាច្រើន ហើយយើងខ្ញុំបានទទួលការប្រាស្រ័យទាក់ទងតាមអ៊ីម៉ែលរបស់លោកដែរ។ អ៊ីចឹងសំណួររបស់ខ្ញុំនោះគឺ យ៉ាងដូច្នេះតើថ្មីៗលោកមានបានផ្ញើឡើងវិញនូវអត្ថបទមួយដែលលោកសរសេរជាមួយលោក ចន ឆរឈីអារី អំពីឯកសាររបស់កម្ពុជាប្រជាធិប-តេយ្យដែរឬទេ?

**លោក ឆាំង យុះ**

**ឆ៖** ខ្ញុំបានផ្ញើចេញបាទ។

**ស៖** ដូច្នេះ ខ្ញុំគិតថាលោកនៅតែប្រកាន់យកជំហរនេះគឺថា នៅក្នុងអត្ថបទជាគុណវិបត្តិមួយនៃឯកសារសវនាការឆ្នាំ១៩៧៩ ដែលលោកលើកឡើងថា វាមានបញ្ហាលម្អៀងខាងនយោបាយ។ អ៊ីចឹងខ្ញុំចង់លើកឡើងថាតើពាក្យ ការរំលេចពាក្យពេចន៍ថា វាមានការលម្អៀងផ្នែកនយោបាយនេះ គឺវាយ៉ាងម៉េចដែរ? ឬក៏ខ្ញុំសួរទៅវិញថា ហេតុអ្វីក៏មានគេហៅថា គោលការណ៍នៃការមានគុណវិបត្តិចំពោះសវនាការឆ្នាំ១៩៧៩ ដែលថាមានការលម្អៀងផ្នែកនយោបាយនោះ?

[១០:៥៦:៤៨]

**ឆ៖** ដូចខ្ញុំជម្រាបជូនលោកអ៊ីចឹង គឺថាយើងខ្ញុំបាននាំអ្នកជំនាញរបស់អង្គការសហប្រជាជាតិឆ្នាំ៩៨ ទៅកាន់បណ្ណសារដ្ឋានជាតិ ដើម្បីត្រួតពិនិត្យមើលឯកសារ ដែលមាននៅទីនោះ។ ហើយដូចលោកដឹងស្រាប់ហើយថា នៅពេលនោះគឺ ជនចុងចោទមិនមានវត្តមានទេ ហើយដូច្នេះហើយឯកសារទាំងអស់នោះទៀតសោត គឺមានលក្ខណៈមួយមិនគ្រប់គ្រាន់។ អ៊ីចឹងយើងឃើញថា សំខាន់ណាស់ គឺត្រូវមានតុលាការមួយទៀត គឺតុលាការសព្វថ្ងៃនេះ។ អ៊ីចឹងហើយបានជាទោះបីជាយ៉ាងណាក៏ដោយ ក៏យើងគិតថា អាចមានព័ត៌មានផ្សេងៗទៀត ដែលអាចប្រើប្រាស់បាន។ អ៊ីចឹង ខ្ញុំក៏បាននាំគាត់អញ្ជើញគាត់ទៅកាន់ទីនោះ។

**ស៖** លោកបានលើកឡើងនៅក្នុងចម្លើយរបស់លោកមុនពេលឈប់សម្រាកនេះថា ឯកសារមួយចំនួនត្រូវបានបំផ្លិចបំផ្លាញ ឬក៏ត្រូវបានគេបោះចូលទៅក្នុងទឹក។ លោកអាចជម្រាបបានទេថាតើអ្នកណាអាចបំផ្លិចបំផ្លាញហ្នឹង ដោយបោះវាចូលទៅក្នុងទឹកហ្នឹង?

[១០:៥៨:០៣]

**ឆ៖** ចំពោះឯកសារបោះនៅក្នុងទឹក លោកអាចសួរមន្ត្រីក្រសួងវប្បធម៌ និងព័ត៌មាននៅខេត្តស្ទឹងត្រែង ពីព្រោះខ្ញុំបានទៅដល់ទីនោះ ព្រោះខ្ញុំតាមរកឯកសារពាក្យបណ្ដឹងរបស់ប្រជាជនកាលពីឆ្នាំ៨២, ៨៣ ដែលកាលនោះ ខ្ញុំជឿជាក់ថា មានប្រជាជន១លានមួយសែននាក់ ទាមទារឲ្យមានតុលាការកាត់ទោសមួយ។ ពេលខ្ញុំទៅដល់គាត់ ខ្ញុំក៏ទៅរើ-- គាត់មានអគារផ្ទះឈើមួយនៅខេត្តស្ទឹងត្រែងហ្នឹង ហើយខ្ញុំសួរគាត់ថា ចុះឯកសារទៅណាអស់ទៅហើយ តាមបញ្ជីតួលេខដែលផ្ញើទៅគណៈអប់រំមជ្ឈិមបានបង្ហាញថា ប្រជាជនរាប់ម៉ឺននាក់បានផ្ញើព័ត៌មានទៅកាន់គណៈអប់រំមជ្ឈិមនៅទីក្រុងភ្នំពេញ? គាត់

បានប្រាប់ខ្ញុំថា ឯកសារទាំងអស់នេះ បានបោះចូលទៅក្នុងទន្លេមេគង្គ ហើយខ្ញុំមានបញ្ជីឯកសារ មានឈ្មោះអ្នកដែលរៀបចំឯកសារ ហើយសព្វថ្ងៃក៏ខ្ញុំមានបញ្ជីនេះ នៅក្នុង*អូហ្វហ្វីស* ខ្ញុំដែរ។ ហើយអ្នកដែលធ្វើការតាមដែលខ្ញុំដឹង គឺនៅធ្វើការទីនោះដដែលដែរសព្វថ្ងៃបាទ។ គាត់អ្នកប្រាប់ខ្ញុំ។

**ស៖** ដូច្នេះលោក ឆាំង យុ គឺថាខ្ញុំដឹងថា លោកមានចេតនាចង់បង្ហាញជូនតុលាការនូវបញ្ជីឈ្មោះនេះ ប្រសិនណាជាស្នើសុំឱ្យបង្ហាញនូវបញ្ជីឈ្មោះរបស់អ្នកទាំងនេះ។

**ឆ៖** ខេត្តស្ទឹងត្រែងមានបញ្ជីឈ្មោះ-- មានបញ្ជីឯកសារអ្នកដាក់បណ្ដឹងឆ្នាំ៨២, ៨៣ នៅក្នុងបញ្ជីនេះមានឈ្មោះអ្នកដែលរៀបចំឯកសារ ហើយគឺជាអ្នកដែលខ្ញុំបានទៅជួបសាកសួរ អំពីឯកសារដែលបាត់បង់ ហើយជាអ្នកដែលបានប្រាប់ខ្ញុំថា ឯកសារបោះចូលទៅក្នុងទឹកទន្លេមេគង្គ។

[១០:៥៩:៤៥]

**ស៖** ទើបតែលើកឡើងថា ខ្លួនលោកផ្ទាល់គឺថា លោកមានបានរៀបចំបញ្ជីឈ្មោះអ្នកដែលពាក់ព័ន្ធនៅក្នុងការផ្ដល់ឯកសារមកឱ្យលោកនេះ ឬក៏ខ្ញុំឃើញលោកគ្រវីក្បាល ឬក៏វាមិនត្រឹមត្រូវទេ?

**ឆ៖** មិនមែនទេ បាទ មិនមែនបញ្ជីដែលខ្ញុំធ្វើទេ។ បញ្ជីហ្នឹង ខាងហ្នឹងគេធ្វើហើយស្រេច។ ខាងខេត្តស្ទឹងត្រែង គេធ្វើហើយស្រេច ហើយខ្ញុំបានឃើញបញ្ជីហ្នឹង រកឃើញភ្លាម ទៅតាមសួរបញ្ជីហ្នឹង។ អ៊ីចឹង មិនមែនបញ្ជីហ្នឹង ខ្ញុំមិនមែនជាអ្នកធ្វើទេ គឺជាបញ្ជីរបស់ក្រសួងវប្បធម៌ និងព័ត៌មានខេត្តស្ទឹងត្រែង ហើយតាមរយៈបញ្ជីនេះ ខ្ញុំបានកាន់បញ្ជីដដែលហ្នឹង ទៅសួររកមនុស្សដែលធ្វើការនៅកន្លែងនោះ។ ហើយនៅក្នុងបញ្ជីហ្នឹង គឺជាបញ្ជីអ្នកនិយាយអំពីអ្នកដែលដាក់ពាក្យបណ្ដឹងឆ្នាំ៨២, ៨៣ ហើយមនុស្សដែលប្រាប់ខ្ញុំនោះ គឺមានឈ្មោះនៅក្នុងបញ្ជីហ្នឹងតែម្ដង ហើយគាត់គឺជាអ្នកដែលប្រាប់ខ្ញុំថា ឯកសារទាំងអស់ត្រូវប្រមូលទម្លាក់ទៅក្នុងទឹកទន្លេមេគង្គអស់ហើយ។

**ស៖** បាទ ជាការត្រឹមត្រូវនេះ។ តើបញ្ជីឈ្មោះនេះ គឺថាលោកនៅមានបញ្ជីឈ្មោះនេះមែនទេ? ហើយលោកអាចជូនឈ្មោះមកអង្គជំនុំជម្រះសាលាដំបូងបានទេ បើសិនណាអង្គជំនុំជម្រះស្នើសុំឱ្យលោកផ្ដល់បញ្ជីឈ្មោះទាំងនេះមក?

**ឆ៖** ខ្ញុំអាចប្រគល់ជូនគ្រប់ពេលវេលាបាទ។

**ស៖** សូមអរគុណលោក យុ។ សំណួរមួយទៀត ទាក់ទងទៅនឹងចម្លើយសារភាពដែលបានរកឃើញនៅមន្ទីរសន្តិសុខ ស-២១ គឺជាចម្លើយសារភាពរបស់ រស់ ញឹម ហៅក្រៅ ញឹម រស់ ឬក៏ មូល សម្បត្តិ។ ទោះបីជាខ្ញុំអានទៅ វាអាចនឹងមិនចាំក៏ដោយ ខ្ញុំគិតថា លោកអាចនឹងស្គាល់ឈ្មោះនេះ?

**ឆ៖** ខ្ញុំស្គាល់ឈ្មោះនេះបាទ។

[១១:០១:៥៧]

**ស៖** តាមដែលលោកដឹង តើចម្លើយសារភាពរបស់ប៉ុន្មានច្បាប់ដែរ ដែលមាននៅគុកទួលស្លែងនោះ?

**ឆ៖** កន្លែងនេះ ខ្ញុំមិនច្បាស់ទេបាទ មិនដឹងជាប៉ុន្មាន តែដឹងថាមាន។ មិនដឹងថាប៉ុន្មានច្បាប់។ យើងអាចរកបាននៅក្នុង ដេតាបេស របស់យើងអំពីចំនួនសន្លឹក យើងអាចរកឃើញបាទ។

**ស៖** តើលោកដឹង ថាតើចម្លើយសារភាពដែលរកបាននៅស-២១ នោះ តើចម្លើយសារភាពទាំងអស់នេះ ជាចម្លើយសារភាពដែលគាត់បានផ្តល់ជូនទៅ ឬក៏ថាមានចម្លើយសារភាពណាខ្លះវាអាចនឹងបាត់ពីនោះទេ?

**ឆ៖** ខ្ញុំបានតាមរកចម្លើយសារភាពដែរ ព្រោះខ្ញុំគិតទៅតាមតួលេខ ថានៅទីនោះ មានទោសជាង១២.០០០នាក់ ឬក៏១៤.០០០នាក់ ហើយជាទូទៅ យើងបានសាកសួរឆ្មាំគុកដែលរស់រានមានជីវិត និងអ្នកធ្វើឯកសារ។ ហើយទាំងអស់គ្នាហាក់ដូចជាប្រាប់ ខ្ញុំថាមនុស្សទាំងអស់ដែលឆ្លងកាត់នៅទីនេះ គឺត្រូវមានធ្វើជីវទស្សន៍ ឬក៏ប្រវត្តិរូប ឬក៏ថតរូប ឬក៏ផ្តល់ចម្លើយសារភាព។ ប៉ុន្តែចម្លើយសារភាពយើងមើលទៅ មានតែជាង៤.០០០ បាទក្នុងចំណោមមនុស្សជាង១២.០០០នាក់។ អ៊ីចឹង ខ្ញុំក៏បានស្រាវជ្រាវរកមើលទៀត ខ្ញុំឃើញមានបញ្ជីឯកសារមួយ ដែលមានមនុស្សខ្ចី។ បាទ នៅក្នុងសារមន្ទីរទួលស្លែងមានបងស្រី ឡាច វរល័ក្ខកល្យាណ គាត់ជាថែរក្សា ឃ្លាំមើលឯកសារនេះ ហើយជាទូទៅ ខ្ញុំបានសុំគាត់មើល ថាតើមានអ្នកណាខ្លះខ្ចីឯកសារទាំងអស់នេះ? ហើយបើគេខ្ចី យកមកដែរឬក៏អត់? អ៊ីចឹង ខ្ញុំបានរកឃើញថាមានបញ្ជីមួយ មានមនុស្សដែលខ្ចីដែរ។ ហើយខ្ញុំបានទៅតាមរកមនុស្សហ្នឹងទៀត ថាបើខ្ចីហើយយកមកដែរឬអត់? មកផ្ទៀងផ្ទាត់ពីអ្វីដែលទួលស្លែងបានប្រាប់ខ្ញុំថាបានឲ្យគេខ្ចីយកទៅប្រើប្រាស់អ្នកសិក្សាស្រាវជ្រាវជាដើម។

[១១:០៣:៥៧]

អ៊ីចឹង ខ្ញុំគិតថា ពេលនោះឯកសារមកទល់បច្ចុប្បន្ននេះ ខ្ញុំមិនធ្វើការសន្និដ្ឋានថា មានគ្រប់មួយរយភាគទេ មានការបាត់បង់ ហើយសូមបញ្ជាក់ថា ឯកសារទួលស្លែងនេះ ចំនួនពិតប្រហែលជាជាង៤.០០០ ប្រសិនបើលោកចង់បានច្បាស់ ខ្ញុំអាចរកពេលតាមក្រោយទៀត។ ប៉ុន្តែខ្ញុំគិតថា នៅមានទៀតមិនអាចគ្រប់ទេ នៅមានទៀត។

**សៈ** សូមអរគុណ។ នៅពេលដែលលោកសាកសួររកស្វែងរកចម្លើយសារភាពផ្សេងៗទៀតនោះ តើលោកមានបានទទួលចម្លើយសារភាពរបស់ វស់ ញឹម ទេ?

**ធៈ** ខ្ញុំមិនច្បាស់ដែរ ប៉ុន្តែបើសិនជាឯកសារនេះរបស់ទួលស្លែង ច្បាស់ជាមាន*ម៉ៃក្រូហ្វីម* ច្បាស់មាននៅកន្លែងនោះ ហើយគ្មានហេតុផលអ្វី ខ្ញុំត្រូវយកឯកសារពីទួលស្លែងមកដាក់ចូលមជ្ឈមណ្ឌលឯកសារកម្ពុជាទេ។ ប៉ុន្តែប្រហែលជាអាចហ្វូតូកូពី ពីព្រោះខ្ញុំចាំថា អង្កាល់ណោះ ខ្ញុំបានជួយធ្វើការសិក្សាស្រាវជ្រាវលោក ស្ទីវ ហេដឌ័រ ហើយគាត់ត្រូវការឯកសារជាច្រើនពីសារមន្ទីរទួលស្លែង ហើយយើងបានធ្វើហ្វូតូកូពី ជូនគាត់។ រឿងនេះអាចកើតមានឡើងជាសំណុំឯកសារហ្វូតូកូពី របស់លោក វស់ ញឹម នៅ*អូហ្វហ្វីស*របស់ខ្ញុំ។

[១១:០៥:១៣]

**សៈ** សំណួររបស់ខ្ញុំថាតើលោកមានបានស្វែងរកចម្លើយសារភាពដទៃទៀត ដែលអាចធ្វើឡើងដោយអ្នកដទៃ ឬក៏អាចធ្វើឡើងដោយ វស់ ញឹម ដែរឬទេ?

**ធៈ** ខ្ញុំចាំមិនច្បាស់ទេ បាទកន្លែងនេះបាទ។ មិនច្បាស់ដែរ។

**សៈ** សូមអរគុណលោក។ ខ្ញុំសូមបន្តចូលទៅប្រធានបទថ្មីមួយទៀត ប្រធានបទនេះក៏និយាយជាមួយអនុប្រធានរបស់លោកហើយ និយាយអំពីបណ្ណសាររបស់ ព្រះនរោត្តម សីហនុ ហើយគាត់បានលើកឡើងអំពីចំណុចហ្នឹង គឺថាមានបណ្ណសារនេះគឺថា បណ្ណាល័យនេះគឺមានក្នុងរយៈពេលខ្លីមួយ។ តើលោកមានអត្ថបទជាឯកសារជាក្រដាសមកពីបណ្ណាល័យរបស់នរោត្តម សីហនុ នេះដែរឬទេ? ហើយថាតើវាមានទីតាំងនៅទីណាដែរ?

[១១:០៦:២៨]

**ធៈ** សូមនិយាយឆ្លាយបន្តិចកន្លែងនេះ។ ខ្ញុំមានឯកសាររបស់ព្រះករុណាដែលបង្ហោះនៅលើគេហទំព័រ។ ជាទូទៅខ្ញុំបាន ឲ្យតែករណីណាមួយដែលទាក់ទងនឹងរឿងរបបកម្ពុជាប្រជាធិបតេយ្យ ខ្ញុំបានព្រីន វាចេញដើម្បីទុកសម្រាប់ធ្វើកិច្ចការស្រាវជ្រាវ ហើយក្រោយមកព្រះករុណាបានសម្រេចព្រះទ័យ ថាឯកសារទាំងអស់របស់ព្រះអង្គនេះគឺថាត្រូវតែទៅទុកនៅប្រទេសបែលហ្សិក វិញ ហើយមានការជជែកគ្នាតាមកាសែតភ្នំពេញប៉ុស្តិ៍ ថាហេតុដូចម្តេចបានជាព្រះករុណាមិនទុកឯកសារនេះមកមជ្ឈ-មណ្ឌលឯកសារកម្ពុជា ហើយខ្ញុំក៏មិនដឹងអំពីព្រះទ័យរបស់ព្រះអង្គដែរ។ ប៉ុន្តែឯកសារនេះ ខ្ញុំធ្លាប់បានទទួលជារូបថត ពី-- ហើយនិង ឯកសារក្រដាសមួយចំនួន តាមរយៈលោក ហ្សូលីយ៉ូ ហៀលជ្រេស

ដែលជាអ្នកសរសេរជីវប្រវត្តិរបស់ព្រះករុណាសម្តេចនរោត្តម សីហនុ សព្វថ្ងៃនេះនៅសាកលវិទ្យាល័យ ម៉ូណាស់ ប្រទេសអូស្ត្រាលី បាទ។

[១១:០៧:៣៣]

**ស៖** ហើយចង់ឲ្យច្បាស់ថា ខ្ញុំយល់ចម្លើយរបស់លោកតើលោកប្រាប់ខ្ញុំថា ឯកសារច្បាប់ដើមក្រដាសនៃបណ្ណសាររបស់ព្រះមហាក្សត្រនរោត្តម សីហនុ នៅប្រទេសបែលហ្ស៊ិកឬ?

**ឆ៖** ពាក្យជាភាសាបារាំងខ្ញុំចាំថា នៅវិទ្យាស្ថានចុងបូព៌ា *"អ៊ីសស្ទីម អូរីយ៉ង់តាល់ អ៊ីនស្ទីទូត"* ខ្ញុំគិតថានៅប្រទេសបែលហ្ស៊ិកដែរ ពីព្រោះលោកអាចស្រាវជ្រាវនៅក្នុងកាសែតភ្នំពេញប៉ុស្តិ៍ ព្រោះមានការជជែកគ្នា ថាហេតុដូចម្តេចបានជាបណ្ណសារដ្ឋាននេះមិននៅស្រុកខ្មែរ ហើយបានប្រគល់ឲ្យទៅខាងណោះទៅវិញបាទ។ សូមអធ្យាស្រ័យផង ពីព្រោះពាក្យនេះ វាវែង បើសិនជាលោក*ស៊ើច* ប្រហែលជាឃើញ។

[១១:០៨:២០]

**ស៖** តើលោកដឹងទេថា បណ្ណសារនេះអាចបើកលទ្ធភាពឲ្យអ្នកផ្សេងស្រាវជ្រាវបើកមើលបានទេ?

**ឆ៖** ខ្ញុំគិតថាវិទ្យាស្ថាននេះ ជាវិទ្យាស្ថានសិក្សាស្រាវជ្រាវចុងបូព៌ា ហើយខ្ញុំគិតថាប្រហែលជាគេមានរបៀបរបបអាចយើងទៅសិក្សាស្រាវជ្រាវបាន ខ្ញុំគិតលោកអាចសាកល្បងមើលបាទ។

**ស៖** តើលោកបានព្យាយាមបើកមើលនូវបណ្ណសាររបស់ព្រះវរមហាក្សត្រ នរោត្តម សីហនុ ទេនៅពេលកន្លងមកនោះ?

**ឆ៖** ថ្មីនេះ? បើថ្មីនេះអត់ទេ បាទ។

**ស៖** ហើយនៅពេលដែលការប្រមូលឯកសារនោះ គេដាក់ក្នុងប្រព័ន្ធអ៊ីនធឺណែត តើគេបានបោះពុម្ពជាឯកសារលើកក្រដាសនូវៗឯកសារទាំងអស់ដែលបានបង្ហោះនៅក្នុង*វេបសាយ* ដោយអ្នកដែលទទួលបន្ទុកក្នុងការដាក់ចូលក្នុងវេបសាយ នោះដែរឬទេ?

**ឆ៖** សូមលោកសម្រួលសំណួរឲ្យខ្លីបន្តិចព្រោះខ្ញុំវាអត់ច្បាស់កន្លែងនេះបាទ។

[១១:០៩:៤៦]

**ស៖** លោកបាននិយាយថា បណ្ណសាររបស់ព្រះមហាក្សត្រត្រូវបានដាក់នៅក្នុងវេបសាយ ក្នុងរយៈពេលខ្លី ហើយលោកក៏បាននិយាយដែរថា លោកបានបោះពុម្ពចេញនូវឯកសារមួយចំនួនដែលៗចុះ

នៅក្នុងវេបសាយ នោះ។ សំណួរខ្ញុំថា តើលោកបានបោះពុម្ពចេញទាំងអស់ ដែលគេដាក់នៅក្នុងវេបសាយ នោះដែរឬទេ?

**ឆ៖** អត់ទេបាទ។ មានពេលមួយនោះខ្ញុំចង់កូពី វេបសាយទាំងមូល ហើយខ្ញុំចាំថាមានពេលមួយនោះ ព្រះករុណាចង់លក់វេបសាយ ហ្នឹងទៅឱ្យអតិថិជន បើអ្នកណាចង់ត្រូវការ*វេបសាយ* នេះ។ ហើយខ្ញុំចាំថា អង្កាល់ពេលនោះ ប្រព័ន្ធអ៊ីនធឺណែតរបស់ស្រុកយើងវា *ស្លូ*-- វាយឺត អ៊ីចឹងយើងបានព្យាយាម ប៉ុន្តែហាក់ដូចជាមិនបានជោគជ័យទេ។ ចិត្តខ្ញុំកាលពេលនោះគឺថា ចង់កូពីទាំងស្រុងតែម្តងក្នុងគេហទំព័ររបស់ព្រះករុណា។ ប៉ុន្តែតាមដែលខ្ញុំចាំធ្វើទៅមិនបានជោគជ័យ ហើយយើងបានតែឯកសារណាដែលយើងព្រីនចេញមកបាន។

**ស៖** សូមអរគុណ។ ហើយខ្ញុំនឹងទុកប្រធានបទនេះក្នុងពេលនេះសិន ហើយខ្ញុំសូមអនុញ្ញាតចូលត្រឡប់ទៅចំណុចមួយទៀត ដែលលើកឡើងពីព្រឹកមិញនេះ ពីព្រោះខ្ញុំមិនទាន់ច្បាស់អំពីចំណុចមួយដែលទាក់ទងទៅនឹងបញ្ហាដែលយើងនិយាយអំពីការពិនិត្យកោសល្យវិច័យលើឯកសារ លើក្រដាសនោះ។ លោកបានរៀបរាប់អំពីការសន្ទនាជាមួយតំណាងរបស់សាលាក្តីនេះនៅក្នុងឆ្នាំ២០០៥ ទាក់ទងទៅនឹងលទ្ធភាពនៃការបញ្ជាក់យថាភាពនៃឯកសារ ហើយលោកទំនងជាបានបញ្ជាក់ថា ខ្ញុំមិនដាក់ពាក្យនៅក្នុងមាត់លោកទេ មិនឱ្យលោកសន្និដ្ឋានទេ ដែលថាតំណាងរបស់តុលាការ ហាក់ដូចជាមិនមានឆន្ទៈក្នុងការប្រើនូវនីតិវិធីឱ្យបានត្រឹមត្រូវ ដើម្បីបញ្ជាក់យថាភាពឯកសារនេះទេ។ តើលោកអាចប្រាប់តុលាការឱ្យទូលាយជាងហ្នឹងទៀតទេ ឱ្យពិស្តារថា ជាមួយមន្ត្រីតុលាការនោះ សេចក្តីលម្អិតដូចម្តេចបាទ?

[១១:១២:០៤]

**ឆ៖** ជាទូទៅខ្ញុំមិននិយាយជាមួយមាត់ទេ ខ្ញុំសរសេរជាលាយលក្ខណ៍អក្សរបាទ។ ដូចខ្ញុំជម្រាបជូនលោកអ៊ីចឹង ទោះបីខ្ញុំទៅធ្វើដំណើរទៅទីក្រុងញូវយ៉ក ជួបជាមួយអ្នកស្រី មីសែល លី យ៉ាងណាក៏ដោយ ខ្ញុំមានលិខិត។ បាទ ខ្ញុំសរសេរលិខិតរហូតទៅខាងភាគីរដ្ឋាភិបាលទៀត។ ខ្ញុំប្រាប់ថាបញ្ហាឯកសារនេះជាបញ្ហាសំខាន់ណាស់ គឺដើម្បីធានានូវយថាភាព គឺថាត្រូវមានកិច្ចព្រមព្រៀងមួយរវាងមជ្ឈមណ្ឌលឯកសារកម្ពុជាហើយនិងតុលាការ ដើម្បីធ្វើយ៉ាងណាកុំឱ្យមានបញ្ហា លើបញ្ហានេះ ដោយសារថាយើងចង់បម្រើគ្រប់ភាគីទាំងអស់។ បាទ អ៊ីចឹងខ្ញុំបានសរសេរជាលិខិត ហើយលិខិតខ្ញុំមានទុកទាំងអស់ទល់សព្វថ្ងៃ តាំងពី ២០០៥, ២០០៦, ២០០៧ គ្រប់ដំណាក់កាលទាំងអស់ខ្ញុំតែងតែរំឭកទៅតុលាការអំពីវាជាការសំខាន់។ នៅពេលដែលខ្ញុំរំឭកទៅដល់តុលាការនេះ ព្រោះមានសំណើសុំមកពីភាគី

ទាំងអស់ មកពីខាងសហចៅក្រមស៊ើបអង្កេត មកពីសហព្រះរាជអាជ្ញា មកពីក្រុមការពារក្ដី។

[១១:១២:៥១]

អ៊ីចឹងយើងក៏គិតថា បើសិនជាគ្មានការព្រមព្រៀងណាមួយរវាង អ.វ.ត.ក និងមជ្ឈមណ្ឌលឯកសារកម្ពុជាទេ យើងផ្តល់ជូនដូចជាគេដូចជាឯង ជាបណ្ណសារដ្ឋានមួយ ជាកន្លែងស្រាវជ្រាវសាធារណៈ អ្នកណាចង់បានអី យើងឲ្យហ្នឹងទៅ។ អ៊ីចឹងអត់មានចំណងណាមួយ ដែលត្រូវបានចុះហត្ថលេខាទេ រហូតពេលដែលលោក ស៊ាន វិសុទ្ធ ត្រូវបានសម្រាកក្នុងករណីណា ដោយប្រការណាមួយនោះ អ្នកស្រី មីសែល លី ក៏បានលាចេញពីតំណែងទៅ ខ្ញុំបានរំឭកសាឡើងវិញម្ដងទៀតទៅលោក ឃ្នុត ហើយនិងលោកតូនី ក្រាញ់។ ខ្ញុំថាចាំបាច់ណាស់ គួរតែមាន អ៊ឹម.អូ.យូ មួយ ដើម្បី-- ហើយថ្ងៃណាមួយបើសិនជាមេធាវីណាមួយចង់ទៅមើលឯកសារដើម យើងត្រូវមាន*ប្រូស៊ីជឺ* មួយ ត្រូវធ្វើយ៉ាងដូចម្ដេចឲ្យបានច្បាស់លាស់។ ប៉ុន្តែគ្មានការឆ្លើយតបទាល់តែសោះ។ ហើយខ្ញុំចង់ខឹងបន្តិចផង ព្រោះថាទោះបីព្រមមិនព្រមគួរតែប្រាប់។ ហើយការដែលឆ្លើយសំបុត្រទៅ ដែលយើងយកឯកសារផ្ដល់មករាប់សែនហើយមិនឆ្លើយ ខ្ញុំចាត់ទុកថា ជាការមាក់ងាយដល់តម្លៃការងារជាប្រវត្តិសាស្ត្រនេះ។

អ៊ីចឹងខ្ញុំមានលិខិតទាំងអស់ ហើយបើសិនជាលោកចង់បាន ខ្ញុំមានគ្រប់លិខិតដែលខ្ញុំទាក់ទងមក ហើយគ្រប់ពេលដែលខ្ញុំទាក់ទងមក គឺខ្ញុំតែងតែទាក់ទងទាំងភាគីសងខាង។ ពីព្រោះយើងត្រូវទាក់ទងមកកន្លែងរដ្ឋបាល យើងមិនអាចទាក់ទងមកសហព្រះរាជអាជ្ញា ឬក៏អ្នកការពារជនចុងចោទ ឬក៏ចៅក្រមស៊ើបអង្កេតទេ។ អ៊ីចឹងក៏យើងសរសេរសំបុត្រទៅរដ្ឋបាល។ ប៉ុន្តែរដ្ឋបាលមិនដែលឆ្លើយតបទាល់តែសោះអំពីបញ្ហានេះ លើកលែងតែលិខិតមួយគាត់សរសេរថា យើងសូមអរគុណដែលបានផ្តល់ឯកសារជាងប្រហែលប្រាំសែននេះ ហើយយើងចាត់ទុកថាលោកគឺជា *ដូនណើ អ៊ីនខាញ* មកដល់ អ.វ.ត.ក។ មានតែប៉ុណ្ណឹងឯងបាទ។

[១១:១៤:១៧]

ហើយពង្រាង កិច្ចព្រមព្រៀងនេះខ្ញុំបានបង្ហោះនៅលើគេហទំព័រ។ ក្នុងករណីណាមួយដែលតុលាការចង់ឲ្យមាន អ៊ឹម.អូ.យូ នេះយើងអាចធ្វើបានភ្លាមៗ។ ហើយនៅក្នុងនេះយើងដាក់តម្លៃទៀត ដាក់តម្លៃអំពីការហ្វូតូកូពី ឯកសារ យើងគិតជាលុយបាទ។ ពីព្រោះ ហើយយើងគិតស្តង់ដារក្នុងស្រុកបាទ មិនមែនគិតជាស្តង់ដារអន្តរជាតិ ដូចក្នុង អាយ.ស៊ី.ធី.វ៉ាយ ទេ។ យើងគិតតម្លៃម៉ៃក្រូហ្វីម ក្រដាសផ្សេងៗដែលយើងប្រើប្រាស់។

អ៊ីចឹងយើងមានទាំងស្រុងនៅក្នុងនេះ អំពីការនីតិវិធី បើសិនជាមានមេធាវីណាមួយចង់ផ្ទៀងផ្ទាត់ឯកសារដើម ក៏យើងមានរៀបចំពង្រាងហើយស្រេច បើសិនជាតុលាការចង់ឲ្យមានកិច្ចព្រមព្រៀងណាមួយក៏យើងបានធ្វើពង្រាងហើយស្រេច។ យើងរង់ចាំតែតុលាការជូនជាយោបល់មកយើងវិញ ពេញចិត្ត ឬក៏មិនពេញចិត្ត។ ប៉ុន្តែមកទាល់សព្វថ្ងៃនេះ គ្មានជាលាយលក្ខណ៍អក្សរណាមួយទាល់តែសោះអំពីការិយាល័យរដ្ឋបាលរបស់ អ.វ.ត.ក នេះ។

[១១:១៥:១០]

**ស៖** សូមអរគុណលោក ឆាំង យុ ហើយខ្ញុំច្បាស់ហើយពេលនេះ។ បន្តទៅទៀត គឺខ្ញុំសូមអនុញ្ញាតតុលាការដើម្បីសួរសំណួរមួយចំនួនទាក់ទងទៅនឹងអ្វីដែលលោកធ្វើទៅនឹងឯកសារ នៅពេលដែលលោកបានទទួលឯកសារហ្នឹងហើយ ត្រូវធ្វើអ្វី? លោកបាននិយាយកាលពីសប្តាហ៍មុនថា មជ្ឈមណ្ឌលឯកសារនោះមិនៗបានវាយតម្លៃថា នៅព័ត៌មានក្នុងនោះដាក់បន្ទុក ឬដោះបន្ទុកនោះទេ។ ខ្ញុំចង់សួរឲ្យស៊ីជម្រៅជាងហ្នឹងបន្តិច ជាបឋម ខ្ញុំនឹងបង្ហាញនូវក្របសៀវភៅមួយដែលនិយាយអំពីបុគ្គលប្រាំពីរនាក់ដែលនេះ គឺឯកសារ E3/48 ឯកសារ ERN 003937--

**អ្នកបកប្រែ៖**

សូមអនុញ្ញាតលោកប្រធានគាត់អាន ERNលឿនពេកអ្នកបកប្រែមិនអាចតាមទាន់ទេបាទ។

[១១:១៦:៤០]

**ប្រធានអង្គជំនុំ៖**

រៀបចំសំណួរអម្បាញ់មិញម្តងទៀត ដោយលោកនិយាយលឿនពេកលេខERN ហ្នឹងគឺខាងអ្នកបកប្រែស្តាប់មិនទាន់ទេ ហើយគាត់បកប្រែមិនបានទេ។ សូមឲ្យយឺតៗ ដើម្បីឲ្យការកំណត់នូវអត្តសញ្ញាណឯកសារហ្នឹងឲ្យបានជាក់ច្បាស់។

**សួរដោយលោក ហ្សាស្តេី ប៉ោ៖**

សូមអភ័យទោស ខ្ញុំសូមមិនទាន់សួរសំណួរទេ។ ខ្ញុំ--

**ស៖** សូមឲ្យមើលក្របសៀវភៅមួយនៃសៀវភៅដែលនិយាយថា "ជនប្រាំពីររូបដែលត្រូវចោទប្រកាន់" ដើម្បីឲ្យសាក្សីអាចធ្វើសក្ខីកម្មថា តើនេះជាការបោះពុម្ពផ្សាយរបស់មជ្ឈមណ្ឌល ឌី.ស៊ី.ខេមដែរ ឬទេ? ប្រសិនជាចាំបាច់ ខ្ញុំនឹងថាឡើងវិញនូវERN នោះ បាទខ្ញុំនឹងនិយាយយឺតជាងនេះបាទ។

**លោក ឆាំង យុះ**

**ឆ៖** បាទ ដូចលោកមេធាវីឃើញហើយ យើងដាក់ថាបោះសាឡើងវិញ *វីផាប់ប្លិស*។ បានន័យថា ឯកសារនេះត្រូវបោះឡើងដោយសាកលវិទ្យាល័យនៅសហរដ្ឋអាមេរិក ហើយបើសិនជាលោកមើលទៅទំព័រខាងក្នុងមានដាក់ពាក្យថា "*ឌីសក្លេមម័រ*" បានន័យថា ជាគំនិតគឺជាការសិក្សាស្រាវជ្រាវរបស់លោក ស្ទីវ ហេដឌ័រ ជាមួយ ប្រាយអ៊ិន ធីតធីម័រ ដោយសារថាលោក ស្ទីវ ហេដឌ័រ បានប្រើប្រាស់ឯកសាររបស់យើង ហើយវាជាការប្រឹងប្រែងរបស់យើងនៅក្នុងការជួយផ្តល់ឯកសារទៅគាត់។ អ៊ីចឹងក៏យើងបានសូមផ្តល់ សូមបោះពុម្ពសាឡើងវិញ ដើម្បីចែកចាយឲ្យប្រជាពលរដ្ឋបានដឹងអំពីបញ្ហានេះ។

[១១:១៨:១៥]

ហើយនៅក្នុងក្របទីមួយហ្នឹង ជាទូទៅនៅក្នុងបោះផ្សាយឯកសាររបៀបនេះ យើងប្រើពាក្យ "*ឌីសក្លេមម័រ*" ហើយលោកបានដឹងហើយថា វាគឺជារឿងរបស់លោក ស្ទីវ ហើយនិងលោក ធីតធីម័រ។ ហើយនៅក្នុងការសិក្សានេះ ខ្ញុំផ្ទាល់ជាអ្នកហ្វូតូកូពី ឯកសារជូនគាត់ ដែលប្រាប់កាលពីសប្តាហ៍មុនមានរហូតដល់ទៅពីរទូ ប្រាំបីថត។ ហើយជាទូទៅគឺគាត់សង្កត់ទៅលើប្រភេទឯកសារណាដែលជា ឯកសារជាប្រភេទទូរលេខ។

**ស៖** សូមអរគុណលោក ឆាំង យុ។ ពិតហើយ គឺថាវាត្រូវមានពាក្យថា "*ឌីសក្លេមម័រ*" ដែលថាខ្លឹមសារនេះដែលបោះលើក្រដាសនេះ គឺជាមតិរបស់អ្នកនិពន្ធទេ ដូចជាថា លោក ស្ទីវ ហេដឌ័រ និងធីតធីម័រ ជាដើមអ៊ីចឹង។ ដូច្នេះ សៀវភៅនេះគឺយើងរកឃើញនៅក្នុងវេបសាយ របស់ ឌី.ស៊ី.ខេម គឺនៅក្នុងថាកន្លែងបោះពុម្ពផ្សាយ។ លោកបានពាក់ព័ន្ធចូលរួមក្នុងការបោះពុម្ពផ្សាយសៀវភៅនេះ ជាពិសេសលោកបានដឹងហើយថា នៅក្នុងក្របនេះមានចំណងជើងបែបនេះ។

[១១:១៩:៣៣]

ខ្ញុំនឹងសូមចូលទៅដល់ មិនដល់ខ្លឹមសារសៀវភៅទេ ខ្ញុំនិយាយអំពីអារម្ភកថា ដែលនិយាយអំពីច្បាប់បោះពុម្ពលើកទីពីរ នៅក្នុង ERN 00393483។ ហើយខ្ញុំអាចជម្រាបលោកថា ដើម្បីជា-- យើងបង្វិលទៅក្នុងទំព័រខាងក្រោមនៃទំព័រទីពីរ ដែលយើងមើលនៅក្នុងអារម្ភកថានេះ លោក ឆាំង យុ ជានាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយបាទដូចឃើញនៅក្នុងនេះគឺថានៅទំព័រដំបូងនៃអារម្ភកថានេះឃើញថា កថាខណ្ឌទីមួយនៃអារម្ភកថានេះ លោកបាននិយាយថា គម្រោងនិយាយពី *អាខោនថេបិលីធី*

*ប្រូចិច* គឺថាមិនដែលជាតួនាទី -- តំណាងពីតួនាទីដ៏សំខាន់មួយរបស់មជ្ឈិម ហើយវាមានគោលបំណងពីរចម្បងនៅក្នុងនេះ។ ទីមួយ គឺដើម្បីបង្កើតព័ត៌មានដែលអាចប្រើជាភស្តុតាងដ៏សំខាន់ ដែលអាចនឹងយកទៅប្រើនៅក្នុងការជំនុំជម្រះរបស់មន្ត្រីបក្សកុម្មុយនីស្តកម្ពុជា ហើយកថាខណ្ឌទីបី ហើយខ្ញុំដកស្រង់ដោយត្រង់ពីខ្លឹមសារនេះ លោកបានបញ្ជាក់ថា គម្រោងនិយាយពីការទទួលខុសត្រូវនេះ គឺនិយាយពីទាក់ទងទៅនឹងការបោះពុម្ពផ្សាយនូវរបាយការណ៍នេះ គឺជាការវិភាគនូវឯកសារភស្តុតាងមួយចំនួនផងដែរ។ ខ្ញុំកត់សម្គាល់ដើម្បីកំណត់ត្រាតុលាការ តាមមតិរបស់លោក ថាតើមជ្ឈមណ្ឌលឯកសារកម្ពុជាវិភាគព័ត៌មានដែរឬទេ ថាតើនៅក្នុងរបាយការណ៍នេះ ដែលហៅថាអាចនឹងគេយកទៅប្រើក្នុងខ្លឹមសារសៀវភៅមួយនិយាយអំពីបេក្ខជនប្រាំពីររូប ដើម្បីការ-- ត្រូវរងការចោទប្រកាន់នុ៎ង។ តើលោកអាចប្រាប់ខ្ញុំថាតើ ក្នុងវិធីណាមួយដែលលោកវិភាគឯកសារភស្តុតាងទាំងអស់ហ្នឹង? ដូចដែលលោកបានបញ្ជាក់នៅក្នុងអារម្ភកថា នៃសៀវភៅនេះនោះបាទ?

[១១:២២:០៧]

**ឆៈ** ដូចខ្ញុំជម្រាបលោកហើយអ៊ីចឹងថា នៅក្នុងនេះមាន *ឌីសក្លេមម័រ* គឺជាលោករបស់ ស្ទីវ ហើយនិងលោក ប្រាយអ៊ិន ធីតធីម័រ ហើយជាទូទៅពាក្យ *អេវីដិន* នេះគឺថាច្បាប់មិនបានផ្តាច់មុខ ថាតើដោយសារថាយើងជា *សូស្យល សាយអ៊ិនធីស* បាទយើងជាអ្នកប្រវត្តិសាស្ត្រ គឺយើងចង់បង្ហាញអំពីព្រឹត្តិការណ៍មួយ ការពិតនៃព្រឹត្តិការណ៍មួយ។ ពេលណាដែលយើងប្រើពាក្យ *អេវីដិន* នៅក្នុងនេះ។ ហើយដូចខ្ញុំប្រាប់អង្គាល់ពីលើកមុនអ៊ីចឹង បាទ *ឡ ដឺសណាត មូណូប៉ូលី ឌឺសណាត អេវីដិន*។ ដូចគ្នាដែរ។ ហើយចំពោះពីរឿងកម្មវិធីក្នុងការចុះទៅសួរអ្នកស្រុកនេះ គឺជាប្រភេទឯកសារមួយដែលយើងចង់ដឹងថា នៅក្នុងជុំវិញបទឧក្រិដ្ឋទាំងឡាយដែលយើងបានឮនេះ មានរណ្តៅសាកសព មានគុក មានអីនេះ តើនៅក្នុងបញ្ហាប្រវត្តិសាស្ត្រ វាមានរឿងអ្វីដែលបានកើតឡើង។ អ៊ីចឹងលោក ស្ទីវ ក៏បានប្រើប្រាស់ឯកសារហ្នឹងដែរ ដែលយើងប្រមូលតាមរយៈការបទសម្ភាស តាមរយៈតេឡេក្រាម ហើយនិងតាមរយៈចម្លើយសារភាព។

[១១:២២:៥៨]

អ៊ីចឹងនៅក្នុងន័យនេះ បើសិនជាលោកមើលឃ្លាដំបូង ហើយបន្ទាត់ទីពីរយើងនិយាយអំពីការផ្សះផ្សាជាតិ ប៉ុន្តែលោកមិនបានអានទេ លោកអានតែចំណុចទីមួយ។ ចំណុចទីពីរយើងបាននិយាយថាទាំងអស់នេះ វាជួយដល់ការផ្សះផ្សាជាតិ បើសិនជាយើងដឹងរឿងពិតអំពីប្រវត្តិសាស្ត្រ។ បើសិនជា

លោកឡើងទៅខាងលើ មើលចំណុចទីពីរ គឺខ្ញុំចាំច្បាស់ណាស់ ខ្ញុំឲ្យពិភាក្សាជាមួយ ចន គឺគោលជំហររបស់យើងគឺដើម្បីការផ្សះផ្សាជាតិ។ អ៊ីចឹងចំណុចទីពីរ លោកឡើងទៅលើ លោកឃើញហើយបាទ។

**ស៖** លោក ឆាំង យុ ខ្ញុំមិនជំទាស់ទេនៃគោលបំណងរបស់មជ្ឈមណ្ឌលថា ដើម្បីផ្សះផ្សាជាតិ ប៉ុន្តែតាមបុព្វកថាក្នុងសៀវភៅនេះ ដែលលោកបញ្ជាក់ហ្នឹង គឺថាគោលបំណងមួយនៃគម្រោងជំរុញឲ្យមានការទទួលខុសត្រូវគឺថាបង្កើតភស្តុតាង ដើម្បីការចោទប្រកាន់ ទីពីរគឺដើម្បីជួយសម្រួលឲ្យមានការផ្សះផ្សាជាតិ ប៉ុន្តែខ្ញុំពិនិត្យមើលឋានានុក្រមនៃគោលបំណងនេះ ក៏ប៉ុន្តែខ្ញុំ យើង-- ខ្ញុំចង់បានយោបល់របស់លោកអំពី ដែលពាក្យថា ការផលិតនូវភស្តុតាងជាសក្តានុពល នៅក្នុងគោលដៅទីមួយនោះន៎។ ទីមួយខ្ញុំយល់ស្របជាមួយលោក គឺថាមាន *ឌីសក្លេមម័រ* គឺមានសេចក្តីប្រកាសថា គឺ ប្រាយអ៊ិន ធីតធីម័រ ហើយនិង ស្ទីវ ហេដឌ័រ ទេជាអ្នកទទួលខុសត្រូវលើខ្លឹមសារនោះ។ ខ្ញុំមិនសួរពីបញ្ហានេះទេ។ ឥឡូវនេះ ខ្ញុំមើលកថាខណ្ឌទី៣ ដែលនិយាយថា គម្រោងជំរុញឲ្យមានការទទួលខុសត្រូវនោះ គឺថាមានផ្នែកពីរចម្បង។

ទីមួយ គឺការវិភាគនូវឯកសារភស្តុតាង មិនមែនការវិភាគរបស់ ស្ទីវ ហេដឌ័រ ឬក៏ ប្រាយអ៊ិន នោះទេ។ គឺមនុស្សនៅក្នុងគម្រោងជំរុញឲ្យមានការទទួលខុសត្រូវទេ ជាអ្នកវិភាគ។ ថាតើការវិភាគនោះមានលក្ខណៈដូចម្តេច? ការវិភាគដូចម្តេចដែលថាការវិភាគនូវឯកសារភស្តុតាងបែបនេះនោះបាទ?

[១១:២៤:៥៤]

**ឆ៖** ខ្ញុំគិតថា នៅកន្លែងនេះប្រហែលជាទាក់ទងនឹងការបកប្រែឯកសារទូរលេខ ពីព្រោះយើងមានពេលមួយនោះ ខ្ញុំចង់បោះឯកសារទូរលេខទាំងស្រុងតែម្តង។ យើងបានសុំថវិកាពីប្រទេសហូឡង់កាលណោះ។ យើងចង់បោះឯកសារទូរលេខ ពីព្រោះយើងយល់ថាឯកសារនេះសំខាន់ណាស់ ហើយអាចប្រើប្រាស់ជាសាធារណៈ។ អ៊ីចឹងយើងបានបកប្រែទាំងអស់នូវឯកសារទូរលេខនេះជាភាសាអង់គ្លេស។ ប៉ុន្តែសភាពការណ៍ វាមិនអំណោយផល វាមិនបានទាន់ពេលវេលា ក៏យើងមិនបានបោះផ្សាយឯកសារនេះទៅ។ តាមដែលខ្ញុំចាំ នៅក្នុងពេលដែលយើងបកប្រែឯកសារទូរលេខទាំងអស់នេះ ខ្ញុំបានឲ្យក្រុមឆ្លើយតបទៅនឹងសំណើរបស់តុលាការ ហើយកាលណោះ ដូចជាខ្ញុំចាំថាមានបុគ្គលិកខ្ញុំម្នាក់ឈ្មោះ សួ ប៊ុនស៊ូ ឲ្យសរសេរជាសង្ខេប។ បាទ យើងនៅនោះ យើងប្រើពាក្យសង្ខេប *សាំម៉ារី* ហ្នឹង អំពីថាស្អីខ្លះដែលជាទូរលេខទាំងអស់ហ្នឹង។ ហើយខ្ញុំចាំថាឯកសារទាំងអស់នោះ ដែលបានបកប្រែរួច ហើយដែលបានសរសេរសេចក្តីសង្ខេបរួចហើយនេះ ខ្ញុំបានប្រគល់មកឲ្យតុលាការទាំងអស់ ដើម្បីពន្លឿន

កិច្ចការសិក្សាស្រាវជ្រាវ ដោយសារនេះជាភាសាអង់គ្លេសហើយស្រេច។

[១១:២៥:៥២]

អ៊ីចឹង ខ្ញុំគិតថាទាំងអស់នេះប្រហែលជាទាក់ទងទៅនឹងទូរលេខដែលខ្ញុំបានបកប្រែៗ ជាក្រុម។ ទូរលេខនេះមានទៅដល់រាប់ពាន់ទូរលេខ បាទជាភាសាអង់គ្លេស។

**ស៖** ដូច្នេះ លោកឆ្លើយថា ការវិភាគនេះធ្វើឡើងដោយ គឺថានៅក្នុងគម្រោងទំនួលខុសត្រូវ គឺវាផ្អែកលើការបកប្រែតេឡេក្រាម សារទូរលេខ តើអ៊ីចឹងមែនទេ?

**ឆ៖** នៅក្នុងការសិក្សារបស់ ស្ទីវ នេះ--

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយ។ បាទ សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ។

[១១:២៦:៣៥]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអភ័យទោស ដែលខ្ញុំបាននិយាយកាត់នេះ គឺថាយើងជំទាស់ទៅនឹងសំណួរនេះ គឺថាមេធាវីដូចជាត្រឡប់ទៅទៅប្រធានបទនៅសប្តាហ៍មុនកាលពីខែកុម្ភៈនោះ គឺទាក់ទងទៅនឹងគោលបំណងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។ ដូច្នេះ សំណួរនេះគឺថាអាចនឹងភ្ជាប់ទំនាក់ទំនងថាការងារ ហើយនិងទស្សនៈវិស័យ។ ដូច្នេះ មិនទាក់ទងទៅនឹងសាលាក្តីនេះទេ។ តុលាការបានសម្រេចថា យើងយល់ហើយឃើញថា អ្វីដែលជាការងារទាំងអស់នោះ តុលាការបានស្តាប់អស់ទៅហើយ។ ហើយយើងមិនត្រូវដើរថយក្រោយនោះទេ។

ដោយមូលហេតុនេះ មេធាវីការពារទំនងជាដើរថយទៅក្រោយ សួរសំណួរនោះឡើងវិញ។ ដូច្នេះ សូមតុលាការបង្គាប់ឲ្យគាត់សួរទៅមុខវិញ។

[១១:២៧:២៤]

**លោក ហ្សាស្តេី ប៉ោ៖**

ខ្ញុំសូមអនុញ្ញាតឆ្លើយភ្លាម ខ្ញុំមិនមានបំណងសួរពីភាពលម្អៀងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាទេ គោលបំណងរបស់ខ្ញុំ គឺសួរដោយជាក់លាក់អំពីវិធីសាស្ត្រដែលមជ្ឈមណ្ឌលឯកសារកម្ពុជាពិនិត្យភស្តុតាង ឬក៏ឯកសារទាំងអស់នោះថា តើវិធីគេវិភាគដូចម្តេច ថាតើព័ត៌មានទាំងអស់នោះគេផ្ទេរចូលទៅឲ្យ បញ្ជូនទៅភាគីទីបីដោយរបៀបណា ជាពិសេស អ.វ.ត.ក។ ហើយខ្ញុំមិនសួរអំពីៗមូលហេតុ

ដែលថា ឌី.ស៊ី.ខេម ទាក់ទងទៅនឹងការងារជាក់ស្តែងដែលធ្វើនៅទីនោះ នោះទេ។ ហើយយើងនិយាយតែអំពីដំណើរការ ហើយនិងការផ្ទេរបញ្ជូនឯកសារនៅក្នុងព្រឹកនេះតែប៉ុណ្ណោះ។

ខ្ញុំសូមអនុញ្ញាតតុលាការ អនុញ្ញាតឲ្យខ្ញុំសួរបន្តទៅទៀត សួរសំណួរនេះ បាទ។

*(ចៅក្រមពិភាក្សាគ្នា)*

[១១:២៩:៥៩]

**ប្រធានអង្គជំនុំ៖**

ការជំទាស់របស់តំណាងសហព្រះរាជអាជ្ញាអន្តរជាតិមានមូលដ្ឋានត្រឹមត្រូវ។ ដូច្នេះ ជំទាស់នេះមានប្រសិទ្ធភាព។ សាក្សីមិនបាច់ឆ្លើយតបទៅនឹងសំណួរដែលសួរចុងក្រោយដោយមេធាវីការពារក្តី នួន ជា ទេ។

មេធាវីអាចតាំងសំណួរផ្សេងទៀតបាន។

**លោក ហ្សាស្តេី ប៉ៅ៖**

សូមអរគុណលោកប្រធាន។ ឥឡូវនេះខ្ញុំអនុញ្ញាតបន្តទៅមុខទៀត។

**សួរដោយលោក ហ្សាស្តេី ប៉ៅ៖**

**ស៖** បន្ទាត់ទីបីនៃកថាខណ្ឌដដែល ដែលខ្ញុំបានបង្ហាញសាក្សី គឺនិយាយថាចាប់តាំងពីឆ្នាំ២០០១ គឺថាមជ្ឈមណ្ឌលមានបុគ្គលិក គឺថាប្រមូលឯកសារ ចងក្រងជាឯកសារ គឺថាអំពីមន្ត្រីដប់រូប អតីតមន្ត្រីដប់រូបនៃបក្សកុម្មុយនីស្តកម្ពុជា។ តើលោកអាចប្រាប់ឈ្មោះកម្មាភិបាល ឬក៏មន្ត្រីដប់រូបរបស់អតីតកម្ពុជាប្រជាធិបតេយ្យបានទេ លោកសាក្សី?

[១១:៣១:១០]

**លោក ឆាំង យុ៖**

**ឆ៖** ដូចខ្ញុំជម្រាបលោកអ៊ីចឹង គឺយើងមានបញ្ជីពីរ គឺទីមួយ គឺធ្វើឡើងដោយលោកសាស្ត្រាចារ្យ ប៊ែន ឃៀរនិន ដែលបោះផ្សាយនៅក្នុងសៀវភៅ "*ជេណូសាយ អេន ដេម៉ូក្រាស៊ី អ៊ីន ខេមបូឌា*" គឺមានដល់២០រូបឯណោះ តាមដែលខ្ញុំចាំ មាន២០រូប។ នៅក្នុងទំព័រ១៣ និងទំព័រ១៤ ហើយយើងមានបញ្ជីមួយទៀត គឺជាបញ្ជីប្រវត្តិរូបមេដឹកនាំខ្មែរក្រហម។ នៅក្នុងនោះគឺជាបញ្ជីមួយដែលមានមនុស្សជាង ២០នាក់ឯណោះ ហើយបញ្ជីទាំងអស់នេះ គឺបោះផ្សាយជាសាធារណៈ បើសិនជាលោកអាចរកឃើញសៀវភៅនេះ គឺនៅក្នុងទំព័រ១៣ និងទំព័រ១៤ ខ្ញុំប្រាប់កាលពីសប្តាហ៍មុនរួចហើយ។

[១១:៣១:៥២]

**ស៖** ដូច្នេះខ្ញុំមិនទាន់សួរសៀវភៅរបស់ ប៉ែន យៀវនិន ទេ ខ្ញុំសួរពីសៀវភៅពីអតីតកម្មាភិបាលកម្ពុជាប្រជាធិបតេយ្យដប់រូប ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងឯកសារភស្តុតាងទាក់ទងនឹងពួកគាត់នោះ។ ខ្ញុំសួរម្តងទៀត តើលោកអាចប្រាប់ឈ្មោះកម្មាភិបាលដប់រូប ដែលនៅក្នុងបញ្ជីនោះទេ លោកសាក្សីបាទ?

**ឆ៖** ខ្ញុំអាចចាំច្បាស់ប្រាំនាក់បាទ យ៉ាងហោចណាស់ ពីព្រោះវាមិនដឹងជាអ្នកណាទៀត ហើយយើងអាចមើលទៅក្នុងឯកសារ ដោយសារទាំងប្រាំនាក់នេះ គឺមានតួនាទីពិតប្រាកដបាទ។ ដូចជា លោក នួន ជា បាទ គាត់ជាសមាជិកមួយនៅក្នុងគណៈមជ្ឈិមបក្សនៃបក្សកុម្មុយនីស្តកម្ពុជា មាន លោក អៀង សារី, មានលោក ខៀវ សំផន, មានលោកស្រី អៀង ធីរិទ្ធ ជាដើម គឺជាព័ត៌មានពិតជាក់ស្តែង។

[១១:៣២:៤៧]

ហើយនៅក្នុងព័ត៌មានទាំងអស់នេះ អាចព័ត៌មានមួយចំនួនជួយដល់គាត់ទៀតផងក៏អាចថាបាន។ ពីព្រោះព័ត៌មានដែលយកមកនេះ គឺជាព័ត៌មានប្រវត្តិរូប អំពីជីវិតរបស់គាត់ គាត់ធ្លាប់រៀននៅសាលាធម្មសាត្រ គាត់ធ្លាប់រស់នៅលំបាកទេវនា គាត់មានបងប្អូនប៉ុន្មាននាក់ អីប៉ុន្មាននាក់អីចឹង។ អីចឹងព័ត៌មាននេះ គឺយើងមាន ហើយបើខ្ញុំចាំច្បាស់ គឺគាត់ទាំងប្រាំនាក់គឺមានឈ្មោះនៅក្នុងនេះដែរ ហើយយើងហៅថា "ប្រវិត្តរូបមេដឹកនាំខ្មែរក្រហម" បាទនៅក្នុងនុ៎ង។

**ស៖** ហើយខ្ញុំមិនសង្ស័យថា គឺថាលោកមិនឆ្លើយប្រាំទៀត។ បាទលោកបានឆ្លើយតែប្រាំ ថាតើប្រាំទៀតនោះអ្វីដែលបាទ?

**ឆ៖** ខ្ញុំគិតថា--

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធានខ្ញុំសូមអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ!

**លោក អាប់ឌុលឡាក់ ថារីក៖**

តុលាការជាទីគោរព គឺថាសូមជំទាស់ ដោយសារសំណួរនេះគឺមិនទាក់ទងទៅនឹងប្រធានបទព្រឹកនេះទេ។

[១១:៣៣:៤៤]

**លោក ហ្សាស្តើ ប៉ៅ៖**

លោកប្រធាន យើងខ្ញុំគ្រាន់តែចង់ដឹងថា វិធីរៀបចំការងារដូចម្តេច? ហើយការរៀបចំឯកសារដូចម្តេច? ការវិភាគដូចម្តេច? យើងនៅទីនេះដើម្បីរកឲ្យឃើញថាតើមជ្ឈមណ្ឌលឯកសារកម្ពុជាហ្នឹង គាត់បានរៀបចំឯកសារភស្តុតាងដូចម្តេច ទាក់ទងនឹងការវិភាគ? ជាពិសេសបើសិនជាលោកមិនអនុញ្ញាតឲ្យខ្ញុំនិយាយពីបញ្ហានេះ វាគួរឲ្យចម្លែក។ នេះជាសំណួរត្រង់ៗអំពីការងារ នីតិវិធីការងាររបស់ ឌី.ស៊ី.ខេម តែប៉ុណ្ណោះ គឺអនុលោមទៅតាមបុគ្គលម្នាក់ៗ ជាការងារ។ ហើយខ្ញុំមិនពិនិត្យឃើញថាហេតុអីបានជាសហព្រះរាជអាជ្ញាអាចនឹងជំទាស់បែបនេះបាននោះបាទ។

[១១:៣៤:២៣]

*(ចៅក្រមពិភាក្សាគ្នា)*

[១១:៣៥:០០]

**ប្រធានអង្គជំនុំ៖**

បាទជំទាស់របស់តំណាងសហព្រះរាជាអាជ្ញាអន្តរជាតិទៅនឹងសំណួរចុងក្រោយអម្បាញ់មិញនេះមានប្រសិទ្ធភាព។ សំណួរនេះមិនមានការពាក់ព័ន្ធនៅនឹងគោលបំណងនៃការសួរដេញដោលនាពេលនេះទេ។ ដូច្នេះ សាក្សីមិនបាច់ឆ្លើយតបទៅនឹងសំណួរអម្បាញ់មិញនេះទេ។

**លោក ហ្សាស្តើ ប៉ៅ៖**

សូមអរគុណលោកប្រធាន។ អ៊ីចឹង ខ្ញុំសូមផ្អាកសួរពាក់ព័ន្ធទៅនឹងការវិភាគភស្តុតាងដោយ ឌី.ស៊ី.ខេម នេះហើយ ឬក៏ថារបៀបរបបនៃ ឌី.ស៊ី.ខេម រៀបចំឯកសារដោយរបៀបណានោះ។

**សួរដោយលោក ហ្សាស្តើ ប៉ៅ៖**

**ស៖** អ៊ីចឹងខ្ញុំសុំចូលទៅប្រធានមួយផ្សេងទៀត ជាប្រធានបទពាក់ព័ន្ធទៅនឹងការបោះពុម្ពផ្សាយដោយ ឌី.ស៊ី.ខេម ដែលយើងអាចរកបាននៅលើគេហទំព័រ មានចំណងជើងថា "អ្វីដែល ឌី.ស៊ី.ខេម អ្វីមួយដែល ឌី.ស៊ី.ខេម រៀបចំ ដើម្បីជាកម្មវិធីចុះផ្សព្វផ្សាយពាក់ព័ន្ធទៅនឹងអំពើប្រល័យពូជសាសន៍ដែលប្រព្រឹត្តឡើងដោយមេដឹកនាំ ជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ ដែលត្រូវមកធ្វើការផ្តន្ទាទោសនៅក្នុងសំណុំរឿង០០២"។ អ៊ីចឹង ខ្ញុំសូមបង្ហាញ ឯកសារនេះនៅលើអេក្រង់កុំព្យូទ័រ។ ហើយបើយើងចូលទៅក្នុងទំព័រទីមួយ ពេលនោះយើងនឹងឃើញថា តើអ្នកនិពន្ធជាអ្នកណាហើយ អ្នកនិពន្ធនៃការបោះពុម្ពផ្សាយ

ឯកសារនេះ។ ពិបាកអានបន្តិច អក្សរតូចៗពេក។ ដូច្នេះអ្នកនិពន្ធយើងឃើញមាន ចាយ៉ា វ៉ាមជី នូហ្កាលិស ហើយហ្នឹង អេនទី-- ហើយនិង អាន ហេនឌល តើលោកអាចជម្រាបថា តើអ្នកទាំងនេះជាអ្នកណាទេ?

[១១:៣៦:៥៦]

**លោក ឆាំង យុះ**

**ឆ៖** បាទ ខ្ញុំស្រឡាញ់បោះពុម្ពនេះ ព្រោះខ្ញុំ*ឌីហ្សាញ* ខ្លួនឯងបាទ។ ចាយ៉ា វ៉ាមជី គឺជាទីប្រឹក្សាច្បាប់ម្នាក់ ដែលធ្វើការដោយស្ម័គ្រចិត្ត អាន ហេនឌល គឺជាអ្នកធ្វើការផ្នែកច្បាប់ដែលយើងជួលគាត់មកឲ្យមកធ្វើការនៅក្នុងស្រុកខ្មែរ ដើម្បីធ្វើការឆ្លើយតបទៅនឹងព័ត៌មាន សំណួរនានាដែលទាក់ទងទៅនឹង អ.វ.ត.ក។

**ស៖** សូមអរគុណ។ បើយើងចូលទៅទំព័រទីមួយនៃការបោះពុម្ពផ្សាយឯកសារនេះ យើងនឹងឃើញអារម្ភកថា។ នេះនិយាយពីឈ្មោះលោកតែម្តង។ ខ្ញុំសូមបង្ហាញកថាខណ្ឌទីមួយនៃទំព័រមុខ។ សូមបង្ហាញធ្វើម៉េចឲ្យអានបាន។ ហើយខ្ញុំសូមអានពីកថាខណ្ឌដែលលោកនិយាយអំពី នួន ជា, អៀង សារី, អៀង ធីរិទ្ធ និង ខៀវ សំផន។ លោកបានលើកឡើងថា មេដឹកនាំទាំងនេះមិនបានសារភាព ទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនៅក្នុងពេលនេះទេ ប៉ុន្តែបែរជាទម្លាក់កំហុសទៅលើកម្មាភិបាលថ្នាក់ទាបទៅវិញ។ ហេតុដូច្នេះឯង តុលាការនេះសំខាន់ណាស់ដែលត្រូវបង្ហាញឲ្យឃើញថា របបកម្ពុជាប្រជាធិបតេយ្យបានចេញនូវសេចក្តីសម្រេចចិត្តដែលនាំឲ្យមានការបាត់បង់ជីវិតប្រជាជន ជាង២លាននាក់។ នៅក្នុងកថាខណ្ឌទី២ លោកសរសេរថា មានព័ត៌មានយ៉ាងច្រើនដែលអាចតុលាការនេះយកមកប្រើប្រាស់ដើម្បីបង្ហាញឲ្យឃើញថា អ្នកដឹកនាំទាំងអស់នេះមានទោស។ អ៊ីចឹងថាតើសាក្សីណាខ្លះដែលត្រូវនិយាយដើម្បីមកបង្ហាញថា អ្នកដឹកនាំទាំងអស់នោះប្រព្រឹត្តអំពើអ្វីខ្លះនោះ? នៅពេលដែលខ្ញុំអានទាំងនេះ ហាក់បីដូចជាលោកបានបង្ហាញនូវចម្លើយថាតុលាការនេះនៅតែត្រូវចេញនូវសេចក្តីសម្រេចមួយថា តើមេដឹកនាំបានសម្រេចអ្វីដែលនាំឲ្យមានកើតអ្វីនៅក្នុងប្រទេស ហើយដែលត្រូវតែមានពិរុទ្ធភាព?

ដូច្នេះ បន្ទាប់ពីការវិភាគទៅលើភស្តុតាងនេះទៅ លោកនឹងយល់អំពីចំណុចនេះហើយ ថាតើចំណុចនេះវាយ៉ាងម៉េច?--

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន សូមជំទាស់ទៅនឹងចំណុចនេះ ដោយសារមេធាវីការពារក្តីបានត្រឡប់ទៅកាន់

គំនិតយោបល់ដែលសាក្សីបានផ្តល់មក ហើយដែលវាមិនមានការពាក់ព័ន្ធនោះទេ។ សូមឲ្យបន្តទៅសំណួរណាដែលពាក់ព័ន្ធ និងបន្តទៅមុខទៀត។

**លោក ហ្សាស្តេី ប៉ោះ**

ខ្ញុំសូមឆ្លើយតបសង្ខេប។ សំណួរនេះគឺថាវាចាក់ចំបេះដូងនៃបញ្ហានេះតែម្តង ដោយសារតែ លោក យុ ឆាំង នេះគឺថាគាត់ជាអ្នកដើរតួយ៉ាងសំខាន់នៅក្នុងការវិភាគទៅលើភស្តុតាង ទៅនិងការប្រមូលភស្តុតាងដែលពាក់ព័ន្ធនៅក្នុងសំណុំរឿងក្តីនេះ ដែលវាឈានទៅដល់ការផ្តន្ទាទោស លើកឡើងអំពីការផ្តន្ទាទោសនោះ។ គាត់សន្និដ្ឋានថា ជនជាប់ចោទមានពិរុទ្ធភាព។ ប៉ុន្មានសប្តាហ៍មុននេះ យើងមិនចង់ឲ្យគាត់លើកឡើងអំពីការបញ្ហាពិរុទ្ធភាពបញ្ហានេះទេ ហេតុដូច្នេះហើយបានជាយើងសួរគាត់ ដោយសារគាត់ពាក់ព័ន្ធទៅនឹងបញ្ហា នៃភាពលម្អៀង គឺថាជាទស្សនៈមួយដែលមានលក្ខណៈលម្អៀង ដែលថាមេដឹកនាំជាន់ខ្ពស់មានពិរុទ្ធភាព ហើយឯកសារភស្តុតាងនេះ គឺត្រូវបង្កើតឡើងដោយសារគាត់។ ដូច្នេះខ្ញុំព្យាយាមសួរទៅលោក ឆាំង យុ តែម្តងទៅលើគំនិតយោបល់ផ្ទាល់ខ្លួនរបស់គាត់ ថាតើវាច្បាស់ហើយថាដែលគាត់បានបញ្ចេញនូវទស្សនៈនេះ ក្នុងឋានៈគាត់ជាប្រធានមជ្ឈមណ្ឌលឯកសារកម្ពុជា។ ខ្ញុំចង់ឲ្យលោក យុ ឆាំង គាត់ចង់ពន្យល់អំពីពាក្យពេចន៍របស់គាត់ ព្រោះគាត់ជាអ្នកសរសេរអត្ថបទនេះតែម្តង។

*(ចៅក្រមពិភាក្សាគ្នា)*

[១១:៤១:៤៥]

**ប្រធានអង្គជំនុំ៖**

បាទ ការជំទាស់របស់ព្រះរាជអាជ្ញាអន្តរជាតិ មានមូលដ្ឋានសមរម្យ។ ដូច្នេះការជំទាស់នេះមានប្រសិទ្ធភាពសាក្សីមិនគប្បីឆ្លើយតបនឹងសំណួរ ដែលសួរចុងក្រោយនេះទេ។ ហើយបញ្ហាទាំងអស់នេះអង្គជំនុំជម្រះបានជម្រាបជូនលោកមេធាវីរួចហើយ កាលពីអំឡុងពេលដំណើរការសវនាការកាលពីថ្ងៃព្រហស្បតិ៍ ដោយចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍។

**លោក ហ្សាស្តេី ប៉ោះ**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ហ្សាស្តេី ប៉ោះ**

**ស៖** ខ្ញុំសូមបន្តចូលទៅប្រធានបទផ្សេងទៀត។ គឺប្រធានបទដូចខាងក្រោមនេះ។ អនុប្រធានរបស់លោក លោក ដារ៉ាពៅ គឺបានប្រាប់ថា មជ្ឈមណ្ឌលឯកសារកម្ពុជា គឺបានស្វែងរកព័ត៌មានដោយ

សេរីនៅទីណាក៏បានដែរនៅក្នុងប្រទេសកម្ពុជា។ លោកយល់ស្របជាមួយនឹងការលើកឡើងរបស់គាត់ទេ?

**ឆ៖** ខ្ញុំយល់ស្របក្នុងការលើកឡើងនេះ។ ប៉ុន្តែខ្ញុំបានប្រាប់កាលពីអាទិត្យមុនកន្លែងខ្លះក៏ជួបប្រទះការលំបាកដែរ ប៉ុន្តែយើងមានលិខិតអនុញ្ញាតពីរាជរដ្ឋាភិបាលកម្ពុជា យើងអាចចុះទៅកន្លែងណាក៏បាន ប៉ុន្តែនៅគ្រប់ស្ថាប័ននីមួយៗ របៀបរបបការងារខុសៗគ្នា ហើយយើងជួបបញ្ហាក្នុងការជ្រៀតចូលទៅសិក្សាស្រាវជ្រាវខុសៗគ្នា។

[១១:៤៣:៥៦]

**ស៖** លោក ដាវ៉ាំពៅ ក៏បាននិយាយអំពីបណ្ណសារដ្ឋាន នៃគណបក្សប្រជាជនកម្ពុជា។ ខ្ញុំមិនដឹងថាលោក គឺថាអាចធ្វើការសិក្សាស្រាវជ្រាវបានដោយសេរី ហើយលោកក៏ធ្លាប់បានទៅធ្វើការស្រាវជ្រាវនៅបណ្ណសារដ្ឋានរបស់គណបក្សប្រជាជនកម្ពុជាដែរ។ តើត្រឹមត្រូវទេ?

**លោក អាប់ឌុលឡាក់ ថាវីក៖**

ខ្ញុំសូមជំទាស់ គឺនេះគឺសម្រាប់តែបញ្ហានៃសារព័ត៌មាន ឬក៏អ្វីនោះមួយទេ ប៉ុន្តែឯកសារនៅចំពោះមុខអង្គជំនុំជម្រះនោះ គឺយើងត្រូវពាក់ព័ន្ធតែឯកសារជាក់លាក់នេះទេ ហើយវាពាក់ព័ន្ធតែទៅនឹងអ្វីដែលជាសំណើរបស់ក្រុម នួន ជា នូវបញ្ជីឯកសារដែលយើងបានបញ្ជាក់ហើយ យើងបានទទួលពីឯកសារនៃមជ្ឈមណ្ឌលឯកសារកម្ពុជាតែប៉ុណ្ណោះ។ ហើយការស្វែងរកទៅលើផ្នែកណាពាក់ព័ន្ធទៅលើការទទួលខុសត្រូវ ឬក៏ការសំអាងរបស់ ឌី.ស៊ី.ខេម ឬក៏វិធីសាស្ត្រសម្រាប់កត់ត្រានោះ គឺថាយើងមិនជំទាស់ទេ ក៏ប៉ុន្តែការសាកសួរ ថាតើ ឌី.ស៊ី.ខេម ទទួល-- គឺជាឯកសារដែលវាមិនពាក់ព័ន្ធនៅក្នុងបញ្ជីឯកសារយើងខ្ញុំផ្តល់ជូនសម្រាប់គោលបំណងនៃសវនាការនេះនោះទេ។ ដូច្នេះសូមជំទាស់។

[១១:៤៥:២៤]

**លោក ហ្សាស្តេ ប៉ោះ៖**

លោកប្រធាន ខ្ញុំគ្រាន់តែចង់និយាយថា គឺថាខ្ញុំត្រូវបានរំខានទៅដោយអន្តរាគមន៍របស់ខាងការិយាល័យសហព្រះរាជអាជ្ញា។ យើងនៅទីនេះ គឺយើងកំពុងតែដោះស្រាយពីវិធីរបៀបនៃការប្រមូលឯកសារភស្តុតាងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា។ ខ្ញុំមិននិយាយអំពីយោបល់ផ្ទាល់ខ្លួនរបស់លោក យុ ឆាំង ទេ។ ខ្ញុំសួរសំណួរងាយៗ ថាតើមជ្ឈមណ្ឌលឯកសារកម្ពុជានេះ ត្រូវបានអនុញ្ញាតឲ្យធ្វើការសិក្សាស្រាវជ្រាវនៅក្នុងបណ្ណសារដ្ឋាន របស់គណបក្សប្រជាជនកម្ពុជាដែរឬទេ? តាមដែលខ្ញុំដឹង គឺថា

ការិយាល័យសហព្រះរាជអាជ្ញាបានស្វែងរកបញ្ហានេះ ស្វែងរកព័ត៌មាននេះ ដែលខ្លួនចង់បង្កើតចេញ ចង់ដឹងថាតើ ឌី.ស៊ី.ខេម ទទួលបានយ៉ាងម៉េចៗ ហើយប្រតិបត្តិការនៃការប្រមូលឯកសារពីស្ថាប័នផ្សេងៗនេះ ដោយរបៀបណានោះ?

[១១:៤៦:៣២]

ដូច្នេះ ហេតុអ្វីបានជាមិនអនុញ្ញាតឲ្យខ្ញុំសួរថា ឯកសារដែលទទួលបានពីបណ្ណសារដ្ឋានជាតិ គាត់សួរបាន ពីក្រសួងមហាផ្ទៃ គាត់សួរបាន ឯខ្ញុំសាកសួរអំពីថាតើមជ្ឈមណ្ឌលឯកសារកម្ពុជាមានលទ្ធភាពចូលទៅសិក្សាស្រាវជ្រាវបណ្ណសារដ្ឋានរបស់គណបក្សប្រជាជនកម្ពុជាដែរឬក៏អត់?តែប៉ុណ្ណោះ ម៉េចក៏ទៅជាបានជំទាស់ទៅវិញនោះ។ ដូច្នេះ ខ្ញុំសូមឲ្យសាក្សីឆ្លើយតបទៅនឹងសំណួររបស់ខ្ញុំ បើសិនណាជាលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

កុំទាន់ឆ្លើយនឹងសំណួរនេះ សាក្សី។

[១១:៤៧:០៦]

*(ចៅក្រមពិភាក្សាគ្នា)*

[១១:៤៨:២៦]

**ប្រធានអង្គជំនុំ៖**

បាទ ការជំទាស់របស់តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ក្នុងការតាំងសំណួរចុងក្រោយអម្បាញ់មិញ របស់មេធាវីការពារក្តី នួន ជា គ្មានប្រសិទ្ធភាពទេ។

សាក្សីត្រូវឆ្លើយតបទៅនឹងសំណួរ ដែលសួរចុងក្រោយដោយមេធាវីការពារក្តី នួន ជា។

**លោក ឆាំង យុ៖**

**ឆ៖** សូមអរគុណលោកប្រធានចៅក្រម។ ខ្ញុំសប្បាយចិត្តនឹងសំណួរនេះ។ បាទ ពីព្រោះជាសំណួរដែលខ្ញុំចង់ឆ្លើយ ជាងសំណួរផ្សេងៗទៀត។ ទាំងអស់គ្នាយល់ច្រឡំ តាមពិតទៅនៅក្នុងឆ្នាំ ១៩៨៣ គណបក្សប្រជាជនមានបណ្ណសារដ្ឋានជាតិមួយ ឈ្មោះហៅថា "គណៈកម្មាធិការប្រវត្តិសាស្ត្របក្សប្រជាជនកម្ពុជា" ដែលសហការធ្វើឡើងជាមួយវៀតណាម ឡាវ ជាមួយគ្នាជាបីប្រទេស ហើយខ្ញុំបានស្រាវជ្រាវថា នៅក្នុងអង្គភាពនេះ បានទទួលការគ្រប់គ្រងអំពី លេនីន *អ៊ុនស្ទីទូត* មកពីប្រទេសសូវៀតទៀតផង។ ហើយក្រោយពីឆ្នាំ៩៣ បណ្ណសារដ្ឋាននេះ ត្រូវបានបិទលែងមានជារូបរាងទៀត

ហើយ ហើយខ្ញុំតាមទៅរកទៀត តាមខ្ញុំចាំលោក ជ័យ សុផន ឬក៏លោក ជ័យ សុភា ដែលជាប្រធានគណៈកម្មាធិការនេះ។ អ៊ីចឹង ខ្ញុំបានទៅជួបគាត់ ខ្ញុំបានទៅដល់វៀតណាមទៀត ខ្ញុំបានទៅដល់ឡាវទៀត ពីព្រោះខ្ញុំដឹងថា គណៈកម្មាធិការទាំងបីនេះធ្វើការជាមួយគ្នា ដើម្បីសរសេរប្រវត្តិបក្ស ហើយមានឯកសារនៅកន្លែងនេះ។ អ៊ីចឹងហើយ ដោយសារថាកន្លែងនេះ វាមិនមែនស្ថាប័នទៀត វាមិនមែនជារូបរាង ជាអគារទៀត ជាស្ថាប័នមួយទៀត។ អ៊ីចឹង ខ្ញុំក៏បានដាក់ព័ត៌មាននេះ នៅក្នុងវេបសាយ ដើម្បីឲ្យដឹងថាកន្លែងខ្លះ យើងទៅដល់ដែរ ប៉ុន្តែប្រហែលជាតុលាការមានលទ្ធភាពច្រើនជាងខ្ញុំ។ ក្នុងនីតិវិធីណាមួយ អាចទៅស្រាវជ្រាវឯកសារនៅកន្លែងនេះបាន។

[១១:៥០:០២]

អ៊ីចឹងខ្ញុំបានធ្លាប់ជួបទៅគណបក្សប្រជាជន ធ្លាប់ទៅជួបសួរឯកឧត្តម សាយ ឈុំ បាទអំពីបញ្ហានេះដែរ ហើយលោកបានប្រាប់ ហើយជាការពិតគឺស្ថាប័ននេះត្រូវបានបិទទ្វារហើយ លែងមានហើយគេហៅថា គណៈកម្មាធិការប្រវត្តិសាស្ត្របក្សប្រជាជនបដិវត្តន៍កម្ពុជា ហើយធ្វើឡើងជាមួយវៀតណាមឡាវ កម្ពុជា ហើយប្រទេសទាំងបីនេះ គឺថាបានផ្លាស់ប្តូរឯកសារគ្នា ដើម្បីសរសេរប្រវត្តិបក្សរួមគ្នា។ អ៊ីចឹងខ្ញុំដឹងអំពីឯកសារនេះ ហើយដោយសារថាឯកសារនេះវាលែងមានជាៗអាគារជាកន្លែងទៅសិក្សាស្រាវជ្រាវ ខ្ញុំបានទៅសួរជាបុគ្គលថា ឯកសារនេះនៅកន្លែងណា? នៅពេលដែលខ្ញុំសាកសួរទៅឯកសារទាំងអស់នេះវានៅអាវត់អាវាយ ខ្ញុំបានទៅសួរនៅវៀតណាមទៀត។

បាទ តាមដែលខ្ញុំដឹងវៀតណាម ហើយនិងឡាវ គេបានចេញជាសៀវភៅមួយនិយាយអំពីប្រវត្តិបក្សរបស់គេ ហើយដែលក្នុងនោះអត់មានខ្មែរយើងទេ ដោយសារខាងខ្មែរយើងត្រូវបានផ្លាស់ប្តូរគោលនយោបាយ ហើយឈានទៅរកការបោះឆ្នោតដោយសេរី និងយុត្តិធម៌ឆ្នាំ៩៣ ទៅវិញ។ អ៊ីចឹងកន្លែងនេះមាន ហើយខ្ញុំបានទៅរក ហើយខ្ញុំបានសាកសួរ ហើយខ្ញុំបានដាក់ព័ត៌មានហ្នឹងជាសាធារណៈទៀត សង្ឃឹមថាថ្ងៃណាមួយ តុលាការប្រហែលជាមានអាទិភាពនៅក្នុងផ្លូវច្បាប់អាចទៅរកឯកសារកន្លែងហ្នឹងបាន។ មូលហេតុហ្នឹងហើយ បានគាត់ក៏ដឹង ខាងនេះក៏ដឹងទាំងអស់គ្នាព្រោះខ្ញុំអ្នកប្រាប់ ហើយខ្ញុំអ្នកទៅរកខ្លួនឯងបាទ កន្លែងនេះ។

[១១:៥១:២៨]

**ស៖** អរគុណលោក ឆាំង យុ។ ខ្ញុំជឿថាលើ-- លោកនិយាយអម្បាញ់មិញញាប់បន្តិចសម្រាប់អ្នកបកប្រែ។ ខ្ញុំមិនមានកាតព្វកិច្ចអីដែលត្រូវឲ្យលោកនិយាយយឺតទេ។ ប៉ុន្តែខ្ញុំចង់ដឹងពីអ្វីៗដែលលោក

លើកឡើងនេះ។ ខ្ញុំសូមចាប់ផ្ដើមសួរសំណួរឡើងវិញដោយឲ្យៗងាយស្រួលទេ តើមានបានទៅការប្រមូលឯកសារពីបណ្ណសារដ្ឋានរបស់គណបក្សប្រជាជនកម្ពុជាដែរឬទេ ដែលលោកគិតថា ប្រើពាក្យថា ស៊ី.ភី.ភី *អាកខាយ* បណ្ណសារដ្ឋានគណបក្សប្រជាជនកម្ពុជា?

**ឆ៖** បណ្ណសារដ្ឋាននេះមានឈ្មោះថា "ប្រវត្តិសាស្ត្របក្សប្រជាជនបដិវត្តន៍កម្ពុជា" ដែលលែងមានជារូបរាងនៅក្នុងឆ្នាំ៩៣ ប៉ុន្តែខ្ញុំបានដឹងថាអង្គភាពនេះមានប្រមូលឯកសារសហការជាមួយវៀត-ណាម និងប្រទេសឡាវ ហើយខ្ញុំដឹងថា ប្រទេសវៀតណាម ឡាវ កម្ពុជានេះបានទទួលការគាំទ្រពីប្រទេសសូវៀតក្នុងការចងក្រងប្រវត្តិបក្សមួយរួមគ្នា។

[១១:៥២:៣៤]

អ៊ីចឹងខ្ញុំបានទៅរក ខ្ញុំបានទៅសួរគណបក្សប្រជាជនថា ឯកសារនេះនៅកន្លែងណា ខ្ញុំបានទៅជួបឯកឧត្ដម សាយ ឈុំ ខ្ញុំបានទៅជួបលោក ជ័យ សុផុន តាមដែលខ្ញុំច្បាស់ ជ័យ សុផុន ដែលជាប្រធានប្រវត្តិសាស្ត្របក្សក្រុមមួយនីស្ត-- ប្រវត្តិសាស្ត្រគណបក្សប្រជាជននេះ នៅពេលដែលខ្ញុំទៅសួរគាត់ស្ថាប័ននេះ វាលែងមានជារូបរាង ហើយឯកសារមិនដឹងជានៅកន្លែងណាទៀតទេ។ អ៊ីចឹងខ្ញុំមិនអស់ចិត្តខ្ញុំទៅវៀតណាមទៀត ព្រោះខ្ញុំគិតថាប្រទេសទាំងបីនេះ បានផ្លាស់ប្ដូរឯកសារគ្នា អ៊ីចឹងច្បាស់ជាមានឯកសារខ្មែរនៅវៀតណាម មានឯកសារវៀតណាមនៅប្រទេសឡាវ ឯកសារឡាវច្បាស់ជានៅវៀតណាម។ អ៊ីចឹងខ្ញុំបានទៅដល់ទីនោះៗ ខ្ញុំក៏អត់មានបានរកឃើញឯកសារនេះទៀត ប៉ុន្តែខ្ញុំបានដឹងថាប្រទេសវៀតណាម និងប្រទេសឡាវ គេបានបោះពុម្ពឯកសារប្រវត្តិបក្សរួមគ្នាមួយលើកលែងតែស្រុកខ្មែរយើង។

[១១:៥៣:១៨]

ដោយសារស្រុកខ្មែរយើងបានសម្រេចយកគោលនយោបាយផ្សេង ឲ្យមានអង្គការសហប្រជាជាតិចូលមករៀបចំការបោះឆ្នោត អ៊ីចឹងស្ថាប័នមួយនេះគឺបាត់សូន្យឈឹង អត់មានរូបរាងទៀតទេ។ ហើយខ្ញុំមិនអស់ចិត្តទៀត មូលហេតុហ្នឹងហើយបានខ្ញុំគិតថា ច្បាស់ជាមាននៅកន្លែងណាមួយហើយ មូលហេតុហ្នឹងហើយខ្ញុំក៏ដាក់ព័ត៌មានជាសាធារណៈ សង្ឃឹមថា ថ្ងៃណាមួយនៅពេលដែលយើងមានតុលាការប្រហែលជាតុលាការមានលទ្ធភាពខ្ពស់ជាងខ្ញុំ មានអំណាចច្រើនជាងខ្ញុំ មានវិធីច្រើនជាងខ្ញុំអាចទៅរកឯកសារនេះដើម្បីជួយបំភ្លឺថាមានរឿងរ៉ាវអ្វីខ្លះដែលបានកើតឡើងកាលពីសម័យនោះ។ មូលហេតុហ្នឹងហើយ បានលោកក្ដី លោកខាងណេះក្ដី ទាំងអស់គ្នាដឹង គឺខ្ញុំជាអ្នកប្រាប់ ពីព្រោះខ្ញុំជាអ្នក

តាមរកឯកសារនេះ បាទ។

[១១:៥៤:០៨]

**ស៖** សូមអរគុណលោក ឆាំង យុ បើសិនជាខ្ញុំយល់លោកមិនច្រឡំទេ គឺបណ្ណសារដ្ឋានដើម របស់គណបក្សប្រជាជនកម្ពុជា គឺបិទនៅឆ្នាំ១៩៩៣ តាមដែលលោកដឹងថាតើគណបក្សប្រជាជនកម្ពុជា នៅតែមានឯកសារទាក់ទងទៅនឹងសម័យកម្ពុជាប្រជាធិបតេយ្យដែល គណបក្សប្រជាជនកម្ពុជាកំពុង តែកាន់កាប់ដែរឬទេ?

**ឆ៖** លោកចង់ថា សព្វថ្ងៃនេះ?

**ស៖** បាទ ជាការពិតហើយ ខ្ញុំនិយាយពីថ្ងៃនេះតែម្តង គឺពេលនេះតែម្តង ថាតើគណបក្សប្រជា ជនកម្ពុជានៅតែមានឯកសាររបស់កម្ពុជាប្រជាជាធិបតេយ្យដែរឬទេ?

[១១:៥៤:៥២]

**ឆ៖** នៅពេលដែលមានតុលាការកើតឡើងនៅក្នុងឆ្នាំ២០០៥ ខ្ញុំបានធ្វើសេចក្តីប្រកាសធំមួយ ទៅមនុស្សទាំងអស់ទូទាំងពិភពលោក ឥឡូវយើងមានតុលាការហើយ សូមមេត្តាប្រគល់ឯកសារមកឲ្យ តុលាការកុំឲ្យមកខ្ញុំ។ បាទ ខ្ញុំបានធ្វើសេចក្តីប្រកាសនេះជាភាសាខ្មែរ ជាភាសាបារាំង ជាភាសា អង់គ្លេស *ផុស្តិ៍* នៅវេបសាយផ្ញើទៅគ្រប់ស្ថានទូតទាំងអស់រួមទាំងរាជរដ្ឋាភិបាលទៀតផង។ ពីព្រោះ ខ្ញុំគិតថា ពេលដែលមានតុលាការហើយ លែងជាតួនាទីសំខាន់របស់ខ្ញុំហើយ គឺតុលាការគួរតែជាអ្នក ទីមួយ ដែលរកឃើញឯកសារទាំងអស់នេះ។

អ៊ីចឹង ក្រោយមកពីឆ្នាំ២០០៥ ខ្ញុំបានធ្វើសេចក្តីប្រកាសនេះផ្សព្វផ្សាយតាមកាសែតរស្មីកម្ពុជា តាមអ៊ីម៉ែល តាមសំបុត្រផ្ញើទៅគ្រប់អង្គទូតទាំងអស់ទូទាំងប្រទេស។ អ៊ីចឹងត្រង់ថាមាន មិនមាន ខ្ញុំគិត ថា នេះជាតួនាទីរបស់តុលាការ គួរតែធ្វើចុះស្រាវជ្រាវខ្លួនឯង រកឯកសារបន្ថែមទៀត ពីអ្វីដែលយើង បានផ្តល់ឲ្យ ហើយយើងក៏មិនដែលអះអាងថា យើងមានឯកសារមួយរយភាគរយដែរ។

មូលហេតុហ្នឹងហើយបានយើង ហើយយើងគិតថា មិនឯកសារនៅកន្លែងផ្សេងទៀត ច្បាស់ជា មានមនុស្សណាមួយ អ្នកណាមួយនៅមានឯកសារផ្សេងទៀត។ មូលហេតុហ្នឹងហើយ យើងក៏បានធ្វើ អស់ពីលទ្ធភាពដែលយើងធ្វើបាន ប្រមូលបានជិត១លានហ្នឹង មិនមែនច្រើនទេ។ ខ្ញុំជឿថានៅមានច្រើន ទៀត។ អ៊ីចឹងហើយបានជាខ្ញុំធ្វើសេចក្តីប្រកាសនេះ ទុកនាទីនេះឲ្យតុលាការជាអ្នកធ្វើដោយខ្លួនឯង។ ត្រង់ថាតុលាការធ្វើមិនធ្វើ អាហ្នឹងមិនមែនជារឿងរបស់ខ្ញុំទេ។ ហើយមួយទៀត ខ្ញុំមិនដែលគិតថា ខ្លួន

ឯងជាតុលាការផង។

[១១:៥៦:០៩]

អ៊ីចឹងខ្ញុំគិតថា តុលាការអាចមានអំណាចច្រើនជាងខ្ញុំ ក្នុងការជ្រៀតចូលទៅរកឯកសារផ្សេងៗ ដែលខ្លួនចង់បាន។ អ៊ីចឹងខ្ញុំមានតួនាទីត្រឹមតែប្រាប់ទីតាំងកន្លែង--

**ស៖** យុ ឆាំង ខ្ញុំសូមរំខានលោក ដោយសារខ្ញុំមើលទៅម៉ោងជិតអស់របស់ខ្ញុំ។ ជាចម្លើយមួយវែង ប៉ុន្តែមិនឆ្លើយចំទៅនឹងសំណួរខ្ញុំទេ។ តើលោកដឹងថា គណបក្សប្រជាជនកម្ពុជាឥឡូវនេះ នៅតែមានឯកសារដែលពាក់ព័ន្ធទៅនឹងសម័យកម្ពុជាប្រជាធិបតេយ្យដែរឬទេ? សូមឲ្យឆ្លើយគ្រាន់តែថា ទេ ឬក៏បាទ ប៉ុណ្ណឹងទៅបានហើយ។

**ឆ៖** ប៉ុន្តែសំណួររបស់លោកមិនអាចឆ្លើយ ទេ ឬក៏បាទ ព្រោះលោកនិយាយអំពីឯកសារដែលពាក់ព័ន្ធ។ អាមួយឯកសារសម័យខ្មែរក្រហម អាមួយឯកសារពាក់ព័ន្ធអំពីរបបកម្ពុជាប្រជាធិបតេយ្យ។ បើលោកចង់និយាយអំពីឯកសារពាក់ព័ន្ធនេះមានរាល់ថ្ងៃ បាទរដ្ឋាភិបាលនិយាយរាល់ថ្ងៃដែលពាក់ព័ន្ធរឿងខ្មែរក្រហមមានរាល់ថ្ងៃ។ អ៊ីចឹងខ្ញុំគិតថា អាហ្នឹងគឺមានដែរ។ ប៉ុន្តែបើនិយាយអំពីឯកសារខ្មែរក្រហមតែម្តង អាហ្នឹងខ្ញុំមិនដឹងទេ។

[១១:៥៧:១០]

**ស៖** ខ្ញុំរៀបសំណួរខ្ញុំឡើងវិញ ដើម្បីឲ្យឈានទៅដល់ការឆ្លើយថា មានឬក៏មិនមាន។ តើលោកដឹងថា គណបក្សប្រជាជនកម្ពុជានៅតែមានឯកសារដែលគេបានបង្កើតនៅចន្លោះពីឆ្នាំ១៩៧៥ ដល់៧៩ គឺសម័យកម្ពុជាប្រជាធិបតេយ្យនេះតែម្តង?

**ឆ៖** ខ្ញុំថា បើសិនជាមានក៏នៅក្នុងលក្ខណៈបុគ្គល ពីព្រោះស្ថាប័នវាបិទទៅហើយ។

**ស៖** (គ្មានការបកប្រែ)

**ឆ៖** ខ្ញុំគិតថា ១ជាបុគ្គល សមាជិករាជរដ្ឋាភិបាល ឬគណបក្សប្រជាជនអាចមានឯកសារជាបុគ្គល បាទជាបុគ្គល។ ប៉ុន្តែបើនិយាយអំពីគណបក្សទាំងមូល ស្ថាប័នដែលគ្រប់គ្រងឯកសារទាំងអស់នោះ គឺបានបិទហើយ តាំងពីឆ្នាំ៨៣ គឺជាបណ្ណសារដ្ឋានជាតិ ប្រវត្តិបក្ស គណបក្សប្រជាជនបដិវត្តន៍កម្ពុជាបិទទៅហើយ។ តែជាបុគ្គលខ្ញុំគិតថានៅមាន។ ពីព្រោះមានបុគ្គលក៏បានឲ្យខ្ញុំដែរ។

**ស៖** សូមអរគុណលោក។ ចម្លើយនេះជាចម្លើយមួយច្បាស់លាស់មែនទែន។ ទាក់ទងទៅនឹងលោក ខៀវ កាញ៉ារិទ្ធិ គាត់បានលើកឡើងច្រើនដងហើយ ថាមានអ្នកដែលផ្តល់ឯកសារមកជាច្រើន។

សំណួររបស់ខ្ញុំ ថាតើលោក ខៀវ កាញ៉ារិទ្ធិ មានបានផ្តល់ឯកសារដើមក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ដែលគាត់ជាអ្នកកាន់កាប់នោះ មានបានផ្តល់មកដែរឬទេ? លោកដឹង ឬក៏មិនដឹង?

[១១:៥៩:១៩]

**ឆ៖** ខ្ញុំដឹងរឿងនេះបាទ។

**ស៖** (គ្មានការបកប្រែ)

**ឆ៖** ខ្ញុំព្យាយាមឆ្លើយខ្លី ឥឡូវលោកឲ្យខ្ញុំឆ្លើយវែង។ អ៊ីចឹងបានខ្ញុំជូនវែងទៅវិញបាទ។ ខ្ញុំដឹងថា ឯកសាររបស់លោក ប៉ែន យៀរនិន ដែលនិយាយអំពីគណៈមជ្ឈិមបក្សនៃបក្សកុម្មុយនីស្តកម្ពុជា លោកបានទទួលមកពីលោក ខៀវ កាញ៉ារិទ្ធិ។ អ៊ីចឹងខ្ញុំមិនអស់ចិត្ត ខ្ញុំបានទៅសួរលោក ខៀវ កាញ៉ារិទ្ធិ ថា ឯកសារដើមនៅកន្លែងណា។ ពីព្រោះលោក ប៉ែន យៀរនិន បានប្រាប់ថា លោកជាអ្នកប្រគល់ឲ្យ។ អ៊ីចឹងខ្ញុំបានទៅសួរលោក ខៀវ កាញ៉ារិទ្ធិ សរសេរជាលាយលក្ខណ៍អក្សរទៀត។ និយាយឲ្យខ្លីទៅរឿងរ៉ាវទាំងអស់នេះខ្ញុំបានប្រាប់ទៅ អូ.ស៊ី.អាយ.ជេ រួចហើយ បើសិនជាលោកមើលប្រតិចារឹកហ្នឹងគឺមានហើយស្រេច។ ខ្ញុំបានសួរទៅលោក ខៀវ កាញ៉ារិទ្ធិ ថា ឯកសារនៅកន្លែងណា។ ប៉ុន្តែគាត់ក៏មានការភ្លេចភ្លាំង គាត់ថាគាត់មិនចាំ ប៉ុន្តែគាត់ច្បាស់ណាស់ ថាគាត់បានឲ្យទៅលោក ប៉ែន យៀរនិន។

[១២:០០:០០]

ប៉ុន្តែលោក ប៉ែន យៀរនិន ប្រាប់ថា គាត់អត់បានឯកសារដើមទេ។ អ៊ីចឹង វាយើងស្ថិតក្នុងស្ថានភាពនេះឯង ថាមិនដឹងជាអ្នកណាមានឯកសារដើម? ហើយទាំងពីរនាក់នេះ គឺធ្លាប់ធ្វើការសហការជាមួយគ្នាពីមុនមក។ អ៊ីចឹង ខ្ញុំបានសួរទាំងពីរនាក់ ហើយមានខ្ញុំដើម្បីចៀសវាងភាពមន្ទិលសង្ស័យ ខ្ញុំបានសួរគាត់ជាលាយលក្ខណ៍អក្សរ ហើយខ្ញុំបានទុកឯកសារទាំងអស់ទុកជាសំអាងថាខ្ញុំបានសួរ។ អ៊ីចឹងខ្ញុំបានសួរទៅគាត់ អានេះវាទាក់ទងទៅនឹងឯកសារកំណត់ប្រជុំគណៈអចិន្ត្រៃយ៍ បាទ។

**ស៖** តាមលោកដឹង តើលោក ខៀវ កាញ៉ារិទ្ធិ មានបានផ្តល់ឯកសារដើមមកឲ្យលោកទេ? គឺឯកសារដើមដែលស្ថិតនៅក្នុងដៃរបស់គាត់នោះ?

**ឆ៖** មកខ្ញុំ? លោកចង់សួរថា--

**ស៖** មកឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជា លោក?

**ឆ៖** បាទ។

[១២:០១:១០]

**ស៖** ជាចម្លើយមួយខ្លី ខ្ញុំពេញចិត្ត ប៉ុន្តែមិនច្បាស់ថាតើចម្លើយនេះ-- ឥឡូវខ្ញុំសួរសំណួរ ថាតើលោកដឹងថា លោក ខៀវ កាញ៉ារិទ្ធិ គឺពេលនេះឯង ថ្ងៃនេះឯង នៅតែមានឯកសារដើម ដែលបង្កើតនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យដែល ឌី.ស៊ី.ខេម មិនមានឯកសារដើមនេះនោះដែរឬទេ?

**ឆ៖** ខ្ញុំមិនដឹងដែរ បាទ ទាល់តែសួរគាត់។ ហើយខ្ញុំសួរគាត់ហើយ គាត់ថាឲ្យទៅលោក ប៉ែន យៀរនិន អស់ហើយ។ អ៊ីចឹងខ្ញុំយកសម្ដីគាត់។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណច្រើនមេធាវី ហើយសាក្សី។ ឥឡូវនេះដល់ពេលសមល្មមនឹងសម្រាកពិសាអាហារថ្ងៃត្រង់ហើយ។ អង្គជំនុំជម្រះប្រកាសសម្រាកដើម្បីពិសាអាហារថ្ងៃត្រង់ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយ និងសាមសិបនាទីរសៀលនេះ ដើម្បីអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការដេញដោលសាក្សី ឆាំង យុ តទៅទៀត។

ហើយនៅក្នុងអំឡុងពេលនេះ ពេលឈប់សម្រាកសុំមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកសមរម្យសម្រាប់សាក្សីរូបនេះផង ហើយនិងសូមឲ្យអញ្ជើញគាត់ មកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះឲ្យបានមុនពេលអង្គជំនុំជម្រះចូលមកកាន់អាសនៈ។ សូមអញ្ជើញលោកមេធាវី!

[១២:០២:៤០]

**មេលោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន។ នៅក្នុងដៃរបស់ខ្ញុំ គឺទាក់ទងលិខិតរបស់កូនក្ដីខ្ញុំទាក់ទងទៅនឹងគាត់សុំស្នើសុំទៅក្នុងបន្ទប់តាមដានសវនាការខាងក្រោម។

**ប្រធានអង្គជំនុំ៖**

បាទ បានស្ដាប់សំណើសុំរបស់មេធាវីការពារក្ដី នួន ជា ដែលបានស្នើសុំឲ្យកូនក្ដីរបស់ខ្លួនទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ តាមរយៈប្រព័ន្ធសោតទស្សន៍នៅបន្ទប់ខាងក្រោមនៃបន្ទប់សវនាការនេះ ដែលបានរៀបចំរួចហើយសម្រាប់សវនាការពីចម្ងាយ ហើយដោយលះបង់សិទ្ធិមិនចូលរួមកិច្ចដំណើរការសវនាការផ្ទាល់នៅក្នុងបន្ទប់សវនាការនេះ នៅក្នុងអំឡុងពេលរសៀលថ្ងៃនេះ។

អង្គជំនុំជម្រះយល់ព្រមតាមសំណើសុំរបស់គាត់។ ហើយដោយតម្រូវឲ្យមេធាវីការពារក្ដីលោក នួន ជា ប្រគល់មកអង្គជំនុំជម្រះភ្លាមៗនូវលិខិតលះបង់សិទ្ធិក្នុងការចូលរួមដោយផ្ទាល់ក្នុងបន្ទប់សវនាការ

ដោយចុះហត្ថលេខា ឬក៏ផ្តិតស្រាមមេដៃជាក់ច្បាស់ពីជនជាប់ចោទ នួន ជា។ ហើយបង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់នូវប្រព័ន្ធសោតទស្សន៍ សំឡេង រូបភាព សម្រាប់ជនជាប់ចោទរូបនេះតាមដានកិច្ចដំណើរការសវនាការពីចម្ងាយនៅក្នុងអំឡុងពេលធ្វើសវនាការនៅរសៀលនេះ។

[១២:០៤:១២]

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប នួន ជា និង ខៀវ សំផន ទៅកាន់បន្ទប់ខាងក្រោមនៃបន្ទប់សវនាការនេះ។ ហើយឡែកនៅរសៀលនេះ សុំបង្គាប់ឲ្យនាំខ្លួនជនជាប់ចោទ ខៀវ សំផន មកកាន់សាលសវនាការឲ្យបានមុខម៉ោងមួយសាមសិបនាទី។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១២:០៤នាទី ដល់ម៉ោង ១៣:៣៥នាទី)*

[១៣:៣៥:៥៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការសវនាការពិភាក្សាដេញដោលលើសាក្សី។ ជាបន្តអង្គជំនុំជម្រះសូមផ្តល់វេទិកាទៅក្រុមមេធាវីការពារក្តី នួន ជា ដើម្បីមានឱកាសក្នុងការតាំងសំណួរចំពោះសាក្សីរូបនេះ។ ហើយក្រុមមេធាវី គឺមានពេលវេលាមួយម៉ោងម្ភៃនាទីចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងបីខ្វះម្ភៃនាទី។ សូមជ្រាប។

សូមអញ្ជើញ!

**សួរដោយលោក ហ្សាស្តេ ប៉ោ៖**

សូមអរគុណលោកប្រធាន។ លោក ឆាំង យុ ខ្ញុំនឹងរៀបចំសំណួររបស់ខ្ញុំទៅតាមពេលវេលាដែលបានអនុញ្ញាត ហើយខ្ញុំជូនឱកាសទៅលោក សុន អរុណ ដែលជាសហមេធាវីជាតិការពារក្តីរបស់ នួន ជា។

**ស៖** ខ្ញុំសូមចាប់ផ្តើមសួរលោក ឆាំង យុ ទៅនឹងអត្ថបទសិក្សាស្រាវជ្រាវ ដែលធ្វើឡើងដោយលោក ស្ទីវ ហេដឌ័រ និយាយអំពីតួនាទីរបស់មន្ត្រីជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងមន្ត្រីមូលដ្ឋាន គឺលេខ ERN 001455 រហូត 00661461។ ខ្ញុំសូមបង្ហាញឯកសារនោះលើអេក្រង់កុំព្យូទ័រ។

[១៣:៣៧:៥១]

នេះគឺជាទំព័រមុខ ទំព័រទីមួយ បើសិនណាយើងចុះមកខាងក្រោម មកទំព័រ៣៦ ហើយយើងមើល ជើងទំព័រ២០៧ និង២០៨ នៃអត្ថបទនេះ។ បាទយើងឃើញហើយ គឺនេះគឺជាលេខជើងទំព័រនិយាយអំពី ភស្តុតាងដទៃទៀតដែលជាប់ពាក់ព័ន្ធទៅនឹងលោក ហេង សំរិន ហើយនិងកងទ័ពក្នុងពេលដែលឆ្លងកាត់ ទៅវៀតណាមនៅក្នុងឆ្នាំ១៩៧៩។ ហើយជើងទំព័រ២០៨ គឺ ជា ស៊ីម ត្រូវបានចោទប្រកាន់ពីការទទួល ខុសត្រូវទៅការសម្លាប់មនុស្ស ប្រជាជនថ្មី និងអ្នកដទៃទៀតក្នុងស្រុកពញាក្រែកនៅភូមិភាគបូព៌ា។ ហើយខាងក្រោមមកទៀតយើងឃើញថា មានអ្នកផ្តល់ព័ត៌មានថា មានប្រជាជនរាប់ពាន់អ្នកស្លាប់នៅ ក្នុងស្រុកនៅពេលដែលលោក ជា ស៊ីម គឺជាលេខាធិការស្រុកនេះនៅចុងឆ្នាំ១៩៧៧ និងដើមឆ្នាំ១៩៧៨។ នេះគឺជាអត្ថបទរបស់លោក ស្ទីវ ហេដឌ័រ យើងបាននិយាយច្រើនណាស់ហើយ ពាក់ព័ន្ធទៅនឹងឯកសារ របស់គាត់នេះ។ ហើយដែលគាត់ត្រូវបានគេចាត់ទុកថាជាអ្នកជំនាញក្នុងការស្រាវជ្រាវឯកសារសម័យ កម្ពុជាប្រជាធិបតេយ្យ។

តើ ឌី.ស៊ី.ខេម អនុញ្ញាតឲ្យចូលទៅមើលបណ្ណសាររដ្ឋាភិបាលទាក់ទងទៅនឹងការចោទប្រកាន់ របស់លោក ហេដឌ័រ ដែលយោងនៅលើលេខជើងទំព័រទាំងពីរនេះដែរឬទេ?

[១៣:៣៩:៤០]

**ប្រធានអង្គជំនុំ៖**

បាទ-- សាក្សីកុំអាលឆ្លើយ។

*(ចៅក្រមពិភាក្សាគ្នា)*

អង្គជំនុំជម្រះសម្រេចមិនឲ្យសាក្សីឆ្លើយតបនឹងសំណួរនេះទេ ព្រោះសំណួរនេះមិនពាក់ព័ន្ធទៅ នឹងកិច្ចដំណើរការសវនាការនៃរឿងក្តីនេះទេ។

**លោក ហ្សាស្តើ ប៉ោ៖**

បាទ សូមអរគុណលោកប្រធាន។ គម្រោងជំរុញឲ្យមានការទទួលខុសត្រូវដែលយើងនិយាយ ច្រើនមកហើយ គឺបានធ្វើការសិក្សាស្រាវជ្រាវនៅទូទាំងប្រទេសកម្ពុជា។

**សួរដោយលោក ហ្សាស្តើ ប៉ោ៖**

**ស៖** ហើយសំណួររបស់ខ្ញុំនោះ តាមដែលលោកដឹងនោះ តើគម្រោងជំរុញឲ្យមានការទទួល ខុសត្រូវបានធ្វើការសម្ភាសនៅក្នុងស្រុកពញាក្រែក ដែលជាស្រុកមួយដែលយោងតាមលេខជើងទំព័រ

នេះគឺមានឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្តឡើង គឺថាលោក ជា ស៊ីម ត្រូវបានចោទប្រកាន់ថា ប្រព្រឹត្តបទល្មើសនៅក្នុងស្រុកមួយនេះ។ តើមជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើការសិក្សាស្រាវជ្រាវទៅលើការចោទប្រកាន់បទល្មើសទាំងនេះដែរឬទេ?--

[១៣:៤១:១០]

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធានសូមជំទាស់ចំពោះការសាកសួរនេះ គឺថាខ្ញុំសូមឲ្យសាកសួរទៅសំណួរផ្សេង។

**លោក ហ្សាស្តើ ប៉ោ៖**

លោកប្រធានខ្ញុំសូមឆ្លើយតប ខ្ញុំគិតថាសំណួរនេះគឺដែលសហព្រះរាជអាជ្ញា គាត់បានលើកឡើងគឺខ្ញុំចង់បញ្ជាក់ថា វាជាបញ្ហាមួយសំខាន់។ មានហេតុផលបី ហេតុអីបានជាខ្ញុំសួរយ៉ាងនេះ។

គឺទីមួយ យើងព្យាយាមចង់ស្វែងរកឲ្យដឹងថា តើ ឌី.ស៊ី.ខេម មានដំណើរការសិក្សាស្រាវជ្រាវចងក្រងឯកសារទៅរឿងនេះទេ? តើខ្លួនបានបង្ហាញទៅដល់សាធារណជន ឬក៏បង្ហាញមកដល់ការិយាល័យសហព្រះរាជអាជ្ញានូវនៅគ្រប់ព័ត៌មានទាំងអស់នោះទេ? ហើយថាតើវាសំខាន់សម្រាប់សហព្រះរាជអាជ្ញាដែរទេ ដែលថានេះវាជាភស្តុតាងដោះបន្ទុកសម្រាប់កូនក្តីរបស់យើងខ្ញុំ?

ហើយទីពីរ ខ្ញុំនឹងលើកឡើងចំៗតែម្តងគឺថ្ងៃនេះយើងចង់ស្វែងរកឲ្យឃើញថា តើរដ្ឋាភិបាលបានជ្រែកជ្រៀតចូលមកដល់កិច្ចការរបស់ ឌី.ស៊ី.ខេម ដែរឬក៏យ៉ាងណាទាក់ទងទៅនឹងតថភាពពិតនៅក្នុងសង្គមកម្ពុជាពីមួយថ្ងៃទៅមួយថ្ងៃ?

ហើយដោយសារថា រាជរដ្ឋាភិបាលកម្ពុជាគឺមិនទាន់ដកខ្លួនចេញពីការជ្រៀតជ្រែកចូលមកក្នុងកិច្ចដំណើរការរបស់តុលាការនេះនៅឡើយទេ។ ហើយដូចដែលសហព្រះរាជអាជ្ញាអន្តរជាតិ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានលើកឡើង។ ហើយវាជារឿងមួយគួរឲ្យចម្លែកណាស់ បើថារដ្ឋាភិបាលមិនដកខ្លួនចេញពីនេះទេ ហើយអង្គការក្រៅរដ្ឋាភិបាលកម្ពុជា គឺថាធ្វើការសិក្សាស្រាវជ្រាវទៅលើប្រវត្តិនៃកម្ពុជាប្រជាធិបតេយ្យ--

[១៣:៤២:៥៨]

**ប្រធានអង្គជំនុំ៖**

លោកមេធាវី លោក-- ឱកាសនេះ គឺអង្គជំនុំជម្រះផ្តល់វេទិកាឲ្យលោកតាំងសំណួរជាក់លាក់ពាក់ព័ន្ធទៅនឹងវិធីសាស្ត្រនៃការទទួលឯកសារ រៀបចំឯកសារកាតាឡុក គ្រប់គ្រងឯកសារ ឬប្រភេទ

ឯកសារជាក់លាក់មួយចំនួនទៀត។ អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យលោកធ្វើសេចក្តីថ្លែងការណ៍អ្វីផ្សេងទៀតឡើយ។ ប្រសិនបើលោកអស់សំណួរយើងនឹងបញ្ចប់ការសួរដេញដោលរបស់លោកចំពោះសាក្សីរូបនេះ។ ដោយឡែកសំណួរអម្បាញ់មិញនេះការជំទាស់របស់សហព្រះរាជអាជ្ញាមានប្រសិទ្ធភាព។ ដូច្នេះសាក្សីមិនចាំបាច់ឆ្លើយនឹងសំណួរចុងក្រោយដែលក្រៅអង្គហេតុនេះទេ។ ប្រសិនបើលោកព្យាយាមក្នុងការសួររបៀបនេះទៀតនោះ គឺអង្គជំនុំជម្រះនឹងមិនអនុញ្ញាតឲ្យលោកដាក់ឯកសារនេះដេញដោលទៀតទេ។ សូមលោកតម្រង់ទិសទៅតាមគម្រោងផែនការដែលអង្គជំនុំជម្រះបានកំណត់ទុកអំពីកម្មវត្ថុឬក៏បញ្ហាដែលភាគីត្រូវមានសិទ្ធិនៅក្នុងការសួរដេញដោលចំពោះសាក្សីរូបនេះ។

[១៣:៤៤:០៩]

រំឭកឡើងវិញពាក់ព័ន្ធទៅនឹងវិធីសាស្ត្រនៃការទទួលឯកសារ ការរៀបចំឯកសារជាកាតាឡុក ការគ្រប់គ្រងឯកសារ ឬ/និង ប្រភេទឯកសារជាក់លាក់មួយចំនួនផ្សេងទៀត។

ទីពីរ នៅក្នុងការកំណត់កាលបរិច្ឆេទនៃការដេញដោលចំពោះសាក្សី គឺមិនមានការសួរដេញដោលលើឯកសារជាក់លាក់នីមួយៗឡើយ។ ឯកសារនីមួយៗអាចត្រូវបានយកមកបង្ហាញ ឬយោងទៅលើ ប្រសិនបើចាំបាច់សម្រាប់គោលបំណងបង្ហាញ បញ្ជាក់ពីភាពពាក់ព័ន្ធជាបញ្ហាទូទៅណាមួយតែប៉ុណ្ណោះ។ ការជំទាស់ដេញដោលលើឯកសារជាក់លាក់នីមួយៗនឹងធ្វើឡើងនៅពេលក្រោយ។ អង្គជំនុំជម្រះដូចជារំឭកលោកច្រើនលើកច្រើនសាហើយ។

[១៣:៤៥:០៨]

**លោក ហ្សាស្តេ ប៉ោះ**

សូមអរគុណលោកប្រធាន ខ្ញុំនឹងងាកចេញអំពីភស្តុតាងនេះ ដែលពាក់ព័ន្ធទៅដល់មន្ត្រីជាន់ខ្ពស់ក្នុងរដ្ឋាភិបាលសព្វថ្ងៃ។ ហើយខ្ញុំសូមចូលទៅប្រធានបទមួយផ្សេង គឺលោក ស៊ីវ ហេងឆ័រ នៅក្នុងអត្ថបទរបស់គាត់ បានរៀបចំនូវទ្រឹស្តី ដោយយោងទៅលើភស្តុតាងដែលថាការកាប់សម្លាប់សំខាន់បំផុតគឺប្រព្រឹត្តឡើងដោយកម្មាភិបាលថ្នាក់ក្រោមនៃរបបកម្ពុជាប្រជាធិបតេយ្យ ដោយមិនមានការបង្គាប់ណែនាំពីថ្នាក់ដឹកនាំខាងលើទេ។

**ស៖** ដូច្នេះសំណួររបស់លោកខ្ញុំដំបូង គឺលោកសាក្សីមានដឹងអំពីទ្រឹស្តីដែលលោក ស៊ីវ ហេងឆ័រ បានប្រើប្រាស់នេះដែរទេ?

**លោក ឆាំង យុះ**

**ឆៈ** បាទ នេះជាទ្រឹស្តីរបស់លោក ស្ទីវ ហេដឌ័រ ខ្ញុំមិន-- ខ្ញុំពិបាកនឹងឆ្លើយចំពោះគាត់ តែសូមបញ្ជាក់ប្រាប់លោកថា យើងបានទៅចុះទៅសម្ភាសមនុស្សអស់ប្រហែលជា១.០០០នាក់ ចេញពីប្រវត្តិរូបប្រហែលជា៣០.០០០ ហើយក្នុងនោះគ្មានអ្នកណាម្នាក់ថា បានសម្លាប់មនុស្សទេ។ នេះគឺជាផ្នែកមួយនៃការចុះធ្វើបទសម្ភាសរបស់អតីតយុទ្ធជន នៃរបបកម្ពុជាប្រជាធិបតេយ្យ។

**សៈ** បាទ អរគុណលោក។ តាមការបោះពុម្ពផ្សាយឯកសាររបស់លោក គឺលោកធ្វើការសិក្សាស្រាវជ្រាវដែលបង្ហាញអំពីខ្សែចង្វាក់ នៃការបញ្ជាទាក់ទងទៅនឹងការទទួលខុសត្រូវ របស់មេដឹកនាំជាន់ខ្ពស់។ តើមជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើការសិក្សាស្រាវជ្រាវឯកសារណាមួយ ដើម្បីឱ្យស៊ីសង្វាក់គ្នាទៅនឹងឯកសារលោក ស្ទីវ ហេដឌ័រ ដែលថាការសម្លាប់មនុស្សច្រើនបំផុតនោះ គឺប្រព្រឹត្តឡើងដោយកម្មាភិបាលថ្នាក់ទាប ថ្នាក់មូលដ្ឋានដោយមិនមានការបង្គាប់ ឬណែនាំពីថ្នាក់លើនោះឡើយ?

[១៣:៤៧:០៩]

**ឆៈ** ដូចខ្ញុំបានជម្រាបលោកអ៊ីចឹង កម្មវិធីនេះគឺយើងចុះទៅធ្វើបទសម្ភាស អ្នកដែលរស់រានមានជីវិតពីសម័យរបបកម្ពុជាប្រជាធិបតេយ្យ និងអតីតៗយុទ្ធជននៃរបបកម្ពុជាប្រជាធិបតេយ្យ តាមរយៈប្រវត្តិរូបដែលយើងមាន ពីព្រោះយើងចង់ដឹងថានៅក្នុងប្រវត្តិសាស្ត្រ ដែលបានកើតឡើងជុំវិញបញ្ហាទាំងអស់នេះ តើអ្នកណាជាអ្នកទទួលខុសត្រូវចំពោះការកាប់សម្លាប់ប្រជាជនពីរលាននាក់ យើងមិនបានយកគំនិតរបស់លោក ស្ទីវ ហេនឌ័រ ទេ យើងមានវិធីសាស្ត្រជាក់លាក់របស់យើង មានកម្រងសំណួររបស់យើងយកទៅប្រើប្រាស់។ ចំពោះថាលោក ស្ទីវ ហេដឌ័រ យកសំណួររបស់យើង ឬក៏បទសម្ភាសរបស់យើងទៅប្រើប្រាស់នៅក្នុងបញ្ជីណានោះ គឺជារឿងរបស់គាត់។ តែគោលបំណងតែមួយគត់ គឺយើងចង់ដឹងការពិត ថាតើអ្នកណាជាអ្នកទទួលខុសត្រូវចំពោះការកាប់សម្លាប់ប្រជាជន។ ខ្ញុំបានប្រាប់លោករួចហើយ ថាគ្មានអ្នកណាម្នាក់ថាបានសម្លាប់មនុស្សទេ ក្នុងចំណោមជាង៣០.០០០នាក់ចេញពីប្រវត្តិរូប ហើយយើងបានសម្ភាសជាង១.០០០នាក់។

[១៣:៤៨:១៤]

**សៈ** សូមអរគុណលោក។ អ៊ីចឹងខ្ញុំសូមបង្ហាញទំព័រចុងក្រោយនៃអត្ថបទរបស់លោក ស្ទីវ ហេដឌ័រ។ ខ្ញុំសូមការអនុញ្ញាត ដើម្បីបង្ហាញជូននៅលើអេក្រង់នេះ គឺនៅក្នុងប្រអប់ពណ៌ក្រហម។ ខ្ញុំសូមអានជូនលោកនៅផ្នែកក្រោយ គឺលោក ស្ទីវ ហេដឌ័រ បាននិយាយថា "ការទទួលខុសត្រូវត្រឹមត្រូវ គឺតម្រូវ

ឲ្យមានការស៊ើបអង្កេតទូលំទូលាយស៊ីជម្រៅមួយ ទាក់ទងទៅនឹងកម្ពុជាប្រជាធិបតេយ្យដែលវាគ្រាន់តែស្ទួចយកត្រឹតូចៗតែប៉ុណ្ណោះ"។ អ៊ីចេះលោក ហេដឌ័រ គឺគាត់បានសិក្សាទៅលើលភស្តុតាងទាំងអស់នេះ អស់រយៈពេលយ៉ាងច្រើនទសវត្សរ៍ ហើយជាពិសេសគឺកិច្ចការរបស់គាត់ ទាក់ទងទៅនឹងសម័យកម្ពុជាប្រជាធិបតេយ្យ ហើយបន្ទាប់ពីការសិក្សា គឺថាគាត់ធ្វើការៗសន្និដ្ឋានយ៉ាង និងធ្វើការស្រាវជ្រាវយ៉ាងស៊ីជម្រៅទាក់ទងទៅនឹងបញ្ហាប្រវត្តិសាស្ត្រ និងផ្លូវច្បាប់។ ក្នុងនាមលោកធ្វើកិច្ចការនៅក្នុងសិក្សាស្រាវជ្រាវ ប្រវត្តិនេះដែរ តើលោកយល់យ៉ាងម៉េចចំពោះការសន្និដ្ឋានរបស់លោក ស្ទីវ ហេដឌ័រ នេះ?

[១៣:៤៩:៣៣]

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន ខ្ញុំសូមជំទាស់ទៅលើសំណួរនេះ។ លោកប្រធាន គឺថាអនុញ្ញាតឲ្យរហូត ដោយឲ្យអានដល់ចំណុចនេះទៀត គឺថាជាការអនុញ្ញាតដោយការអនុគ្រោះហើយទៅលើចំណុចនេះ គឺខ្ញុំគិតថាផ្នែកនេះមិនពាក់ព័ន្ធទៅនឹងឯកសារនៅក្នុងសំណុំរឿងនោះទេ ដែលស្វែងរករឿងបញ្ហាក្រៅពីបញ្ហានៅក្នុងសំណុំរឿង។ ហើយខ្ញុំសូមស្នើសុំឲ្យលោកប្រធានបង្គាប់ឲ្យមេធាវីការពារក្តីសួរសំណួរផ្សេង។

**លោក ហ្សាស្តេី ប៉ោ៖**

ខ្ញុំសូមឆ្លើយតបទៅវិញយ៉ាងសង្ខេប។ ជាការពិតហើយដែលថា អង្គជំនុំជម្រះបានផ្តល់ពេលវេលាមកឲ្យខ្ញុំដោយការអនុញ្ញាត។ ហើយវាជារឿងមួយដែលជាបញ្ហាសំខាន់បំផុត ជាពិសេសទាក់ទងទៅនឹងវិធីសាស្ត្រការងារក្នុងការប្រមូលឯកសារ របស់មជ្ឈមណ្ឌលឯកសារកម្ពុជានេះ។ ខ្ញុំយល់ស្របថាតើសំណួរនេះគួរឆ្លើយ ឬមិនគួរឆ្លើយគឺ ខ្ញុំនឹងធ្វើតាមការបង្គាប់បញ្ជារបស់អង្គជំនុំជម្រះ ប៉ុន្តែនេះវាជាបញ្ហាមួយដែលយើងខ្ញុំយល់ឃើញថា គួរតែត្រូវឆ្លើយក្នុងពេលនេះ ឬក៏ក្នុងពេលក្រោយ។

[១៣:៥០:៥៤]

ឥឡូវខ្ញុំសូមសន្និដ្ឋានបញ្ចប់សំណួររបស់ខ្ញុំត្រង់ផ្នែកនេះទៅចុះ ពីព្រោះខ្ញុំបានរៀបចំសំណួរច្រើនណាស់ តែខ្ញុំមិនត្រូវបានអនុញ្ញាតឲ្យសាកសួរនោះទេ ពីព្រោះយើងចង់ឲ្យបានស៊ីជម្រៅទៅលើប្រធានបទដែលខ្ញុំចង់បាន គឺថាតើ ឌី.ស៊ី.ខេម នេះមានភាពលម្អៀងដែរឬក៏អត់នៅក្នុងការប្រមូលឯកសារការវិភាគទៅលើភស្តុតាង។ យើងខ្ញុំក៏បានប្រកាសរួចមកហើយ--

**ប្រធានអង្គជំនុំ៖**

ជម្រះបានជម្រាបហើយ លោកមេធាវី អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យលោកធ្វើសេចក្តីថ្លែង

ការណ៍អ្វីនោះឡើយ ឲ្យឱកាសលោកតាំងសំណួរចំពោះសាក្សីនោះ នេះពាក់ព័ន្ធទៅនឹងប្រធានបទដែលអង្គជំនុំជម្រះបានកំណត់ឲ្យភាគីដេញដោលចំពោះសាក្សីរូបនេះ ដោយសារបញ្ហាកន្លងមកមានបញ្ហាពាក់ព័ន្ធនឹងឯកសារ ហើយប្រសិនបើលោកនៅតែបន្តដូច្នេះ គឺប្រហែលជារយៈពេលសម្រាប់លោកសួរដេញដោលចំពោះសាក្សីរូបនេះ ទំនងសង្ខេបមុនពេលដែលអង្គជំនុំជម្រះបានផ្តល់វេទិកាឲ្យទៅលោក។ ពីព្រោះលោកមិនបានប្រើពេលវេលាប្រកបដោយប្រសិទ្ធភាព ចំពោះពេលវេលាដែលបានទាមទារសុំម្តងហើយម្តងទៀតបន្ថែមពេលវេលានោះឡើយ។ ហើយសំណួរអម្បាញ់មិញដែលសួរនេះគឺ ការជំទាស់របស់សហព្រះរាជអាជ្ញាមានប្រសិទ្ធភាព សាក្សី-- មិនឲ្យសាក្សីឆ្លើយតបនឹងសំណួរនេះទេ ពីព្រោះសាក្សីមិន-- មេធាវីមិនអាចយកអត្ថបទអ្នកនិពន្ធឯណាផ្សេងយកមកឲ្យសាក្សីមួយផ្សេងទៀត ដែលមិនមែនជាម្ចាស់សំណេរធ្វើការវាយតម្លៃ ឬក៏បញ្ចេញមតិយោបល់នោះឡើយ។ ម៉្យាងទៀត បើមានផ្ទាល់ខ្លួនក៏ដោយ បើសិនជាក្រៅអង្គហេតុយកមកពិភាក្សាដេញដោល ដែលអង្គជំនុំជម្រះបានកំណត់ក៏អង្គជំនុំជម្រះមិនអនុញ្ញាតដែរ។

[១៣:៥៣:០៩]

**លោក ហ្សាស្តេី ប៉ោះ**

សូមអរគុណលោកប្រធាន។ ខ្ញុំយល់អំពីការណែនាំរបស់លោក។ ខ្ញុំសូមបញ្ចប់ការសួរតទល់ជាមួយនឹងសាក្សីនៅក្នុងដំណាក់កាលនេះចុះ ប៉ុន្តែមានចំណុចពីរខ្ញុំគិតថា វាមានលក្ខណៈសមស្របមុននឹងផ្តល់វេទិកានេះ ឱកាសនេះទៅឲ្យលោក សុន អរុណ ឡើងសួរម្តង។ ទីមួយគឺ យើងខ្ញុំបានស្នើសុំឲ្យអង្គជំនុំជម្រះស្នើសុំឲ្យលោក យុ ឆាំង ផ្តល់នូវព័ត៌មានដែលយើងបានពិភាក្សាគ្នាកាលពីព្រឹកមិញនេះ គឺព័ត៌មានដែលយើងអាចរកបាននៅក្នុងកំណត់ត្រា ៣១៦ និងកំណត់ត្រា ៣១៧ ថាតើឯកសារនេះនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ជាឯកសារដើម ឬក៏អត់? ទាក់ទងទៅនឹងប្រភពដើមនៃឯកសារទាំងអស់នេះ ក៏ដូចជាអ្នកដែលបានគ្រប់គ្រង ឬក៏ថែរក្សាឯកសារនេះពីមុនមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយយើងចង់ឲ្យលោក យុ ឆាំង បង្ហាញនូវឯកសារ ដែលការិយាល័យសហព្រះរាជអាជ្ញាបានផ្តល់ជាបញ្ជីមកឲ្យ។ នេះជាសំណើសុំរបស់ក្រុមយើងខ្ញុំ សំណើទីមួយ។

[១៣:៥៤:២៦]

ហើយសំណើសុំទីពីរ ក្នុង-- យើងចង់ស្តាប់ចម្លើយសាក្សីនេះម្តងទៀត ទៅលើបញ្ហាដែលយើងខ្ញុំមិនត្រូវបានអនុញ្ញាតឲ្យសាកសួរនោះ។ អ៊ីចឹង ខ្ញុំមិនចង់លើកឡើងម្តងទៀតទេ ដោយសារថាបញ្ហា

ទាំងអស់នេះជាបញ្ហាសំខាន់ៗណាស់ ដែលធ្វើឡើងដោយអង្គការឯកជនមួយ ដែលបង្ហាញនូវសក្តានុពលក្នុងការប្រមូលនូវឯកសារទាំងអស់នេះ។

[១៣:៥៥:០០]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះបានជម្រាបលោកហើយ មិនឲ្យលោកយកវេទិកានេះធ្វើសេចក្តីថ្លែងការណ៍អ្វីទេ ឲ្យផ្តល់ឱកាសឲ្យលោកតាំងសំណួរជាក់លាក់ចំពោះសាក្សីដែលមានវត្តមាននៅទីនេះរួចហើយ ពាក់ព័ន្ធទៅនឹងកម្មវត្ថុដែលអង្គជំនុំជម្រះបានកំណត់ពាក់ព័ន្ធទៅនឹងបញ្ហាទូទៅ ទាក់ទិនជាមួយនឹងរឿងឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជា។ លោកមិនអាចបំភ្លៃនូវអ្វីដែលអង្គជំនុំជម្រះផ្តល់វេទិកាឲ្យទៅលោកតាំងសំណួរ ហើយលោកឆ្លៀតឱកាសធ្វើសេចក្តីថ្លែងការនោះទេ។ ពេលវេលាដែលលោកធ្វើសេចក្តីថ្លែងការណ៍គឺមិនទាន់ពេលទេ។ សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចនីតិវិធីនៃកិច្ចដំណើរការ គឺលោកនឹងមានពេលវេលាសមស្របសម្រាប់ធ្វើសេចក្តីថ្លែងការណ៍ទាំងអស់នេះ។

**លោក ហ្សាស្តេ ប៉ោ៖**

សូមអរគុណលោកប្រធាន ទៅតាមការអនុញ្ញាតរបស់អង្គជំនុំជម្រះ ខ្ញុំសូមជូនវេទិកានេះទៅសហការីរបស់ខ្ញុំលោក សុន អរុណ។ សូមអរគុណ។

*(ចៅក្រមពិភាក្សាគ្នា)*

[១៣:៥៨:៣៤]

**ប្រធានអង្គជំនុំ៖**

បាទ ដើម្បីមានភាពកាន់តែច្បាស់លាស់ ហើយមានមូលដ្ឋានពាក់ព័ន្ធទៅនឹងបញ្ហាចុងក្រោយនេះ អង្គជំនុំជម្រះសូមអញ្ជើញមេធាវីការពារក្តី មេធាវីអន្តរជាតិការពារក្តី នួន ជា ដែលបានតាំងសំណួរចុងក្រោយអម្បាញ់មិញនេះ ក្រោកឈរ ហើយអង្គជំនុំជម្រះប្រគល់ភារៈជូនទៅលោកចៅក្រម ហ្សង់ម៉ាក ដើម្បីធ្វើការសួរសាកសួរបន្ថែមជុំវិញបញ្ហានេះ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទសូមអរគុណលោកប្រធាន អង្គជំនុំជម្រះចង់ឲ្យលោកផ្តល់សេចក្តីបំភ្លឺទាក់ទងទៅនឹងសំណើរបស់លោក ដែលលោកត្រូវបានលើកឡើងអម្បាញ់មិញនេះ ដែលថាសំដៅចង់បានព័ត៌មានទាក់ទងទៅនឹងប្រភព និងសភាពឯកសារដែលចេញមកពីមជ្ឈមណ្ឌលកម្ពុជា។

សំណួរទីមួយដែលខ្ញុំចង់ចោទសួរនោះ គឺថាសំណើសុំព័ត៌មានបែបនេះ ត្រូវបានស្នើឡើងទៀតទេនៅក្នុងដំណាក់កាលស៊ើបអង្កេតបឋម ឬក៏លោកមិនដែលបានមានឱកាសណានៅក្នុងការធ្វើដំណើរទៅស៊ី.ឌី.ខេម ដើម្បីទទួលព័ត៌មានបែបនេះនោះទេ?

ហើយរឿងមួយទៀត គឺសំណើរបស់លោកទំនងជាអាចទាក់ទងទៅនឹងការអនុវត្តបទប្បញ្ញត្តិនៃវិធានផ្ទៃក្នុង ឧទាហរណ៍ដូចជា វិធាន៨៧(៤) ទាក់ទងទៅនឹងធាតុផ្សំភស្តុតាងថ្មី ដែលសូមដាក់បង្ហាញក្នុងការជជែកដេញដោល គឺថាវិធាន៨៧(៤) ចែងយ៉ាងដូច្នេះ។ ភាគីគឺត្រូវទទួលខុសត្រូវថា ភាគីទទួលបាននូវភស្តុតាងណាដែលមុននឹងការបើកសវនាការ។

[១៤:០១:០៥]

**លោក ហ្វ្រាស្តេ ប៉ោះ**

សូមអរគុណលោកចៅក្រម ឡាវែន ខ្ញុំសូមឆ្លើយតបសង្ខេប។ ចម្លើយទីមួយ ទៅនឹងសំណួររបស់លោកចៅក្រម គឺយើងខ្ញុំមិនបានព្យាយាមបង្កើតអំពីប្រភពនៃឯកសារនៅលើបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញាទាំងអស់នោះទេ ដោយសារថាយើងមិនដឹងថាឯកសារមួយណាដែលសហព្រះរាជអាជ្ញាបានយកមកធ្វើសំអាង ឬក៏យោងនៅក្នុងពេលនេះទេ នៅក្នុងពេលសវនាការនេះទេ។ ជាពិសេសគឺថាយើងខ្ញុំមិនដឹងថាតើសវនាការនឹងរៀបចំទៅជាផ្នែកតូចៗដូចជាផ្នែក-- ទៅតាមផ្នែកតូចៗនៃឯកសារហើយក៏មិនដឹងថាតើយើងខ្ញុំអាចបញ្ជាក់ប្រភពនៃឯកសារទាំងនេះពីខាងដើមទីបានឬយ៉ាងណានោះទេ ដោយសារសវនាការកាលពីសប្តាហ៍មុន ហើយនិងពីព្រឹកមិញនេះគឺនិយាយគ្នាអំពីការស្វែងរកឲ្យដឹងថាតើមជ្ឈមណ្ឌលឯកសារធ្វើអ្វី? ហើយបានប្រមូល និងរក្សាទុកឯកសារដោយរបៀបណា? ហើយព្រឹកនេះ គឺថា ឌី.ស៊ី.ខេម បានបញ្ចូលព័ត៌មានទាំងអស់នេះទៅក្នុងទិន្នន័យរបស់ខ្លួន នៅក្នុងប្រអប់ ៣១៦ និង ៣១៧។

[១៤:០២:៣០]

ដូច្នេះថ្ងៃនេះខ្ញុំបានបញ្ជាក់ជាមួយលោក ឆាំង យុ ថាប្រអប់ទាំងនេះគឺមានព័ត៌មានដែលយើងកំពុងតែស្វែងរកប៉ុន្មានសប្តាហ៍កន្លងមកនេះ។ សូម្បីតែលោក យុ ឆាំង មិនច្បាស់នូវអ្វីដែលយើងខ្ញុំស្វែងរកនៅក្នុងប្រអប់ទាំងនេះក៏ដោយ។ ហេតុដូច្នេះឯងគឺថា ថ្ងៃនេះយើងខ្ញុំមានសង្ឃឹមថា ទទួលបាននូវអ្វីដែលយើងរក ចង់បានប្រភពនៃឯកសារក៏ដូចជា ខ្សែចង្វាក់នៃការរក្សាទុកឯកសារទាំងអស់នេះ។ ជាពិសេសនៅក្នុងទិន្នន័យជាក់លាក់ ក៏ដូចជានៅក្នុងប្រអប់ ៣១៦ និង៣១៧នេះដែរ។ នេះគឺជាហេតុផល

ដែលខ្ញុំសូមឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជាផ្តល់ព័ត៌មានមកឲ្យខ្ញុំនៅថ្ងៃនេះតែម្តង។ ខ្ញុំសូមស្នើថា តាមការពិតទៅវាមិនមែនយើងខ្ញុំដែលត្រូវលើកសួរអំពីបញ្ហាទាំងអស់នេះ ដើម្បីរកឲ្យឃើញថាតើប្រភពដើមឯកសារយ៉ាងណានោះទេ?

[១៤:០៣:៣១]

គឺតាមការពិតវាអាស្រ័យទៅលើការិយាល័យសហព្រះរាជអាជ្ញា និងការិយាល័យសហចៅក្រមស៊ើបអង្កេតទៅវិញទេ ដែលថាព័ត៌មាននេះ គឺអាចរកបាននៅមជ្ឈមណ្ឌលឯកសារកម្ពុជា។ នេះតាមដែលខ្ញុំយល់សំណួររបស់លោកចៅក្រម។ ប្រសិនណាជាទាក់ទងទៅនឹងការគិតពិចារណាថា យើងខ្ញុំមានការយឺតយ៉ាវនេះ គឺថាយើងបង្កើតឡើងតែនៅថ្ងៃនេះតែប៉ុណ្ណោះ ដែលថាព័ត៌មាននេះគឺអាចនឹងទទួលយកបាន ហើយជាការពិត គឺថាតាមពិតមិនមែនទេ កាតព្វកិច្ចរបស់យើងខ្ញុំនេះគឺជាភាគីទាំងអស់ដែលចង់យកព័ត៌មាននេះមកប្រើប្រាស់ជាភស្តុតាង។ នេះគឺជាចម្លើយផ្នែកខ្លះទៅនឹងសំណួររបស់លោកចៅក្រម។

[១៤:០៤:១៧]

ហើយចម្លើយទីពីររបស់យើងខ្ញុំគឺថាតើព័ត៌មាននេះ អាចទទួលបាននៅមុនការចាប់ផ្តើមសវនាការដែរឬក៏អត់? យើងបានរកឃើញថា តាមការពិតព័ត៌មាននេះគឺ ដែលមាននៅក្នុងប្រអប់ ៣១៦ និង៣១៧ គឺដោយសារតែព័ត៌មាននេះឯង ទើបបានខ្ញុំចោទសួរសំណួរទាំងអស់នេះទៅ។ ខ្ញុំសង្ឃឹមថា ខ្ញុំឆ្លើយទៅនឹងសំណួរលោកចៅក្រម។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ថារីក៖**

ខ្ញុំមិនចង់ស្កាត់ការលើកឡើងរបស់ចៅក្រម ឡាវ៉ែន៍ នោះទេ ក៏ប៉ុន្តែខ្ញុំចង់បញ្ជាក់ឆ្លើយតបទៅលើការលើកឡើងនេះ។ ដោយសារតែវាត្រូវការលើកឡើងពាក់ព័ន្ធទៅនឹងអ្វីដែលលើកឡើង ដើម្បីកែប្រែប្រតិចារឹកឲ្យបានត្រឹមត្រូវ ក្រោយពីចៅក្រម ឡាវ៉ែន៍ សួរ បើសិនជាគាត់មាន ខ្ញុំនឹងសុំលើកឡើងបន្ទាប់ពីលោកចៅក្រម ឡាវ៉ែន៍។

**ប្រធានអង្គជំនុំ៖**

អញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

[១៤:០៥:៥២]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។ ខ្ញុំនឹងលើកឡើងដោយសង្ខេប ក៏ប៉ុន្តែខ្ញុំមានបំណងចង់ធ្វើការឲ្យការលើកឡើង ដើម្បីឲ្យប្រតិចារឹកឲ្យត្រឹមត្រូវ ជូនលោក លោកស្រីចៅក្រម ទៅលើចំណុចដែលពាក់ព័ន្ធ។

ជាចំណុចចាប់ផ្តើម មេធាវីការពារក្តីទទូចចង់សួរលម្អិតទៅលើប្រភព និងការរក្សាទុកឯកសារ។ អង្គជំនុំជម្រះបានចេញសេចក្តីសម្រេចរួចហើយថា ចំណុចនោះគឺមិនត្រឹម-- មិនជាការទាមទារពាក់ព័ន្ធទៅនឹងឯកសារនោះទេ។ អនុស្សរណៈនៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០១២ កថាខណ្ឌ២ បានលើកឡើងយ៉ាងច្បាស់លាស់ថា ភាពជឿជាក់ពីដំបូង យថាភាពពីដំបូង និងភាពពាក់ព័ន្ធពីដំបូងនោះគឺគ្រប់គ្រាន់ហើយ។ លើកលែងតែឯកសារនោះ គឺវាជាឯកសារក្លែងបន្លំទៅលើដើម។ អង្គជំនុំជម្រះបានសម្រេចរួចហើយ។

ដូច្នេះ យើងខ្ញុំសូមលើកឡើង ថាបទដ្ឋានចំណុចត្រង់នេះ ត្រូវតែបំពេញ។ ប្រសិនបើមេធាវីការពារក្តីចង់តវ៉ាឯកសារណាមួយជាក់លាក់ទៅលើប្រភពឯកសារដើម ឬក៏ភាពពាក់ព័ន្ធនឹងយថាភាពនោះ គឺគាត់ត្រូវតែបង្ហាញឲ្យបានច្បាស់លាស់។ គឺវាតម្រូវឲ្យលើកឡើងថា តើហេតុអ្វីបានជាឯកសារទាំងអស់នោះ វាមិនត្រូវគ្នា និងគោរពទៅតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ។

[១៤:០៧:២២]

ចំណុចមួយទៀត ពាក់ព័ន្ធទៅនឹងបំពេញការងារដោយខ្ជាប់ខ្ជួន ប្រសិនបើយើងមើលទៅលើកាលបរិច្ឆេទនូវឯកសារ *មេញ្ចូល* នោះគឺឆ្នាំ១៩៩៩ ដែលមាននៅលើគេហទំព័រ ឌី.ស៊ី.ខេម។ ហើយបន្តទៅលើមេធាវីការពារក្តីដែលគាត់បានដឹងទៅលើឯកសារទាំងអស់នោះហើយ ហើយប្រសិនបើយើងមើលទៅក្នុងសំណុំរឿង វាពាក់ព័ន្ធទៅនឹងដំណើរការកិច្ចស៊ើបសួរ។ ឯកសារមួយចំនួននោះ វាពាក់ព័ន្ធទៅនឹងការចងក្រងប្រមូលឯកសារដោយ ឌី.ស៊ី.ខេម។ ឯកសារ D313 របស់ អូ.ស៊ី.ភី គឺនៅក្នុងកថាខណ្ឌ២៥ នោះ គឺបានបញ្ជាក់ហើយថា យើងបានធ្វើទៅតាមការបង្គាប់របស់ចៅក្រមស៊ើបអង្កេត ហើយយើងត្រៀមឱកាសទៅ ឌី.ស៊ី.ខេម ដើម្បីមើលកំណត់ហេតុឯកសារនៅទីនោះ ពិនិត្យទៅមើលឯកសារពាក់ព័ន្ធ ថាតើវាមានឯកសារជាសាធារណៈនៅក្នុងកន្លែងរបស់គេដែរឬទេ?

[១៤:០៨:២៤]

យើងខ្ញុំបានលើកឡើងទៅលើចំណុចហ្នឹង ហើយចៅក្រមស៊ើបអង្កេតបើកឲ្យភាគីទាំងអស់ ធ្វើទៅលើចំណុចនេះ។ នៅក្នុងអនុស្សរណៈថ្ងៃទី៣១ ខែមករា ២០០៩ គឺនៅពេលនោះ មេធាវីការពារក្តីមិន

មានការឆ្លើយតបទៅនឹងឯកសារដែលស្នើសុំឲ្យពិនិត្យនៅ ឌី.ស៊ី.ខេម នោះឡើយ។ នៅក្នុងឯកសារនោះ គឺមិនមានការបញ្ជាក់ពីមេធាវីការពារក្តី នួន ជា ចំពោះបញ្ហានេះ រួមទាំងមេធាវីដទៃទៀត ដែលថា អូ.ស៊ី.ភី ក.ស.ព គួរតែត្រឡប់ទៅ ឌី.ស៊ី.ខេម វិញ ដើម្បីប្រមូលទៅលើ-- ពិនិត្យទៅលើប្រភព ឯកសារដើម និងខ្សែចង្វាក់នៃការរក្សាទុកឯកសារ។ ដូច្នេះ ឯកសារទាំងអស់នោះ គឺវាពាក់ព័ន្ធស្ថិតនៅក្នុងបញ្ជីដែលយើងបានលើកឡើងយកមកពិភាក្សា។

[១៤:០៩:១៩]

យើងខ្ញុំសូមបង្ហាញជំហរថា លក្ខខណ្ឌដែលអង្គជំនុំជម្រះបានលើកឡើង គឺយើងខ្ញុំបានបំពេញរួចរាល់ហើយ ទៅតាមលក្ខខណ្ឌនៃឯកសារ ហើយយើងបានស្តាប់សក្ខីកម្មភស្តុតាងចំនួនប្រាំថ្ងៃហើយពាក់ព័ន្ធទៅនឹងប្រភពការវាយតម្លៃ-- ការដំណើរការទៅលើឯកសារ និងការរក្សាទុកឯកសារ។ ដូច្នេះ ហើយមេធាវីការពារក្តី នៅពេលនេះ គឺគាត់ព្យាយាមស្វែងរក និងស៊ើបអង្កេតទៅលើឯកសារផ្សេងទៀត។ យើងដឹងហើយថា ឯកសារទាំងអស់នេះ មាននៅក្នុងសំណុំរឿងជាងពីរឆ្នាំ ឬក៏យូរជាងមកហើយ ហើយយើងមានឱកាសរួចមកហើយ យើងមានឱកាសធ្វើសំណើទៅលើចំណុចនេះ ក៏ប៉ុន្តែគាត់មិនបានធ្វើនោះទេ។

ខ្ញុំសូមស្នើថា នៅក្នុងដំណាក់កាលនេះសំណើដែលបានធ្វើឡើងដោយមេធាវីការពារក្តីគ្មានអ្វីក្រៅពីការពន្យារកិច្ចដំណើរការនីតិវិធីនោះឡើយ។ សូមអរគុណ។

[១៤:១០:១៣]

**លោក ហ្សាស្តើ ប៉ោះ**

ខ្ញុំសូមអនុញ្ញាតឆ្លើយតបទៅនឹងបញ្ហានេះ។ ជាថ្មីម្តងទៀត ខាងតំណាងសហព្រះរាជអាជ្ញា គឺព្យាយាមបង្វិលបន្ទុកនៃការបង្ហាញភស្តុតាងទៅលើឯកសារនេះមកកាន់ភាគីផ្សេង។ យើងមិនមែនជាអ្នកត្រូវការផ្តល់យថាភាពទៅលើឯកសារ ដែល អូ.ស៊ី.ភី, ក.ស.ព ចង់យកមកផ្អែកជាមូលដ្ឋាននោះឡើយ។ ប្រសិនបើការិយាល័យសហព្រះរាជអាជ្ញាចង់ប្រើប្រាស់ឯកសារណាមួយជាភស្តុតាង ការិយា-ល័យសហព្រះរាជអាជ្ញាត្រូវតែផ្តល់ព័ត៌មានឲ្យបានគ្រប់គ្រាន់ ដើម្បីអាចឲ្យយើងធ្វើការផ្ទៀងផ្ទាត់ថា ឯកសារព័ត៌មានទាំងអស់នោះ វាមានយថាភាព និងអាចទុកបានចិត្តបានដែរឬទេ។ នេះគឺគោលបំណងនៃសវនាការក្នុងរយៈពេលពីរសប្តាហ៍ចុងក្រោយ។

[១៤:១១:០៤]

យើងបានស្តាប់ហើយព័ត៌មានដែលវាពាក់ព័ន្ធទៅនឹងវិធីដែល ឌី.ស៊ី.ខេម រក្សា និងចាត់ចែងទៅលើឯកសារ និងព័ត៌មាន។ យើងបានកត់សម្គាល់ឃើញនាពេលថ្មីៗនេះថា មិនមានការធ្វើកំណត់ហេតុជាលាយលក្ខណ៍អក្សរនៅពេលដែល ឌី.ស៊ី.ខេម ស្នើសុំពីភាគីដែលប្រគល់ឯកសារនោះឡើយ។ ដូច្នេះហើយទើបចំណុចនេះវាពាក់ព័ន្ធនៅក្នុងសវនាការយើង។ ចំណុចនេះហើយដែលបញ្ហានេះវាជាបញ្ហាបន្ទាន់ ដែលយើងត្រូវតែបង្ហាញឲ្យយើងឃើញឲ្យបានជឿជាក់បន្ថែមទៀត។

សហព្រះរាជអាជ្ញាបានលើកឡើងអំពីករណីដែលថា វាជាការស៊ើបអង្កេតឲ្យលម្អិតទៅលើប្រភពនៃឯកសារ មិនមែនជាសំណើរបស់ខ្ញុំនោះទេ។ ការស្នើសុំរបស់ខ្ញុំនៅពេលនេះ គឺថាតើព័ត៌មាន ៣១៦ និង៣១៧ មានដែរឬទេ? តាមអ្វីដែលខ្ញុំយល់នោះ គឺប្រព័ន្ធ អាយ.ធី ប្រព័ន្ធកុំព្យូទ័រនេះគឺអាចភ្ជាប់ទំនាក់ទំនងឯកសារជាក់លាក់មួយទៅនឹងប្រអប់៣១៦ និង៣១៧បាន។ ដូច្នេះគ្រាន់តែផ្តល់ព័ត៌មានរបស់យើងដែលស្ថិតនៅក្នុងកូឡោន ៣១៦ និង ៣១៧។ បន្ទាប់មកយើងខ្ញុំអាចផ្ទៀងផ្ទាត់ ថាតើខ្សែចង្វាក់នៃការរក្សាទុកនៃឯកសារ និងអ្នកដែលកាន់កាប់ឯកសារមុន និងបច្ចុប្បន្ននោះ គឺបានរៀបចំ និងកត់ត្រាឯកសារបានត្រឹមត្រូវដែរឬទេ?

[១៤:១២:៣៣]

ខ្ញុំមានភាពសង្ស័យចំពោះឯកសារជាច្រើន ហើយដោយពិចារណាទៅលើអ្វីដែលខ្ញុំបានលើកឡើង យើងក៏សង្ស័យទៅលើករណីដែលមិនមានការកត់ត្រាជាលាយលក្ខណ៍អក្សរនៅពេលដែលប្រមូលឯកសារនេះ ជាចំណុចដែលយើងត្រូវតែបង្ហាញ។ វាជាបន្ទុករបស់ការិយាល័យសហព្រះរាជអាជ្ញាជាអ្នកបង្ហាញនៅពេលដែលគេចង់ផ្អែកជាមូលដ្ឋាន។ បើសិនជាយើងនិយាយអំពីកិច្ចការដែលត្រូវបំពេញដោយខ្ជាប់ខ្ជួននោះ គឺការិយាល័យសហព្រះរាជអាជ្ញានោះ ដែលមិនបានបំពេញកិច្ចការដោយខ្ជាប់ខ្ជួន។

ដូច្នេះហើយទើបយើងរៀបចំសវនាការក្នុងរយៈពេលប៉ុន្មានអាទិត្យនេះ ដើម្បីបញ្ជាក់ទៅលើចំណុចនេះ។ វាមិនត្រឹមត្រូវ និងយុត្តិធម៌ទេ ប្រសិនបើដាក់បន្ទុកមកខាងមេធាវីការពារក្តី។

[១៤:១៣:២៤]

ដូច្នេះជាថ្មីម្តងទៀត វាជាបន្ទុករបស់ខាងការិយាល័យសហព្រះរាជអាជ្ញា ហើយយើងផ្តល់ឱកាសឲ្យសហព្រះរាជអាជ្ញាធ្វើការបំពេញ និងបង្ហាញអំពីយថាភាពទៅលើឯកសារ ហើយផ្តល់ព័ត៌-មានទៅលើប្រអប់នៅក្នុង៣១៦-- ព័ត៌មាននៅក្នុងប្រអប់៣១៦ និង៣១៧។ ភាពពិតប្រាកដនៃឯកសារនេះ គឺត្រូវការឯកសារដែលពិតប្រាកដ និងពិត និងជាក់លាក់។ ដូច្នេះហើយ យើងត្រូវយកប្រមូល

ព័ត៌មានទាំងអស់នោះពី ឌី.ស៊ី.ខេម។ យើងត្រូវប្រមូលព័ត៌មានទាំងអស់នេះ បញ្ចូលមកក្នុងសំណុំរឿង ដើម្បីបញ្ជាក់អំពីយថាភាពទៅលើឯកសារ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:១៦:០៦]

**ប្រធានអង្គជំនុំ៖**

ពាក់ព័ន្ធទៅនឹងសំណើសុំដែលលើកឡើងដោយមេធាវីអន្តរជាតិការពារក្ដីលោក នួន ជា អម្បាញ់មិញនេះ អង្គជំនុំជម្រះនឹងធ្វើការឆ្លើយតបនៅក្នុងអំឡុងពេលសមស្របខាងមុខ។ សូមអញ្ជើញលោក សុន អរុណ!

**លោក សុន អរុណ៖**

សូមគោរពអង្គសវនាការ សូមគោរពលោកប្រធាន។ ខ្ញុំមានម៉ោងរយៈពេលប៉ុន្មាន ពីព្រោះខ្លាចក្រែងលោសួរមិនអស់ ដល់ចប់ទៅ ខ្ញុំមានប្រហែលជាម្ភៃសំណួរ។

**ប្រធានអង្គជំនុំ៖**

លោកមានពេលរហូតដល់ម៉ោងបីខ្វះម្ភៃនាទី ព្រោះយើងបានកំណត់តាំងពីយូរមកហើយ។ ព្រឹកមិញក៏ជម្រាប ហើយអម្បាញ់មិញនេះក៏បានជម្រាបដែរ មុននឹងផ្ដល់វេទិកាទៅ។

**សួរដោយលោក សុន អរុណ៖**

បាទ ដូច្នេះ ខ្ញុំបាទនឹងសួរទៅតាមពេលវេលាដែលបានកំណត់។ សូមអរគុណណាស់។

**ស៖** សូមជម្រាបសួរលោក ឆាំង យុ។ ជាដំបូងខ្ញុំសូមសួរលោកនូវសំណួរទីមួយ នៅក្នុងឯកសារសួរចម្លើយរបស់ចៅក្រមស៊ើបអង្កេត លេខ D2.2-7 សហចៅក្រមស៊ើបអង្កេតកាលពីថ្ងៃទី ១២ ខែកក្កដា ឆ្នាំ២០០៧ ក្នុងឋានៈលោកជាសាក្សី ខ្ញុំសូមសួរថា ឯកសារដែលបានតម្កល់នៅ ឌី.ស៊ី.ខេម ទាំងអស់នោះជាឯកសារកាលពីសម័យកម្ពុជាប្រជាធិបតេយ្យ និងពាក់ព័ន្ធក្នុងព្រឹត្តិការណ៍ផ្សេងៗនៅសម័យនោះ។ ឯកសារទាំងអស់ដែលលោកបានទទួលតើជាឯកសារសំណៅដើមទាំងអស់ ឬជាឯកសារថតចម្លងខ្លះ ឬដើមខ្លះ? សំណួរនេះខ្ញុំជឿថា បានសួរម្ដងហើយ ប៉ុន្តែចង់រំឭកឡើងវិញ។

**លោក ឆាំង យុះ**

**ឆ៖** បាទ ឯកសារដែលយើងទទួលបាននេះ គឺមានឯកសារដើមខ្លះ និងឯកសារថតចម្លងខ្លះ។

**ស៖** សូមអរគុណណាស់។ ត្រង់ឃ្លាមួយនៅខាងក្រោម លោកឆ្លើយថា ឯកសារទាំងអស់នោះ នៅ ឌី.ស៊ី.ខេម ពិតជាត្រឹមត្រូវតាមច្បាប់ដើម ៗមានន័យតាមសំណៅដើម។ ឃ្លានេះលោកចង់និយាយថាយ៉ាងម៉េច?

[១៤:១៨:៥២]

**ឆ៖** ខ្ញុំចង់និយាយសំដៅទៅលើឯកសារមកប្រទេសស៊ុយអែត ដែលយើងបានថតចម្លងចេញពីឯកសារដើម ហើយបានដឹកយកមកប្រទេសកម្ពុជា។ ហើយឯកសារមួយចំនួនទៀត គឺជាឯកសារដែលយើងរកឃើញក្រោយពេលដែលសាកលវិទ្យាល័យ ខូណែល បានរៀបចំជា*ម៉ៃក្រូហ្វីម* ឯកសារនៅសារមន្ទីរទួលស្លែង ហើយដែលខ្ញុំបានរកឃើញសេសសល់នៅក្នុងបន្ទប់ផ្សេងទៀត ហើយយើងបានយកឯកសារនោះមកថតចម្លង ទុកឯកសារថតចម្លងនៅមជ្ឈមណ្ឌលឯកសារកម្ពុជារបស់យើង ហើយឯកសារដើមនៅសារមន្ទីរទួលស្លែង។

**ស៖** បើតាមខ្ញុំយល់ ប្រហែលជាខុសជាមួយនឹងលោក។ ឯកសារដើមមានន័យថា សំណៅដើមអ៊ីចឹង?

**ឆ៖** ឯកសារដើមគឺជាឯកសារដែលមិនទាន់ត្រូវបានថតចម្លង។ បាទឯកសារដើមខ្ញុំឧទាហរណ៍ ដូចជាឯកសារមួយដែលមានវ័យចំណាស់ ដែលមានអាយុកាល កាលពីសម័យខ្មែរក្រហមដែលមិនទាន់ត្រូវបានថតចម្លងដោយនរណាម្នាក់ទៀត ដែលមានពណ៌សម្បុរ ដែលមានអ្នកនិពន្ធកាលពីសម័យនោះ។ ឯកសារថតចម្លង គឺយើងប្រើម៉ាស៊ីនហ្វូតូកូពី ឬក៏ម៉ាស៊ីនស្កេន វាមានរូបរាងខុសគ្នា មានពណ៌ខុសគ្នា បើសិនជាលោកធ្វើការថតចម្លង គឺឯកសារនេះមានតែពណ៌ខ្មៅសទេ តែឯកសារដើមវាមានជាពណ៌មានប៊ិក មានក្ដូល័រ មានពណ៌ផ្សេងៗនៅលើឯកសារនោះ។

[១៤:២០:១៥]

**ស៖** អរគុណណាស់។ តើលោកអះអាងថា ត្រឹមត្រូវតាមសំដៅតាម ឬតាមច្បាប់ដើមតើលោកមានអ្វីសំអាងថាត្រឹមត្រូវតាមច្បាប់ដើមនោះ?

**ឆ៖** លោកចង់សំដៅទៅលើឯកសារមកពីប្រទេសស៊ុយអែត ឬក៏--

**ស៖** ពីប្រទេសស៊ុយអែតក្ដី ឬក្នុងប្រទេសក្ដី បើលោកអាចឆ្លើយបានទាំងពីរ?

**ឆ៖** នៅក្នុងប្រទេស គឺខ្ញុំអ្នកហ្វូតូកូពី តែម្តង បុគ្គលិករបស់ខ្ញុំ ដូចជាឯកសារទួលស្លែងអ៊ីចឹង ពេលដែលយើងរកឃើញក្រោយពេលដែលសាលាខូណែល បានបញ្ចប់ការ កម្មវិធីរបស់ខ្លួនទៅ យើងរកឯកសារផ្សេងទៀត។ អ៊ីចឹង ឌី.ស៊ី.ខេម ខ្លួនឯងហ្នឹង ជាមួយទួលស្លែងហ្នឹង គឺហ្វូតូកូពី ចែកគ្នាប្រើប្រាស់ដាក់នៅទួលស្លែងផង ដាក់នៅកន្លែង ឌី.ស៊ី.ខេម ផង ហើយយើងបានចុះលេខសម្គាល់ថា លេខ TSL លេខមួយនេះ ឯកសារដើមមួយនេះជារបស់ទួលស្លែង ហើយមានមួយនៅ ឌី.ស៊ី.ខេម ដែលយើងប្រើអក្សរ D អ៊ីចឹងយើងអាចផ្ទៀងផ្ទាត់គ្នាបានបាទ។

[១៤:២១:០៩]

**សះ** ត្រង់ពាក្យរបស់លោកឆ្លើយប្រាប់ទៅចៅក្រមស៊ើបអង្កេតថា ឯកសារទាំងនោះមានលក្ខណៈស្របច្បាប់ អ៎! ស្របគ្នាទៅនឹងឯកសារសម័យខ្មែរក្រហម។ ត្រង់ចម្លើយនេះមានន័យថាយ៉ាងម៉េច? ស្របគ្នានេះ គ្រាន់តែជាពាក្យសន្និដ្ឋានរបស់លោកទេ ឬយ៉ាងណា ឬមានអ្វីសំអាងពីព្រោះមនុស្សសម័យនេះ បើគេអាចធ្វើទៅជាយ៉ាងណាក៏ធ្វើបាន ពីព្រោះ *តិចណូឡូជី* គេជឿនលឿនណាស់។

**ឆ៖** ខ្ញុំយល់សំណួររបស់លោក។ ខ្ញុំជូនឧទាហរណ៍មួយ ឯកសារមួយចំនួនរបស់របបកម្ពុជាប្រជាធិបតេយ្យ បានប្រើក្រដាស់ដែលសេសសល់ពីរបបសាធារណរដ្ឋខ្មែរយកមកប្រើប្រាស់ ហើយកាលសម័យនោះ គេប្រើអង្គុលីលេខៗ វាយអក្សរអង្គុលីលេខ ហើយមួយទៀតនៅក្នុងនោះមានអ្នកនិពន្ធ តែអ្នកនិពន្ធនោះ គឺដូចជាឧទាហរណ៍ អ្នកខ្លះនៅរស់រានមានជីវិតនៅឡើយ។ អ៊ីចឹងឯកសារពីមួយទៅមួយនេះ វាទាក់ទងគ្នា បើសិនជាលោកចង់ក្លែងឯកសារ ឬចង់បន្លំឯកសារនេះ ទាល់តែលោកធ្វើឯកសារផ្សេងៗទៀត។ ពីព្រោះឯកសារនេះ វាស្រាក់គ្នា លោក អរុណ។

[១៤:២២:១៦]

អ៊ីចឹងគិតថា ឯកសារខ្មែរក្រហមនេះ ហើយមួយទៀតពាក្យពេចន៍សម្តីដែលប្រើប្រាស់ បាទទោះបីមានតិចណូឡូជី ទោះបីមានយ៉ាងណាក៏ដោយ គឺអ្នកហ្នឹងត្រូវដឹងសាច់រឿងធំមែនទែន។ បាទ ដូចជារឿងបុប្ផាណាអ៊ីចឹង ដែលមានជាង១.០០០ទំព័រហ្នឹង គឺគាត់មានសរសេរតាំងពីសំបុត្រស្នេហាជាមួយប្តីគាត់ក៏មាន សរសេរតាំងពីសេកស្មៀរ សរសេរតាំងពីរឿងគាត់រត់ទៅភូមិនេះ ឃុំនេះ ខេត្តនេះក៏មាន។ អ៊ីចឹងការបង្កើតរឿងរ៉ាវមួយ គឺវែងអន្លាយ ហើយមិនងាយនឹងអាចធ្វើបាន ទោះបីសម័យនេះយើងមាន តិចណូឡូជី យ៉ាងណាក៏ដោយ។

**សះ** លោក ឆាំង យុ មានដែលបានទទួលឯកសារ ជាឯកសារសរសេរដៃ ឬជាឯកសារអ្វី

សរសេរជាដៃខ្លះមកទេ ឯកសារអីក៏បានដែរ ឲ្យមានសរសេរជាដៃ?

**ឆ៖** លោកចង់និយាយថា ឯកសារសរសេរដៃក្រោយ៧៩ ឬក៏សម័យខ្មែរក្រហម?

**ស៖** សម័យខ្មែរក្រហម?

**ឆ៖** មាន ដូចជាមានកំណត់ហេតុមួយរបស់ជនរងគ្រោះ។ តាមដែលខ្ញុំចាំ គឺមានសៀវភៅមួយនៅក្នុងចំណោមសៀវភៅ៤៥០ ដែលយើងហៅឈ្មោះថា កំណត់ហេតុរបស់កម្មាភិបាលកម្ពុជាប្រជាធិបតេយ្យ គឺជាកំណត់ហេតុរបស់បុគ្គល។ នៅក្នុងកំណត់ហេតុជាង៤០០នេះ ខ្ញុំបានអាន ហើយឃើញមានមួយនោះ យើងគិតថាមិនមែនជារបស់អតីតយុទ្ធជនកម្ពុជាប្រជាធិបតេយ្យទេ ពីព្រោះនិយាយរឿងរ៉ាវអំពីស្ត្រីម្នាក់ដែលបានធ្វើដំណើរមកពីស្រុកបារាំង ហើយមកចូលរួមបដិវត្តន៍ ក្រោយមកប្រហែលជាត្រូវបានយកទៅសម្លាប់។ ហើយយើងបានឃើញនៅក្នុងកំណត់ហេតុនោះ មានប្រាប់អំពីទីតាំងនៅខេត្តកំពង់ចាម។ ខ្ញុំបានឲ្យកំណត់ហេតុនេះទៅលោក ឫទ្ធី ប៉ាន់ ដើម្បីស្រាវជ្រាវរកមើលក្រុមគ្រួសាររបស់គាត់ទៀតផង។ ហើយឯកសារនេះ គឺសរសេរដោយដៃ បាទ។

[១៤:២៣:៥៣]

**ស៖** តែមួយហ្នឹងទេ ដែលលោកបានទទួលហ្នឹង?

**ឆ៖** នៅក្នុងសម័យខ្មែរក្រហម បើសិនជាឯកសារដែនិយាយជាសរសេរ កំណត់ហេតុទាំងអស់ទាំង៤៥០នេះ គឺសុទ្ធសឹងតែជាកំណត់ហេតុសរសេរដោយដៃទាំងអស់ របស់អតីតយុទ្ធជនកម្ពុជាប្រជាធិបតេយ្យ បាទ សរសេរដៃទាំងស្រុង ហើយគូររូបនៅក្នុងហ្នឹងទៀត ហើយកំណត់ហេតុខ្លះចាប់ផ្ដើមតាំងពីឆ្នាំ៧២, ៧៣ ក៏មានដែរ រហូតមកទល់របបកម្ពុជាប្រជាធិបតេយ្យត្រូវបានឡើងកាន់អំណាច។

**ស៖** បាទ អរគុណណាស់។ លោកបានប្រាប់ទៅចៅក្រមស៊ើបអង្កេតថា អំពីបុព្វបទអក្សរ "ខ" សំដៅទៅឯកសារបានមកពីរដ្ឋបាល និងឯកជនជាច្រើន។ តើលោកយល់ថា ឯកសារទាំងពីរប្រភេទនេះ តើពិតប្រាកដជាឯកសាររបស់កម្ពុជាប្រជាធិបតេយ្យមែនឬទេ?

**ឆ៖** សូមទោស អក្សរ ខេ "K" ជាភាសាអង់គ្លេស។

**ស៖** អ្ហឺ! អក្សរ "ខ" ភាសាខ្មែរ។

**ឆ៖** អក្សរ ខ!

[១៤:២៥:០០]

**ស៖** ខ្ញុំឃើញនៅកំណត់ហេតុសាកសួររបស់សហចៅក្រមស៊ើបអង្កេតសរសេរអក្សរ "ខ"។

**ឆ៖** ខ្ញុំដូចចម្លែកអក្សរ “ខ” បើសិននេះ ប្រហែលអក្សរ “K” ។

**ស៖** វាអាចសន្និដ្ឋានប្រហែលហ្នឹង។

**ឆ៖** បាទ។ បើសិនជាអក្សរ ខេ “K” គឺជាប្រវត្តិរូបបាទ។

**ស៖** ហ្នឹង។

**ឆ៖** ខេ “k” និង អាយ “I” គឺជាប្រវត្តិរូប។ បើអក្សរ “ខ” ជាខ្មែរ យើងមិនដែលប្រើអក្សរខ្មែរទេ យើងប្រើអក្សរអង់គ្លេស ខេ “k”ៗ ខេអេច “KH”។

**ស៖** ចំពោះឯកសារដែលលោកបានប្រមូលមកពី ស-២១ ជាឯកសារប្រភេទ អាយ “I”

**ឆ៖** ប្រវត្តិរូបបាទ។

**ស៖** គឺជាសំដៅទៅលើប្រវត្តិរូបរបស់កម្មាភិបាលខ្មែរក្រហម ឬប្រជាជនទូទៅដែលជាប់ឃុំឃាំងនៅទីនោះ និងកន្លែងផ្សេងទៀត?

**ឆ៖** ឯកសារ អាយ “I” នេះគឺជាប្រភេទឯកសារប្រវត្តិរូប។ នៅពេលដែលយើងប្រើពាក្យថា ប្រវត្តិ-- លោកចៅក្រមខ្ញុំអាចបន្តបាន?

[១៤:២៦:០០]

**ប្រធានអង្គជំនុំ៖**

បន្តបាន ប៉ុន្តែដោយបញ្ហាបកប្រែ មានបញ្ហា ដោយសារតែលោកទាំងពីរនិយាយឆ្លើយឆ្លងហ្នឹងឆាប់រហ័សពេក ហើយនិយាយលឿន អ៊ីចឹងធ្វើឲ្យការបកប្រែមានបញ្ហា។ អ៊ីចឹងសូមលោកពីរ ទាំងពីរគឺឲ្យនិយាយឲ្យបានយឺតបន្តិច ទីពីរបង្អង់បន្តិចមុននឹងសួរ ឬមុននឹងឆ្លើយ។ ដូចខ្ញុំបានជម្រាប រំឭកលោកកន្លងមកហើយបាទ។

**សួរដោយលោក សុន អរុណ៖**

សូមអរគុណ។ ខ្ញុំសូមអំមិញអត់ទាន់អស់ចម្លើយ សំណួរខ្ញុំផង លោកឆ្លើយពាក់កណ្ដាល។ ខ្ញុំអំមិញសួរឡើងវិញ សូមសួរឡើងវិញ។

**ស៖** លោកបានប្រាប់ទៅចៅក្រមថា អំពីបុព្វបទអក្សរ “ខ” ថា សំដៅទៅលើឯកសារបានមកពីរដ្ឋាភិបាល និងឯកជនជាច្រើន។ តើលោកយល់ថាឯកសារទាំងពីរប្រភេទនេះ ពិតប្រាកដទេ ថាជាឯកសាររបស់កម្ពុជាប្រជាធិបតេយ្យ? តើច្បាស់ទេ ឬគ្រាន់តែសន្មតដូចលោកបាននិយាយពីពេលមុនដែលបានឆ្លើយទៅព្រះរាជអាជ្ញានោះ?

[១៤:២៧:០៩]

**លោក ឆាំង យុះ**

**ឆ៖** ដូចខ្ញុំជម្រាបជូនលោកប្រធានអ៊ីចឹង ថាយើងអត់ប្រើអក្សរខ្មែរទេ មានតែអក្សរ ខេ “K”បើសិនជា អក្សរ ខេ “K” គឺជាប្រវត្តិរូប។ មានអក្សរ “K”, អក្សរ “I”, អក្សរ “D”, អក្សរ “J”, អក្សរ “L” ប៉ុន្តែអក្សរ “ខ” ខ្ញុំចម្លែកដែរ មិនដឹងខាងសហព្រះរាជអាជ្ញាបកប្រែ “K” ទៅ “ខ” ក៏មិនដឹង។ តែបើសិនជាអក្សរ “K” គឺជាប្រវត្តិរូបបាទ។ ហើយប្រវត្តិរូបនេះគឺមានពីរគឺមានប្រវត្តិរូប-- ប្រវត្តិរូបយើងបាននិយាយម្តងហើយថា វាមានច្រើនសណ្ឋាន។ មានមួយជារបៀបជីវទស្សន៍ ហើយយើងអាចអាន គឺជាប្រភេទប្រវត្តិរូបដែលអតីត ឬក៏មាជិករបស់កម្ពុជាប្រជាធិបតេយ្យបំពេញប្រវត្តិរូបរបស់ខ្លួនឯង។ ប្រវត្តិរូបម៉្យាងទៀត គឺជារបៀបជីវទស្សន៍ដែលសរសេរដោយខ្លួនឯងមានទំព័រច្រើនដូចជា ខ្ញុំបានលើកឧទាហរណ៍របស់លោក សួង ស៊ីគឿន ហៅសមមិត្ត គង់ គឺគាត់បានសរសេរខ្លួនឯង។ ប្រវត្តិរូបម៉្យាងទៀត មានប្រភេទជា មួយសន្លឹក១ ហើយមានរូបថតរបស់កម្មាភិបាលដែលបម្រើឲ្យអង្គភាពណាមួយ។ ប្រវត្តិរូបមួយទៀត គឺរបស់ជនរងគ្រោះ គឺយើងអាចដឹង ពីព្រោះចំណងជើងដាក់ថា “ប្រវត្តិរូបអ្នកទោសជាប់ឃុំឃាំង” ហើយប្រវត្តិរូបនេះជាទូទៅគឺមានលក្ខណៈមួយសន្លឹក ហើយមានរូបថត ហើយប្រវត្តិខ្លះទៀតអត់មានរូបថតទេ។ ហើយប្រវត្តិរូបនេះ យើងឲ្យអក្សរ “I” ឬក៏អក្សរ “K” ដើម្បីចំណាំថា អក្សរ “K” មកពីទួលស្លែង តាមដែលខ្ញុំចាំ អក្សរ “I” គឺជាប្រភេទប្រវត្តិរូបដែលយើងរកឃើញបាននៅក្រសួងមហាផ្ទៃ។ អ៊ីចឹងប្រវត្តិរូបនេះវាមកពីរកន្លែង មិនមែនមកតែមួយកន្លែងទេ។

[១៤:២៨:៤៧]

**ស៖** ចំពោះឯកសារដែលលោកបានប្រមូលពីស-២១ ជាឯកសារប្រភេទ “I” ត្រឹមត្រូវហើយដូចលោកមានប្រសាសន៍អម្បាញ់មិញអ៊ីចឹង។ គឺជាឯកសារសំដៅទៅលើប្រវត្តិរូបរបស់កម្មាភិបាលខ្មែរក្រហម និងប្រជាជនទូទៅ ដែលជាប់ឃុំឃាំងនៅទីនោះ។ ចម្លើយសារភាពនៅស-២១ និងនៅក្រសួងមហាផ្ទៃ បើតាមលោកចាំថា មានការខុសគ្នារបៀបម៉េច ពីព្រោះមានឯកសារច្រើនណាស់មកពីខាងស-២១ និងឯកសារច្រើនណាស់មកពីក្រសួងមហាផ្ទៃ?

**ឆ៖** ដូចខ្ញុំបានជម្រាបកាលពីសប្តាហ៍មុន ជាទូទៅ ជារួមទាំងអ្នកកាសែតទាំងអស់គ្នា ឲ្យតែឮចម្លើយសារភាពគឺស-២១១។ អ៊ីចឹងខ្ញុំបានព្យាយាមប្រាប់ច្រើនដង ហើយខ្ញុំក៏ធ្លាប់បានប្រាប់ទៅកាសែតដេលី ដែរ ហើយបើសិនជាលោក *ស៊្មើច* មើលនៅក្នុងកាសែតដេលី អត្ថបទនេះសរសេរឡើងដោយ

ដាកក្លាស ហ្កៀលីស៊ិន គឺបញ្ជាក់ច្បាស់ណាស់អំពីចំនួនពិតប្រាកដ ព្រោះរូបខ្ញុំអង្គុយរាប់តែម្តង។

[១៤:២៩:៤៩]

បើនៅសារមន្ទីរ នៅគុកទួលស្លែង មានចម្លើយសារភាពប្រហែល៤០០០។ ហើយឯកសារមួយសំណុំទៀតដែលខ្ញុំបានយកមកពីក្រសួងមហាផ្ទៃក៏មានចម្លើយសារភាពនៅក្នុងនោះដែរ ប្រហែលជា១០០០។ អ៊ីចឹងទាំងពីរនេះវាខុសគ្នា។ យើងបានរកឃើញថាមានមួយចំនួនវាស្ទួន វាដូចគ្នា ប៉ុន្តែចំនួនទំព័រខុសគ្នា ទោះបីមានចម្លើយសារភាពពីរបី ដែលដូចគ្នាក៏ដោយ ប៉ុន្តែចម្លើយសារភាពដែលខ្ញុំមាននេះវាមានទំព័រច្រើនជាងដែលមាននៅសារមន្ទីរទួលស្លែង។ និយាយឲ្យខ្លីទៅភាពដូចគ្នានេះ មានតិចតួចប៉ុន្តែជារួមគឺខុសដាច់ស្រឡះតែម្តង។ អ៊ីចឹងចម្លើយសារភាពមានពីរមកពីទួលស្លែងផង មកពីក្រសួងមហាផ្ទៃផង ដែលសរុបប្រហែលជា៥០០០។ ទាំងអស់នៅក្នុងស្រុកខ្មែរយើងបាទ។

**ស៖** នៅក្នុងសំណួរសារភាពទាំងពីរ ដែលថាខុសគ្នា ចេញមកពីប្រភពពីរខុសគ្នានុ៎ងឧទាហរណ៍ថា មនុស្សម្នាក់គេសួរនៅមហាផ្ទៃផង និងនៅស-២១ ផងអ៊ីចឹងអី?

**ឆ៖** មហាផ្ទៃមិនដែលសួរចម្លើយអ្នកទោសនៅទួលស្លែងទេបាទ។ នេះខ្ញុំចង់និយាយថា ឯកសារដែលមាននៅក្រសួងមហាផ្ទៃបាទ។ សូមបញ្ជាក់កន្លែងហ្នឹងបន្តិច។ អឺ! តាមដែលខ្ញុំចាំ គឺមានឯកសារដូចជា កុយ ធួន ខ្ញុំមិនច្បាស់ដែរ សុំទោសណា ប៉ុន្តែឯកសារនេះ ហាក់ដូចជាបានសួរនៅមន្ទីរទួលស្លែងហើយបញ្ជូនទៅឲ្យកន្លែងមួយផ្សេងទៀត ដែលលោក ប៊ែន ឃៀរនិន ហៅថា មន្ទីរសន្តិបាលដោយសារឯកសារនេះ នៅខាងឆ្វេងដៃ ដាក់ថាមន្ទីរសន្តិបាល។ ហើយប្រហែលៗជាអ្នកដែលទទួលខុសត្រូវនៅខាងសន្តិបាលនេះ បានសួរបន្ថែមទៅលើឯកសារដែលបានទទួលមកពីសារមន្ទីរទួលស្លែងម្ល៉ោះហើយបានជាឯកសារនេះ មានចំនួនច្រើនទំព័រជាង ឯកសារនៅទួលស្លែង។ អ៊ីចឹងមនុស្សនេះអាចត្រូវបានសួរពីរកន្លែងបាទ។

[១៤:៣១:៤០]

**ស៖** កាលនៅក្នុងឯកសារទាំងអស់ ក្រែងលោខ្ញុំមើលមិនអស់ ពីដើមកាលកម្ពុជាប្រជាធិបតេយ្យមិនមានក្រសួងមហាផ្ទៃទេ។ ពីដើម បើលោក សុន សេន គាត់ជារដ្ឋមន្ត្រីក្រសួងការពារជាតិ និងសន្តិសុខក្នុង និងក្រៅប្រទេស។

**ឆ៖** អឺ! ប្រហែលជាមានការភ័ន្តច្រឡំបន្តិចបាទគឺ ខ្ញុំចង់និយាយអំពីឯកសារខ្មែរក្រហមនៅក្រសួងមហាផ្ទៃនៃរដ្ឋកម្ពុជា។ ខ្ញុំមិនបាននិយាយថា ខ្មែរក្រហមមានក្រសួងមហាផ្ទៃទេ អ្វីដែលនៅ

ក្រសួងមហាផ្ទៃនេះ គឺជាឯកសារខ្មែរក្រហម ដែលយកទៅដាក់នៅកន្លែងនោះ ហើយកន្លែងនោះគឺហៅថាសន្តិបាល។ មន្ទីរសន្តិបាលនេះ គឺមិនបាច់ចាំវិភាគ ពីព្រោះក្នុងឯកសារហ្នឹង គឺសរសេរនៅខាងឆ្វេងដៃដាក់ថា មន្ទីរសន្តិបាលតែម្តង។ អ៊ីចឹងខ្មែរក្រហមអត់មានក្រសួងមហាផ្ទៃទេ បាទអត់មានទេ។ សូមទោសបើសិនជាខ្ញុំនិយាយទៅភ័ន្តច្រឡំបន្តិចកន្លែងហ្នឹងបាទ។

[១៤:៣២:៣៨]

**ស៖** ខ្ញុំអរគុណណាស់។ ចំពោះលោកបានជម្រាបតុលាការថា ឯកសារទាំងអស់រាប់លាន ត្រូវតែឆ្លងកាត់តុរបស់លោក ទាំងអស់គ្នាចាំ។ នៅក្នុងការលោកអានឯកសារទាំងអស់ ទោះបីសំខាន់ក៏ដោយ មិនសំខាន់ក៏ដោយ ឯកសារជាផ្លូវការមានន័យថា របស់រដ្ឋបាល របស់រដ្ឋសភា របស់កម្ពុជាប្រជាធិបតេយ្យទាំងអស់ហ្នឹង មានចុះហត្ថលេខា លោកបានឃើញហត្ថលេខានិងត្រាទេ មានដែលបានប្រទះឃើញរឿងហ្នឹងទេ?

**ឆ៖** ខ្ញុំបានប្រទះឃើញបាទ ពីព្រោះ-- លោកប្រធានខ្ញុំសូមបរិយាយបន្តិច ពីព្រោះវាក្នុងចិត្តខ្ញុំបាទ។ ឯកសារនេះ ពេលដែលខ្ញុំរក ដូចដែលខ្ញុំប្រាប់ពីថ្ងៃដំបូងអ៊ីចឹង ដូចរើសគ្រាប់បាយពីភក់នៅក្នុងសម័យខ្មែរក្រហមយកមកទទួលទានអ៊ីចឹង ខ្ញុំឃ្លានណាស់ ខ្ញុំឃ្លានយុត្តិធម៌ ដូចខ្ញុំឃ្លានបាយសម័យអាពតអ៊ីចឹង។ អ៊ីចឹងខ្ញុំមើលទាំងអស់ ហើយខ្ញុំបានឃើញតាមដែលខ្ញុំចាំ មានឯកសារមួយដែលចុះហត្ថលេខាដោយលោក ខៀវ សំផន ជាក្រមៗ តាមខ្ញុំចាំជាក្រម។ ហើយមានឯកសារមួយទៀត ចុះហត្ថលេខាដោយក្រសួងឧស្សាហកម្មមានត្រាៗ។ ហើយឯកសារត្រានេះខ្ញុំមានដាក់បោះផ្សាយទៅក្នុងសៀវភៅក្រហម ដែលសហការីរបស់លោកបង្ហាញព្រឹកមិញនេះទៀត។ អ៊ីចឹងលោកបើកមើលទៅឃើញមានហើយ។ ខ្ញុំបានប្រទះឃើញត្រា ឃើញហត្ថលេខារបស់លោក ខៀវ សំផន ហើយមានឃើញចុះហត្ថលេខារបស់ ឌុច របស់ ខៀវ បាទមាននៅលើទាំងអស់នោះបាទ។ ខ្ញុំបានឃើញ។

[១៤:៣៤:១៧]

**ស៖** ខ្ញុំបានឃើញមានត្រាមួយចំនួនដែរ ប៉ុនភាគច្រើន ច្រើនតែត្រាពីកងពល ពីយោធាមួយចំនួនបើខ្ញុំខុសទេ ហើយនិងមានត្រារបស់ក្រសួងមួយពីរ ប៉ុន្តែក្រៅពីហ្នឹងមិនឃើញមានត្រាទេ ប៉ុន្តែលោកអាចឃើញត្រាច្រើនជាងហ្នឹងទៅទៀតទេ?

**ឆ៖** មានតិចតួចបាទ តែមានមួយគឺច្បាស់ណាស់ គឺលោក ខៀវ សំផន។ ខ្ញុំមានច្បាស់ណាស់ព្រោះខ្ញុំចំណាំ ព្រោះកម្រមាន។ អ៊ីចឹងហើយ ឃើញមានត្រាខ្ញុំចាប់អារម្មណ៍ អ៊ីចឹងត្រាអត់មានច្រើនទេ

មានតិចតួច។

**ស៖** នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មានរបៀបរបបច្បាប់ទម្លាប់តឹងរ៉ឹងណាស់។ ហេតុអ្វីបានជានៅស-២១ មានឯកសារគ្រប់ប្រភេទ តាំងពីឯកសារថ្នាក់រហូតដល់មជ្ឈិម រហូតដល់គណៈអចិន្ត្រៃយ៍ទៅទៀត? លោកមានឆ្លល់ថាហេតុអីបានជាទៅនៅស-២១ នោះទៅវិញ ដែលស-២១ ជាកន្លែងមួយតូច មើលមនុស្សមួយម៉ឺននាក់ផ្លាយនាក់ប៉ុណ្ណឹងទេ។

**ឆ៖** ខ្ញុំឆ្ងល់ដែរ ហើយខ្ញុំក៏ចង់សួរកូនក្តីរបស់លោកដែរ បាទ ថាហេតុអីបានទុកឯកសារទាំងអស់នេះ។ បាទខ្ញុំឆ្ងល់ដែរ ហើយខ្ញុំបានរកឃើញអ្នកធ្វើឯកសារម្នាក់ឈ្មោះ សួស ធី ហើយតាមដែលខ្ញុំចាំ សួស ធី នេះក៏បានធ្វើការជាសាក្សីប្រឆាំងនឹង ឌុច ដែរ។ ព្រោះគាត់ជាអ្នករៀបឯកសារ។ អ៊ីចឹងយើងបានតាមរកប្រវត្តិរូប ហើយគាត់ថា អានេះជាការងារមួយ គេមានក្រុមឯកសារ។ ដូចខ្ញុំអ៊ីចឹងដែរ បាទ គេមានអ្នករូបថត គេមានអ្នកកត់ត្រាលេខ គេមានអ្នកដាក់ក្រសាល់អ៊ីចឹង គឺគេរៀបមានក្រុមឯកសាររបស់គេ។ ហើយតាមដែលខ្ញុំចាំ គឺលោក សួស ធី នេះបានផ្តល់សក្ខីកម្មអំពីបញ្ហានេះដែរ ត្រង់ថាតើរបបនេះ ហេតុអីបានទុកឯកសារនៅកន្លែងនុ៎ង ខ្ញុំមិនដឹងដែរបាទ ខ្ញុំឆ្ងល់ដែរ ហើយហ្នឹងគឺជាសំណួរដែល ជាទូទៅអ្នកកាសែតសួរដែរ ថាហេតុអីបានជាសម្បូរឯកសារខ្លាំងម្ល៉េះ?

[១៤:៣៦:១២]

ដូចខ្ញុំជម្រាបលោកអ៊ីចឹង ឯកសារនេះមិនច្រើនទេ តាមដែលខ្ញុំដឹង គឺមានឯកសារខ្លះត្រូវបានដុតចោលនៅពេលដែលកងទ័ពវៀតណាមចូលមក ហើយហើយឯកសារមួយចំនួនត្រូវផ្លាញ។ អ៊ីចឹងយើងគិតថាច្រើន ប៉ុន្តែខ្ញុំគិតថាអាចច្រើនជាងនេះទៅទៀត។ អ៊ីចឹង ខ្ញុំគិតថាបញ្ហាឯកសារនេះ ជារបៀបរបបការងាររបស់កម្ពុជាប្រជាធិបតេយ្យ គឺមានឆ្លើយឆ្លងសំបុត្រទាក់ទងគ្នា ព្រោះកម្ពុជាប្រជាធិបតេយ្យជារដ្ឋមួយ បាទមិនមែនជាភូមិមួយទេ ជារដ្ឋមួយ ជារដ្ឋាភិបាលមួយ ជាប្រទេសមួយ។ អ៊ីចឹងគេមានរបៀបរបបការងាររបស់គេដែរ។

**ស៖** បើតាមខ្ញុំដឹងមក ខ្ញុំមិនបានដែលរស់នៅជាមួយកម្ពុជាប្រជាធិបតេយ្យទេ ប៉ុន្តែតាមខ្ញុំដឹងមក ហើយខ្ញុំបានសាកសួរទៅតា នួន ជា ជាកូនក្តីរបស់ខ្ញុំ ថាអ្នកធំ អ្នកណាកាន់ការរបស់ខ្លួនឯង គឺដឹងតែរឿងខ្លួនឯង មួយចំនួនក្រុមជុំវិញខ្លួនឯង អ្នកកាន់ការថ្នាក់តូចបន្តិចដឹងតែរឿងខ្លួនឯងទេ ហើយធ្វើរបាយការណ៍ទៅជាន់លើ។ អ៊ីចឹងហើយបានជា ខ្ញុំលើកជាសំណួរនោះឡើង ថាហេតុអីស-២១ ជាកន្លែងមួយតូចទេ ជាអង្គការមួយតូចទេនៅក្នុងរដ្ឋាភិបាលហ្នឹង។ ហេតុអីបានជាកន្លែងហ្នឹងវាដឹងរហូត

ដល់មានឯកសារ មិនមែនត្រឹមដឹងទេ មានឯកសារដែលលោកទៅរកឃើញនោះ មានរហូតដល់និយាយពីរឿងមជ្ឈិមបក្ស គណៈអចិន្ត្រៃយ៍ប្រជុំ ស្អីៗទាំងអស់ ហេតុអីបានមានហ្នឹង? ហើយលោកបានឃើញហ្នឹង មានបានពិចារណាក្នុងហ្នឹងទេ?

[១៤:៣៧:៣៦]

**ឆ៖** ខ្ញុំសប្បាយចិត្ត ព្រោះនិយាយខ្មែរដូចគ្នាអ៊ីចឹង វាចាប់អារម្មណ៍។ តាមពិតលោក អរុណច្រឡំហើយ ឯកសារមជ្ឈិមបក្សនៃបក្សកុម្មុយនីស្តកម្ពុជាមិនមែនត្រូវបានរកឃើញនៅទួលស្លែងទេ គឺជាឯកសារផ្តល់ឱ្យមកខ្ញុំតាមរយៈលោក ប៉ែន យៀវនិន លោក ហ្វូលីយ៉ូ ហៀលជ្រេស និងលោក ដេវីដ ឆេនដ៍ល័រ។ ឯកសារនេះរបស់លោក ប៉ែន យៀវនិន គឺត្រូវបានលោក ខៀវ កាញារិទ្ធ ជាអ្នកប្រគល់ជូន។ បាទអ៊ីចឹងអត់មាននៅទួលស្លែងទេ ឯកសារអស់ហ្នឹងបាទ។ ហើយចំពោះឯកសារទួលស្លែង គឺមានតែទាក់ទងនឹងឯកសារអ្នកទោស បញ្ជីសម្លាប់ ឯកសារចម្លើយសារភាព រូបថតជាដើម។ អ៊ីចឹងឯកសារផ្សេងៗនេះ មិនមែនមកពីទួលស្លែងទាំងស្រុងទេ មកពីកន្លែងផ្សេង។ ហើយនៅក្នុង-- ដូចលោកមានប្រសាសន៍អំមិញអ៊ីចឹង នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនេះ កាលណាពីបីនាក់ឡើងទៅ គេហៅថាអង្គការហើយ “អង្គការលើ” លើហ្នឹងមិនដឹងជាទៅកន្លែងផ្សេងទៀត។ ខ្ញុំក៏ឆ្ងល់ដែរ ព្រោះខ្ញុំរស់នៅសម័យអាពត បាទ ខ្ញុំនៅត្រពាំងវែង នៅបន្ទាយមានជ័យ។ អ៊ីចឹងខ្ញុំក៏ឆ្ងល់ដែរ ព្រោះខ្ញុំនៅសម័យហ្នឹងដែរ គេថាអង្គការៗមិនដឹងជាស្អី។ ហើយបើតាមស្តាប់ ឌុច និយាយទៅ គាត់ថាតែបីនាក់ទៅ គេហៅថាអង្គការហើយ។ អ៊ីចឹងប្រធានក្រុម ប្រធានអីយើងហ្នឹងគឺសុទ្ធតែអង្គការហើយ។

[១៤:៣៨:៤២]

**ស៖** សូមអរគុណណាស់។ បើតាមចម្លើយរបស់លោកថា តាំងពីឆ្នាំ២០០៥ មក មិនទាន់មានការព្រមព្រៀងគ្នាពីរឿងឯកសារនោះជាមួយនឹង អ.វ.ត.ក ទេ។ ចុះបើដូច្នេះ លោកនៅតែផ្តល់ឯកសារយ៉ាងច្រើនដល់ អ.វ.ត.ក នេះ លោកយល់បែបណា? តើលោកមិនខ្លាចខុសច្បាប់ទេម៉េច?

**ឆ៖** អ.វ.ត.ក អ្នកសួរខ្ញុំ ហើយ អ.វ.ត.ក ជាតុលាការ ហើយបើតុលាការមិនស្គាល់ច្បាប់ខ្លួនឯង ខ្ញុំក៏មិនដឹងធ្វើយ៉ាងម៉េច។ ហើយកាលណាសុំ ខ្ញុំឱ្យៗទាំងអស់គ្នា ឱ្យទាំងក្រុមលោកក៏ឱ្យ ទាំងក្រុមលោក អៀង សារី ក៏ជូន ទៅក្រុមលោក ខៀវ សំផន ក៏ជូន សហព្រះរាជអាជ្ញាក៏ឱ្យ ដើមបណ្តឹងរដ្ឋប្បវេណីក៏ឱ្យ អ្នកសិក្សាស្រាវជ្រាវក៏ឱ្យ ព្រោះយើងជាបណ្ណសារដ្ឋាន យើងគឺជាមជ្ឈមណ្ឌលឯកសារ។ អ៊ីចឹងអ្នកណាសុំក៏ខ្ញុំឱ្យដែរ។ ហើយឯកសារនេះ គឺជាគោលការណ៍រដ្ឋាភិបាលមានអនុញ្ញាតឱ្យខ្ញុំ

ស្រាវជ្រាវ ហើយផ្សព្វផ្សាយ មិនឲ្យយកមកលាក់ទុកទេ។ អ៊ីចឹងសុំគឺខ្ញុំឲ្យតែម្តងបាទ។

**ស៖** ខ្ញុំសួរនេះត្រង់ចំណុចថា លោកមានប្រសាសន៍ច្រើនដងហើយថា ឲ្យទៅអ្នកណាក៏ដោយ ឲ្យតែសុំឲ្យទាំងអស់ ប៉ុន្តែខ្ញុំសួរនេះត្រង់ចំណុច អ.វ.ត.ក ជាតុលាការ។ ខ្ញុំមិនមែនសួរថាលោកឲ្យអ្នកណា លោកបាននិយាយហើយ ខ្ញុំមិនបាច់សួរទៀត ប៉ុន្តែគ្រាន់តែចំពោះ ឌី.ស៊ី.ខេម ជាអង្គការមួយដែរ ហើយឲ្យមក អ.វ.ត.ក ជាតុលាការ។ ចង់បញ្ជាក់ប៉ុណ្ណឹងបាទ។

**ឆ៖** ពីព្រោះ អ.វ.ត.ក សុំខ្ញុំបាទ។ សូមខ្ញុំ ខ្ញុំឲ្យ។ បាទ គាត់សុំខ្ញុំ។--

**ស៖** ប៉ុន្តែ សុំលោកដោយមិនទាន់មានកិច្ចសន្យា មិនទាន់មានអនុស្សរណៈអីជាមួយគ្នានៅឡើយទេ?

[១៤:៤០:៣៣]

**ឆ៖** ជាការត្រឹមត្រូវ ពេលដែលសុំ គឺខ្ញុំបានគិតតាំងពីដំបូង ដោយសារគិតថា ខ្ញុំចង់បានតុលាការនេះ។ ខ្ញុំគាំទ្រតុលាការនេះ។ ហើយម្ល៉ោះហើយខ្ញុំធ្វើយ៉ាងណាគឺឲ្យបំពេញកាតព្វកិច្ចជាអ្នកខាងក្រៅដើម្បីជួយដល់តុលាការនេះ។ ហើយខ្ញុំមានការព្រួយបារម្ភ ខ្ញុំគិតថាចុះតុលាការទាំងមូលមកសុំឯកសារអ៊ីចឹង ហេតុអីក៏គ្មានកិច្ចព្រមព្រៀង។ ខ្ញុំមានការព្រួយបារម្ភ។ អ៊ីចឹងហើយខ្ញុំក៏បានសាកសួរអ្នកជិតខាង សួរអ្នកជំនាញខ្ញុំ ខ្ញុំទើបតែនឹកឃើញរឿងមួយទៀត អ្នកជំនាញខាង *ហ្វ័រិនស៊ិក* ឯកសារហ្នឹង គឺអ្នកស្រី ខេត រ៉ូតស៊ិន នៅ អាយ.ស៊ី.ធី.វ៉ាយ ខ្ញុំបានជួបគាត់ ហើយខ្ញុំក៏បានលើកសំណើនេះឡើងសរសេរមកជូនអ្នកស្រី មីសែល លី ជួបគាត់នៅញូវយ៉ក ជួបគាត់ជាហូរហែ ពីព្រោះខ្ញុំបារម្ភៗថា តុលាការមួយសុំឯកឯកសារ ហេតុអីក៏អត់មានកិច្ចព្រមព្រៀង។

[១៤:៤១:១៣]

អ៊ីចឹងខ្ញុំបានប្រាប់ទៅតុលាការ នៅក្នុងពេលដែលខ្ញុំប្រាប់ទៅតុលាការហ្នឹង គឺគ្រប់អង្គភាពមកសុំឯកសារខ្ញុំ។ អ៊ីចឹងខ្ញុំក៏ឲ្យបណ្តើរប្រាប់បណ្តើរ ណ៎ែ ឥឡូវខ្ញុំឲ្យខាងនេះហើយ គិតលុយអស់ប៉ុណ្ណោះ! ខ្ញុំឲ្យ *វីស៊ីប* មកទៀត ខ្ញុំប្រាប់ទៀត។ កាលណាចំនួនឡើងខ្ញុំប្រាប់រហូតៗដល់ចំនួនជិតទៅប្រាំសែន។ អ៊ីចឹងខាងតុលាការនេះព្រងើយកន្តើយមិនឆ្លើយតបទៅនឹងសំណើរបស់ខ្ញុំ។ មនុស្សចុងក្រោយបំផុត ខ្ញុំនិយាយម្តងហើយគឺលោក ឃុត និង តូនី ក្រាញ់ មិនដែលឆ្លើយតបទៅនឹងសំណើរបស់ខ្ញុំសោះ។ ពីព្រោះខ្ញុំព្រួយបារម្ភអំពីបញ្ហាផ្សេងដែលធ្វើឲ្យមានការពន្យារពេលដល់តុលាការនេះ។ ពីព្រោះខ្ញុំគាំទ្រតុលាការនេះ។ អ៊ីចឹងខ្ញុំបានធ្វើអត់លទ្ធភាពដែលខ្ញុំអាចធ្វើទៅបាន។ ខ្ញុំបានប្រាប់តុលាការអំពីបញ្ហានេះ។

[១៤:៤២:០០]

**សៈ** សូមអរគុណចំណុចនេះ។ ខ្ញុំមានចំណុចមួយទៀតត្រង់ថា ពេលដែលលោកបានទទួលឯកសារមកពីបរទេសច្រើនតែភាសាបរទេស ចំពោះសៀវភៅខ្មៅនិងទង់បដិវត្ត។ ឥឡូវនេះនិយាយពីទង់បដិវត្តមួយចុះ។ បើតាមកូនក្តីខ្ញុំប្រាប់ថា សរសេរជាអក្សរដៃ អក្សរខ្លួនគាត់ផ្ទាល់ ហើយបានឲ្យទៅមនុស្សម្នាក់ដែលអក្សរស្អាតចម្លង ហើយបានយកទៅទាញនឹងដៃ ប៉ុន្តែដល់ធ្លាក់ទៅដល់ស៊ុយអែត ទៅដល់បារាំង *អាលីវ-ណាវ* ស្អីអ៊ីចឹងទៅ សៀវភៅហ្នឹងវាចេញអក្សរបារាំង អាហ្នឹងយើងអាចថា ជាសំណៅដើមបានទេ?

**ជៈ** ខ្ញុំមិនទាន់ឃើញទង់បដិវត្តជាភាសាស៊ុយអែតទេ ហើយក៏មិនទាន់ឃើញទង់បដិវត្តជាភាសាបារាំងដែរ។ លោកប្រហែលច្រឡំជាមួយនឹងទស្សនាវដ្តីកម្ពុជាប្រជាធិបតេយ្យដែលមានជាភាសាស៊ុយអែត និងជាភាសាបារាំង។ ទង់បដិវត្តនេះ គេមាននៅក្នុង-- តាមដែលខ្ញុំដឹងនៅក្នុងទង់បដិវត្តនេះ មានទាំងរូបថត ប្រហែលជាកូនក្តីរបស់លោកទៀតផង។ តាមដែលខ្ញុំដឹងមានឯកសារមួយគឺមានរូបលោក ខៀវ សំផន ធ្វើសុន្ទរកថានៅកូឡុំប៊ី និង ស្រីលង្កាទៀតផង។ អ៊ីចឹងខ្ញុំមិនដឹងថា ដើមយ៉ាងម៉េចទៀត ពីព្រោះអាហ្នឹងវាមានអាយុតាំងពីឆ្នាំ៧៥ រហូតមកទាល់សព្វ។ ហើយឯកសារនៅក្នុងប្រទេសស៊ុយអែត នុ៎ងគឺជាឯកសារដើម គឺជា-- ខ្ញុំមិននៅ*អូហ្វហ្វីស* ខ្ញុំបាទ មានទស្សនាវដ្តីជាច្រើន មានបកជាភាសាបារាំង ជាភាសាអង់គ្លេស។

[១៤:៤៣:៣៨]

អ៊ីចឹងពីរខុសគ្នាលោក សុន អរុណ។ មួយជាទង់បដិវត្ត មួយជាព្រឹត្តិបត្រ ហើយមានជា*ប៊ូឡឺធិន*ផ្សេងៗទៀត ដែលខ្ញុំប្រាប់ឈ្មោះពីព្រឹកមិញហ្នឹង ដូចជាមានឈ្មោះថា កម្ពុជាប្រជាធិបតេយ្យ សេរីការជាដើម គឺធ្វើឡើងដោយរបបកម្ពុជាប្រជាធិបតេយ្យ។ ប្រហែលជាលោក នួន ជា ខ្ញុំចង់ចូលចិត្តហៅគាត់ អ៊ំនួន បាទ គាត់ជាចាស់ជាទុំ ហើយជាខ្មែរដូចគ្នា។ សូមអធ្យាស្រ័យផងចំពោះលោកប្រធាន ប្រហែលជាអ៊ំ នួន គាត់គិតតាំងពីសម័យ ៥០, ៦០ ក៏ខ្ញុំមិនដឹងដែរណ៎ា! ប៉ុន្តែបើសិនជាក្នុងសម័យកម្ពុជាប្រជាធិបតយ្យនេះ មានរោងពុម្ពបាទ មានគេបោះ។ ហើយខ្ញុំមានសៀវភៅហ្នឹង ហើដូចខ្ញុំជម្រាបលោកអ៊ីចឹង បើសិនជាលោកចង់បានខ្ញុំជូនមួយក្រៅផ្លូវសង្វៀនតុលាការ។ សូមលោកអង្គុយមើលឲ្យអស់ចិត្ត ពីព្រោះខ្ញុំមិនដឹងថាយ៉ាងម៉េចទៀត។ ហើយនៅស៊ុយអែត អត់មានទង់បដិវត្តជាភាសាស៊ុយអែត ជាភាសាបារាំងទេបាទ។

[១៤:៤៤:២៦]

**សៈ** ខ្ញុំ-- បើលោកប្រធានមិនយល់ទាស់ទេ ខ្ញុំសូមបញ្ជាក់បន្ថែមបន្តិចទៀតពីរឿងទង់បដិវត្ត អំមិញ។ លោក នួន ជា គាត់បានមានប្រសាសន៍ ឥឡូវគាត់មិនបាននៅពីព្រឹកនៅ គាត់និយាយផ្ទាល់មាត់ជាមួយនឹងតុលាការថា ទង់បដិវត្តពេលណាដែលព្រះរាជអាជ្ញាយកឯកសារ និងទង់បដិវត្តមកបង្ហាញគាត់។ គាត់បដិសេធចោល គាត់មិនមើល។ គាត់ថាមិនមែនជារបស់គាត់។ ចំពោះមុខតុលាការអ៊ីចឹង ហើយអ៊ីចឹងយើងតាំងពីហ្នឹងទេ តាំងពីដើមមកដែលខ្ញុំយកទង់បដិវត្តដែលកូពីចេញពី *ហ្វាយឡេប* យកទៅជូនគាត់មើល គាត់ថាគាត់មិនចង់មើលមិនមែនរបស់គាត់។ ត្រង់ហ្នឹង ខ្ញុំខំប្រឹងស្រាវជ្រាវណាស់ ស្រាវជ្រាវដើម្បីរកអាដើមបំផុតមកបង្ហាញគាត់ ថាត្រឹមត្រូវទេ? អាហ្នឹងគាត់ទទួលយកបានទេ បើទទួលយកបាន គាត់អាចនឹងសហការដើម្បីនឹងឆ្លើយបកទៅនឹងព្រះរាជអាជ្ញានៅក្នុងសៀវភៅទង់បដិវត្តរបស់គាត់ហ្នឹង។

**ឆៈ** ឥឡូវអ៊ីចេះវិញ ដើម្បីជួយដល់ការចងចាំរបស់គាត់ ពីព្រោះក៏គាត់មានអាយុច្រើនហើយ ហើយពេលវេលាវាឆ្លងទៅជាងសាម-សែសិបឆ្នាំ។ បាទ ការចងចាំរបស់មនុស្សវាអាចរសាត់។ អ៊ីចឹងប្រហែលជាគាត់នឹកឃើញរបស់មួយ ហើយប្រហែលជាត្រូវការអ្វីផ្សេងទៀត ដើម្បីឱ្យជួយរំឭកគាត់។ ខ្ញុំជូនឧទាហរណ៍មួយ នៅក្នុងសៀវភៅនេះ មានសៀវភៅមួយទៀត គឺជាសៀវភៅប្រលោមលោក។ ខ្មែរក្រហមក៏មានសៀវភៅប្រលោមលោកដែរ លោកប្រធាន។ គឺសមមិត្ត សាយ បាទ គឺជាអ្នកតស៊ូ ជាវីរបុរសកម្ពុជាប្រជាធិបតេយ្យ ហើយតាមដែលខ្ញុំចាំ សៀវភៅប្រលោមលោកនេះ ជាលំនាំប្រលោមលោកនេះ មានសម្តែងជាល្ខោន ហើយមានសរសេរជាអក្សរដៃ តែបោះជា*ស្តង់ស៊ីល* បាទ ពីដើមគេហៅស្តង់ស៊ីល សរសេរហើយ រុញមកជាស្តង់ស៊ីល។

[១៤:៤៦:១៥]

ខ្ញុំគិតថា យើងអាចរកឯកសារផ្សេងៗដើម្បីឱ្យរំឭកការចងចាំរបស់គាត់ ពេលនេះ គាត់ក៏មានអាយុច្រើន គាត់មានសម្ពាធ អ៊ីចឹង គាត់អាចភ្លេច ហើយយើងអាចយករូបថតផ្សេងៗ ដើម្បីឱ្យគាត់យល់ បើសិនជាគាត់នៅតែជំទាស់ថា ទង់បដិវត្តនេះត្រូវបានសរសេរដោយដៃ។ មានឯកសារសរសេរដោយដៃ ដែលខ្មែរថាអូស ស្តង់ស៊ីល លោកប្រធាន ហ្នឹង ខ្ញុំមិនដឹងជាខ្មែរថាយ៉ាងម៉េច គឺតាមដែលខ្ញុំចាំមានរឿងមួយ គឺវីរបុរសចៅសាយ។ ហើយរឿងនេះ គឺត្រូវបានសម្តែងជាល្ខោនផ្សព្វផ្សាយនៅតាមមូលដ្ឋាននៅសម័យហ្នឹងទៀតផងបាទ។

**ប្រធានអង្គជំនុំ៖**

លោកមេធាវី តើលោកត្រូវការពេលវេលាប៉ុន្មានទៀត? ព្រោះឥឡូវហ្នឹង លើសជិតដប់មីនុតហើយ តាមពេលវេលាដែលបានកំណត់ឲ្យ។ បញ្ហាទីមួយ។

បញ្ហាទីពីរ ខ្ញុំគិតថាតាមការសង្កេតឃើញថា អាចមានការភ័ន្តច្រឡំរវាងចម្លើយរបស់លោក នួន ជា កន្លងមក ពាក់ព័ន្ធជាមួយនឹងទស្សនាវដ្ដីទង់បដិវត្ត។ ទស្សនាវដ្ដីទង់បដិវត្ត ដែល នួន ជា បានឆ្លើយ គឺមានពីរដំណាក់កាលខុសគ្នា។ ដំណាក់កាលតស៊ូសម្ងាត់ អំឡុងឆ្នាំទសវត្សរ៍៦០ផ្ដាយ នោះគឺជាការសំណេរដោយដៃ ហើយមានការសរសេរថតចម្លងដោយដៃ ហើយបានបោះពុម្ពតិចតួចទេ។ ចំណែកឯទស្សនាវដ្ដីដែលបោះពុម្ពហ្នឹង គឺមានការយឺតយ៉ាវ មិនបានធ្វើនៅក្នុងអំឡុងខែបួន-- ខែមេសា ឆ្នាំ១៩៧៥ទេ បានពន្យារពេលរហូតដល់ខែសីហា ឆ្នាំ១៩៧៥ ទើបការបោះពុម្ពផ្សាយ ដោយសារមូលហេតុ ការស្រាវជ្រាវរកអ្នកចេះបោះពុម្ពហ្នឹង មិនបាន ទម្រាំតែបានហ្នឹង រហូតដល់យឺតបួនប្រាំខែ។

[១៤:៤៧:៥០]

អានេះ គឺជាការរំឭកមួយ ដើម្បីអាចមើលប្រតិចារឹកឡើងវិញ ដើម្បីរំឭកអំពីកិច្ចដំណើរការក្នុងការសួរដេញដោលពាក់ព័ន្ធនឹងបញ្ហាទង់បដិវត្តនេះ។ អានេះ យើងមានមូលដ្ឋានក្នុងការឲ្យអាចដេញដោលទៅប្រព្រឹត្តទៅបានល្អ។ ប្រសិនបើយើងមិនបានស្រាវជ្រាវឲ្យស៊ីជម្រៅពាក់ព័ន្ធនឹងសំណួរទេ ដល់ពេលសួរអ៊ីចឹង វាអាចនៅតែមានបញ្ហា។ ហើយវាមិន-- យើងសិក្សាអំពីចម្លើយរបស់លោកជនជាប់ចោទដែលបានឆ្លើយរួចហើយ គឺមិនពេញលេញ។ ឥឡូវនេះ លោកត្រូវការពេលវេលាប៉ុន្មានទៀត?

**លោក សុន អរុណ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំត្រូវការប្រហែលជាដប់ប្រាំនាទី។ បើសិនជាអាចអនុញ្ញាត ខ្ញុំបន្ត បើមិនអនុញ្ញាត ក៏ខ្ញុំសូមអាចឈប់ត្រឹមហ្នឹងបាន។

[១៤:៤៨:៤៣]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាតឲ្យលោក ដប់ពីរនាទីទៀត បានន័យថា ម៉ោងបីគត់ បញ្ចប់ការសួរដេញដោលរបស់លោក។ ពីព្រោះគប្បីព្យាយាមក្នុងការប្រើប្រាស់ពេលវេលាដែលអង្គជំនុំជម្រះផ្ដល់ជូន ត្រូវប្រើប្រាស់ឲ្យមានប្រសិទ្ធភាព ចៀសវាងការសួរសំណួរច្រំដែល។ សំណួដែលមិនស៊ីជម្រៅ ហើយរំឭកម្ដងហើយម្ដងទៀត។ អ៊ីចឹង ភាគីពាក់ព័ន្ធត្រូវតែត្រៀមលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការតាំងសំណួរ

ឲ្យបានជាក់ច្បាស់ ដើម្បីចំណេញពេលក្នុងការសួរដេញដោល។

**សួរដោយលោក សុន អរុណ៖**

**ស៖** ខ្ញុំសូមបន្តសំណួរខ្ញុំ។ នៅក្នុងឯកសារដដែល លោកបានឆ្លើយថាឯកសារទាំងប្រាំប្រភេទ៖ ឯកសារក្រដាស មានក្រដាស មានសារទូរលេខ មានកំណត់ហេតុប្រជុំ។ល។ ឯកសារដែលទាក់ទងនឹងភស្តុតាង ការកំណត់ហេតុទីតាំងនៃទីកន្លែង រូបថតនៃបូជនីយដ្ឋាន និងទីកន្លែងកប់សាកសព។ តើលោក-- តើរូបថត និងខ្សែភាពយន្តទាំងអស់នោះ ផលិតឡើងកាលសម័យខ្មែរក្រហម? ឬក្រោយពេលខ្មែរក្រហម?

[១៤:៤៩:៥៩]

**លោក ឆាំង យុ៖**

**ឆ៖** រឿងរូបថត ហើយនិងរឿងខ្សែភាពយន្តនេះ វារឿងវែងអន្លាយបន្តិច បើយើងនិយាយឲ្យខ្លី រូបថតទាំងអស់ គឺសុទ្ធមកពីរបបកម្ពុជាប្រជាធិបតេយ្យ បាទ មានរូបថត។ ហើយពេលដែលខ្ញុំ (ខ្ញុំឮសួរនិយាយគ្នា?) សូមលោកបិទមេក្រូផង បាទ!

ខ្ញុំចង់និយាយថា រូបនេះគឺមានមកពីរបបកម្ពុជាប្រជាធិបតេយ្យ មិនមែនតែរូបថតនៅគុកទួលស្លែងទេ គឺមានរូបថតជាកម្មាភិបាល មានរូបថត នួន ជា អ៊ំនួន គាត់ចុះទៅតាមមូលដ្ឋាន។ រូបថតលោក អៀង សារី ដើរនៅលើខ្សែរទេះភ្លើង រូបថតលោក ខៀវ សំផន ជួបជាមួយនឹងគណៈប្រតិភូបរទេស មានរូបថតទៅអង្គរវត្តជាដើម មានរូបថតច្រើនមែនទែន។ អាហ្នឹងរូបថត សុទ្ធតែមកពីរបបកម្ពុជាប្រជាធិបតេយ្យ ហើយមិនជាការលំបាកក្នុងការបញ្ជាក់ទេ ព្រោះរូបថតហ្នឹងគឺមានរូបគាត់នៅក្នុងតែម្តង។

[១៤:៥០:៤៩]

ចំពោះខ្សែភាពយន្តគឺមានពីរប្រភេទ គឺជាខ្សែភាពយន្តរបស់របបកម្ពុជាប្រជាធិបតេយ្យដែលបានបាត់ចេញពីស្រុកខ្មែរ ហើយធ្លាក់ទៅដល់ស្រុកបារាំង។ នេះរឿងវែងឆ្ងាយណាស់ ហើយខ្ញុំក៏បានប្រាប់ទៅខាងសហចៅក្រម ព្រះរាជអាជ្ញាដែរ ហើយក្រោយមកបានត្រឡប់មកវិញ ប៉ុន្តែមិនបានគ្រប់ចំនួន។ ខ្ញុំតាមរឿងខ្សែភាពយន្តនេះ តាំងពីឆ្នាំ៨៨។ ក្រៅពីខ្សែភាពយន្តនេះ យើងមានខ្សែភាពយន្តមួយចំនួនទៀតផលិតឡើងក្រោយរបបកម្ពុជាប្រជាធិបតេយ្យ ដោយប្រទេសអាល្លឺម៉ង់ខាងកើត ដោយប្រទេសយូហ្គោស្លាវី ដោយបុគ្គលមួយចំនួន ហើយក៏យើងបានប្រមូលដែរ។ ខ្សែភាពយន្តទាំងអស់នេះ

គឺបានប្រគល់មកឲ្យយើងនៅក្នុងលក្ខខណ្ឌមួយគឺមិនឲ្យថតចម្លង ដោយសារជាផលិតផលដែលធ្វើឡើងក្រោយរបបកម្ពុជាប្រជាធិបតេយ្យ។ យើងប្រគល់ទាំងស្រុងតាមដែលខ្ញុំដឹងជាង១០០ មកឲ្យការិយាល័យសហព្រះរាជអាជ្ញាទាំងស្រុង ដើម្បីចែកចាយប្រើទាំងអស់គ្នា។ ហើយខ្ញុំចាំថាលោក វីឆាត រ៉ូជឺ គាត់ធ្លាប់បានទៅ *អូសហ្វីស* របស់ខ្ញុំ មើលកុននៅកន្លែងហ្នឹងដែរ។ អ៊ីចឹងកុនហ្នឹង គឺខ្ញុំឲ្យ១០០ភាគរយតែម្តង។ ខ្ញុំថតបញ្ចូលទៅក្នុងស៊ីឌី។

[១៤:៥១:៤៧]

នៅក្នុងលក្ខខណ្ឌមួយ ខ្ញុំបានប្រាប់ទៅខាងតុលាការថា សូមមេត្តាកុំផ្សព្វផ្សាយចម្លងកុននេះទៅអ្នកដទៃ ពីព្រោះកុននេះ គឺមានចេតនាមួយសម្រាប់បម្រើការសិក្សាស្រាវជ្រាវតែប៉ុណ្ណោះ។ ក្រោយមកខ្ញុំរកឃើញថាមានមនុស្សមួយចំនួនបានប្រើកុននេះទៅធ្វើសុន្ទរកថា ប្រជុំផ្សេងៗនៅស្រុកថៃក៏មាន នៅអង់គ្លេសក៏មាន នៅបារាំងក៏មានដែរ កុនទាំងអស់នេះ។ អ៊ីចឹងខ្ញុំសរសេរសំបុត្រមកមួយសាទៀតថា សូមមេត្តា ពីព្រោះមាន *កូពីរ៉ាយថ៍* ពីព្រោះមិនមែនជារបស់ខ្មែរពី៧៥-៧៩ទេ ហើយឯកសារ ៧៥-៧៩ នេះគឺបានត្រឡប់មកវិញ តាមការទាមទាររបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈសព្វថ្ងៃនេះ។ បាទ ឯកសារនេះត្រឡប់មកវិញ។ អ៊ីចឹងកុនមានពីរប្រភេទ ហើយរូបថតមានច្រើនៗ មិនមែនតែសំដៅរូបថតនៅទួលស្លែងទេបាទ។

[១៤:៥២:៣៤]

**ស៖** សូមអរគុណ ខ្ញុំនៅមានសំណួរមួយទៀត ប៉ុន្តែមុននឹងខ្ញុំបាទសួរ ខ្ញុំនឹងមានបរិយាយមុនបន្តិច ដើម្បីឲ្យលោកយល់ពីសំណួររបស់ខ្ញុំ។ តាមឯកសារកំណត់ហេតុយកចម្លើយរបស់ចៅក្រមស៊ើបអង្កេត លេខD204/2 ចុះថ្ងៃទី២៨/៥/២០០៩ លោកឆ្លើយប្រាប់ទៅចៅក្រមស៊ើបអង្កេតថា “ឯកសារដើមដែលពាក់ព័ន្ធទៅក្រាំងតាចាន់ បានបាត់អស់ហើយ គឺមានតែឯកសារចម្លងតែប៉ុណ្ណោះ”។ ខ្ញុំសួរថា ហេតុអ្វីបានជាបាត់ឯកសារទាំងនោះ ដោយគេលួច ឬយ៉ាងណានៅពេលនោះ ឯកសារទាំងនោះនៅឯណា? អ្នកណាកាន់កាប់ ហើយបាត់នៅពេលណា?

**ឆ៖** បើសិនជាលោកអានប្រតិចារឹកហ្នឹងទាំងស្រុង លោកឃើញហើយ ថាខ្ញុំប្រាប់ថាអ្នកណាខ្លះដែលខ្ញុំបានជួបដំបូង។ ដំបូងឡើង គឺឯកឧត្តម ស៊ូ ភិរិន្ទ ដែលបច្ចុប្បន្នជាអភិបាលខេត្តសៀមរាប។ ខ្ញុំបានទៅមន្ទីរខេត្ត ខ្ញុំបានទៅជួបលោក ទឹង សុខែ តាមដែលខ្ញុំចាំឈ្មោះរបស់គាត់ តាមរកឯកសារដើមនេះ។ ហើយលោកដឹងហើយថា ស្រុកយើងតាំងពីក្រោយបោះឆ្នោតមកមានការប្រែប្រួល មានការរើ

ការិយាល័យផ្សេងៗ ហើយក៏វាបាត់បង់ទៅ។ ក្រោយមកសំណៅមួយនេះ គឺត្រូវរកឃើញនៅក្នុងក្រោមទូនៅក្នុងសារមន្ទីរទួលស្លែង ដែលលោក ប៉ែន យៀវនិន បានហ្វូតូកូពី ចម្លងទុកឲ្យទួលស្លែងជាឯកសារ។

[១៤:៥៤:០២]

ហើយឯកសារមួយនេះ ខ្ញុំមានការព្រួយបារម្ភ ពីព្រោះយើងបានជួយមនុស្សទាំងអស់ដែលបានប៉ះពាល់ឯកសារនេះ ប៉ុន្តែវាអត់ឃើញឯកសារដើម។ អ៊ីចឹងមធ្យោបាយរបស់ខ្ញុំ គឺខ្ញុំស្រាវជ្រាវមនុស្សនៅក្នុងឯកសារនេះ។ សូមចាំថាគុកទាំងអស់ ក្រៅពីទួលស្លែង គឺមានតែគុកទួលស្លែងទេ ដែលបន្សល់នូវឯកសារជាលាយលក្ខណ៍អក្សរ។ អ៊ីចឹងអ្វីដែលខ្ញុំចង់ដឹងថាតើវាពិត មិនពិត ខ្ញុំបានរកមើលបញ្ជីឈ្មោះអ្នកដែលស្លាប់ ហើយរកគ្រួសាររបស់អ្នកដែលស្លាប់ ហើយខ្ញុំបានរកឃើញចៅ និងមាមីងរបស់អ្នកដែលបានស្លាប់នៅគុកក្រាំងតាចាន់។ អ៊ីចឹងបានន័យថា នេះវាអាច យ៉ាងណាស់ជួយឲ្យលោកបានគិតថាឯកសារនេះ វាពិតជាមានមែន។ ប៉ុន្តែឯកសារដើម ខ្ញុំរកមិនឃើញទេ បាទ ខ្ញុំបានប្រាប់ច្បាស់ណាស់អំពីរឿងឯកសារក្រាំងតាចាន់ នេះ។ ហើយឯកសារក្រាំងតាចាន់នេះ ខ្ញុំចាប់អារម្មណ៍ដំបូងដោយខ្ញុំបានអានសៀវភៅលោក ប៉ែន យៀវនិន គាត់សរសេរអំពីគុកក្រាំងតាចាន់។ អ៊ីចឹងឯកសារនេះ អត់មានទេ បាទ ប៉ុន្តែមិនដឹងថាគ្រប់គ្រាន់សម្រាប់លោកដែរ ឬក៏អត់។ ពីព្រោះមានសាច់ញាតិ សាច់សាលោហិតរបស់អ្នកដែលស្លាប់នៅក្នុងបញ្ជីឯកសារគុកក្រាំងតាចាន់។ សំណួរមួយ សួរថាតើនេះអាចគ្រប់គ្រាន់ដែរឬទេ ដើម្បីបញ្ជាក់ថា នេះពិតជាឯកសារនៅគុកក្រាំងតាចាន់មែន។ ហើយអនុប្រធានគុកក្រាំងតាចាន់ ក៏មានឈ្មោះថា ឌុច គាត់ឈ្មោះដែរ គាត់ឈ្មោះ អ៊ាប ឌុច បាទ គាត់ហ្នឹងគឺជាអនុប្រធានគុកក្រាំងតាចាន់ ហើយមានអ្នកដែលធ្លាប់ជាប់គុកក្រាំងតាចាន់ នៅរស់ទៀត ជាវិចិត្រករ។ អ៊ីចឹងយើងបានរកវិធីផ្សេងៗ ដើម្បីបញ្ជាក់ថា ពិតជាមានឯកសារមែន ហើយបើសិនជាទាំងអស់នេះមិនគ្រប់គ្រាន់ ខ្ញុំមិនដឹងជាទៅរកឯកសារដើមមកពីណាទេបាទ ចំពោះឯកសារក្រាំងតាចាន់។

**សះ** នៅក្នុងឆ្នាំ១៩៧៩ ទ័ពវៀតណាមគ្រប់គ្រង ហើយនៅគ្រប់គ្រងក្រសួងមានជំនាញការវៀតណាមរាប់បញ្ចូលកិច្ចការគ្រប់គ្រងឯកសារផងដែរ។ វៀតណាមបានចូលគ្រប់កន្លែងក្នុងក្រុងភ្នំពេញ ហើយប្រមូលឯកសាររួចចាប់ផ្ដើមរៀបចំឯកសារ។ ត្រង់ចំណុចនេះ ខ្ញុំសូមសួរលោកថាឯកសារទាំងអស់ដែលវៀតណាមបានជួយរៀបចំ និងគ្រប់គ្រងឯកសាររបស់ខ្មែរក្រហមទាំងនោះ--អ៊ំៗ របស់ប្រទេសកម្ពុជាយើងទាំងនោះ ហើយវៀតណាមក៏អាចកែច្នៃ បំភ្លៃ កែប្រែ បន្ថែមបន្ថយ និង

បង្កើតនូវឯកសារទាំងន័យ ទាំងឯកសារ និងទាំងខ្លឹមសារ នៃឯកសារនោះផងដែរឬទេ ដើម្បីឲ្យទៅជាឯកសាររបស់ខ្មែរក្រហមសុទ្ធសាធ? លោកជឿបានទេ?

**សៈ** ខ្ញុំថា វៀតណាមនេះទាល់តែលេខមួយពិភពលោកតែម្ដងបានធ្វើបានបាទ។ ខ្ញុំឧទាហរណ៍មួយដូចជាពាក្យ "បដិច្ចសមុប្បាទ" ខ្ញុំគិតថា វៀតណាមអានមិនចេញផងភាសាបាលីនោះ ព្រោះហ្នឹងជាពាក្យមួយនៅក្នុងទង់បដិវត្តដែរ។ អ៊ីចឹងមានពាក្យច្រើនទៀត ដែលខ្ញុំគិតថា មិនអាចទៅរួចហើយ ឯកសាររាប់លាន លោកស្រមៃមើល សរសេររឿងរ៉ាវជីវិតមនុស្សមួយលាននាក់ដែលបានស្លាប់ ឬក៏មនុស្សមួយលាននាក់ដែលបានធ្វើទារុណកម្ម រូបថតរាប់ម៉ឺនរាប់សែន រណ្ដៅសាកសពរាប់ម៉ឺនរាប់សែន។ តើធ្វើយ៉ាងម៉េចក្នុងអំឡុងពេលដប់ឆ្នាំ តើធ្វើទៅបានដែរឬក៏អត់? បាទ អ៊ីចឹងខ្ញុំគិតថា ប៉ុន្តែ ដូចខ្ញុំជម្រាបលោកអ៊ីចឹង ខ្ញុំដឹងថាមានវត្តមានរបស់វៀតណាមនៅក្នុងកម្ពុជា ប៉ុន្តែមិនមែនបានន័យថា ខ្មែរយើងមិនធ្វើការទេ បាទ ខ្មែរយើងសម័យនោះ គឺធ្វើការធ្វើងារ ទោះបីអត់ឃ្លានយ៉ាងណាក៏ដោយ ទាមទារឲ្យមានតុលាការ ទាមទារឲ្យមានការកាត់ទោស គឺធ្វើចេញពីចិត្តពីថ្លើម។ អ៊ីចឹង គឺខ្មែរយើងទេ ដែលជាអ្នកទៅរើសប្រមូលមកអ៊ីចឹងនោះ។ មិនមែនវៀតណាមទេ ហើយដោយសារថាវៀតណាមកាន់កាប់កន្លែងមួយចំនួន អ៊ីចឹងយើងត្រូវសុំការអនុញ្ញាតពីគេ។ ហើយជាទូទៅ មិនថាអង្គភាពណាទេ គឺថាមានជំនាញការវៀតណាម។

[១៤:៥៧:៤០]

អ៊ីចឹងខ្ញុំគិតថា បើសិនជា-- ដូចខ្ញុំបានឲ្យឈ្មោះអ៊ីចឹងអ្នកដែលធ្វើការក្រុមឯកសារនៅក្រសួងមហាផ្ទៃអ៊ីចឹង គឺលោកអាចសួរគេបាន ថាតើអ្នកណាសរសេរលើឯកសារនេះ ហើយនៅក្នុងឯកសារនេះសរសេរជាភាសាខ្មែរបាទ ជាភាសាខ្មែរ។ អ៊ីចឹងលោកអង្គុយសរសេរដប់ឆ្នាំមួយលានឯកសារ ខ្ញុំគិតថាវៀតណាមគ្មានពេលទេបាទ ហើយក៏សរសេរមិនចេញដែរ ហើយពាក្យបាលី ពាក្យអីអ៊ីចឹង ហើយជាពិសេសនៅក្នុងភាសាខ្លះមួយទៀត ជាពាក្យដែលលំបាកបាទ សូម្បីតែខ្មែរយើងក្មេងៗកើតជំនាន់ក្រោយក៏មិនយល់ផង បាទក៏មិនយល់ពាក្យពេចន៍ហ្នឹងផង ដូចជាពាក្យ ដូចខ្ញុំលើកឡើងអំពីពាក្យ "បដិច្ចសមុប្បាទ"ហ្នឹង ខ្ញុំគិតថា នៅអង្គុយកន្លែងនេះ ខ្មែរយើងមួយចំនួនមិនដឹងថាមានន័យថាយ៉ាងម៉េចផងបាទ។

**លោក សុន អរុណ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំអស់មានសំណួរហើយ។

[១៤:៥៨:២៨]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណហើយដល់ពេលសមល្មមនឹងសម្រាកហើយដែរ អង្គជម្រះសូមថ្លែងអំណរគុណចំពោះលោក ឆាំង យុ ដែលបានចំណាយពេលវេលាដ៏មានតម្លៃ និងកម្លាំងកាយចិត្តមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនេះ។ ឥឡូវនេះ អង្គជម្រះគិតថា កិច្ចដំណើរការសួរដេញដោលចំពោះរូបលោកឃើញថា ប្រព្រឹត្តទៅបានចប់សព្វគ្រប់ហើយ វត្តមានរបស់លោកលែងចាំបាច់ទៀតហើយ នៅក្នុងកិច្ចពិភាក្សានេះ។ ដូច្នេះគឺ ការសួរដេញដោលរបស់លោក ពាក់ព័ន្ធនឹងបញ្ហាដំណើរការប្រព្រឹត្តទៅជាទូទៅនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុងនាមលោកជាប្រធានស្ថាប័ននោះ ឃើញថាចប់សព្វគ្រប់ហើយ។ លោកអាចត្រឡប់ទៅវិញ លំនៅដ្ឋានវិញបានហើយ។ ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលក្នុងការធ្វើដំណើរវិលត្រឡប់ទៅលំនៅដ្ឋានរបស់គាត់ ឬក៏គោលដៅដែលគាត់ទៅឲ្យបានស្រួលបួល និងសុវត្ថិភាពផង។

[១៤:៥៩:២៦]

ហើយកិច្ចដំណើរការសវនាការ ថ្ងៃនេះឃើញថា ដល់ពេលត្រូវផ្អាកហើយ ដោយសារមូលហេតុការគិតគូរអំពីពេលវេលាតាមកាលបរិច្ឆេទហ្នឹងឃើញថា មានសល់ពេលខ្លះដោយសារមូលហេតុមេធាវីការពារក្តីលោក អៀង សារី លះបង់មិនសួរដេញដោលចំពោះសាក្សីរូបនេះ។

ដូច្នេះ អង្គជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ ហើយសវនាការលើកទៅបន្តធ្វើនៅថ្ងៃពុធទី៨ ខែកុម្ភៈ ឆ្នាំ២០១២ ដោយចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក ហើយនៅក្នុងអំឡុងពេលសវនាការនៅថ្ងៃទី៨ ខែកុម្ភៈ នោះ គឺនឹងបន្តស្តាប់ចម្លើយជនជាប់ចោទ នួន ជា ដែលនឹងសួរដេញដោលដោយក្រុមមេធាវីការពារក្តីរបស់គាត់។

សូមអញ្ជើញ!

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធានអភ័យទោស។ ខ្ញុំចង់ស្នើសុំអង្គជំនុំជម្រះឲ្យបញ្ជាក់អំពីសវនាការសម្រាប់ថ្ងៃពុធ និងថ្ងៃព្រហស្បតិ៍ ពីព្រោះខ្ញុំដឹងថានឹងមានសវនាការពេលព្រឹកអំពី នួន ជា ហើយខ្ញុំគិតថាតើមានតែសវនាការតែពេលព្រឹក ឬក៏មានបន្តដល់ល្ងាចដែរ។ សូមលោកប្រធានមេត្តាបញ្ជាក់ឲ្យបានច្បាស់។ សូមអរគុណ។

[១៥:០១:៤៣]

**ប្រធានអង្គជំនុំ៖**

បាទអរគុណ ដោយបញ្ហានៃការរៀបចំកាលវិភាគ សម្រាប់កិច្ចដំណើរសវនាការតែងតែមានការប្រែប្រួល ដូចជាអ្វីដែលអង្គជំនុំជម្រះបានជម្រាបជូនភាគីរួចហើយ នៅស្ថានភាពនៃភាពជួបប្រទះនូវបញ្ហាប្រឈមនានានៅក្នុងការរៀបចំ នៅកិច្ចដំណើរការសវនាការសម្រាប់សំណុំរឿងក្តី០០២ នេះ។ ប៉ុន្តែទោះទោះបីយ៉ាងណាក៏ដោយ អង្គជំនុំជម្រះតែងតែធ្វើការគ្រោងទុក ហើយនិងជម្រាបជូនដល់ភាគីនានាបានជ្រាប ទោះបីមិនបានលឿនរហ័សរហូតដល់ច្រើនសប្តាហ៍ក៏ដោយ ក៏អង្គជំនុំជម្រះតែងតែបានរៀបចំនូវបញ្ហានេះផងដែរ។ ហើយជាក់ស្តែងគឺនៅក្នុងថ្ងៃពុធ និងថ្ងៃព្រហស្បតិ៍ ចុងសប្តាហ៍នេះ អង្គជំនុំជម្រះនឹងបន្តសួរចម្លើយជនជាប់ចោទ នួន ជា ដោយភាគីមេធាវីការពារក្តីរបស់គាត់តាមពេលវេលាដែលអង្គជំនុំជម្រះបែងចែកឲ្យ ហើយនៅពេលព្រឹក។ ដោយឡែកពេលរសៀលហ្នឹង អង្គជំនុំជម្រះនឹងពិនិត្យពិចារណាបន្តលើកិច្ចដំណើរការ នៃការដាក់ឯកសារចំពោះមុខភាគី ឬក៏ភាគីដាក់ឯកសារនានាចំពោះមុខអង្គជំនុំជម្រះ តាមដែលលទ្ធភាពដែលអាចធ្វើទៅបាន និងដោយឡែកបញ្ហាផ្សេងទៀតសម្រាប់បន្តកិច្ចដំណើរការសវនាការនៅសប្តាហ៍មួយទៀតនោះ គឺអង្គជំនុំជម្រះបានជម្រាបជូនដំណឹងដល់ភាគីរួចហើយ អំពីផែនការនៃកាលវិភាគកំណត់កាលបរិច្ឆេទសវនាការ ក្នុងការដាក់ឯកសារទាំងពីរដំណាក់កាល។ ដំណាក់កាលនៃកិច្ចដំណើរការសវនាការ ដោយយើងបានធ្វើរួចហើយនេះ ឬក៏ចុងសវនាការនៃសវនាការបរិបទនៃប្រវត្តិបក្សកុម្មុយនីស្តកម្ពុជា ហើយនិងឯកសារមួយទៀតយើងត្រៀមសម្រាប់លើកទៅដេញដោលនូវអង្គហេតុបន្ទាប់ គឺរចនាសម្ព័ន្ធរដ្ឋបាលកម្ពុជាប្រជាធិបតេយ្យ ហើយនិងទំនាក់ទំនងការងារ។ ខ្ញុំគិតថា អាចសមល្មមនឹងអាចស្តាប់យល់ហើយនូវបញ្ហាទាំងអស់នេះ។

[១៥:០៤:០២]

អនុរក្សមន្ទីរឃុំឃាំង ឲ្យនាំខ្លួនជនជាប់ចោទទាំងបីរូប ទៅកាន់មន្ទីរឃុំឃាំងនៃអ.វ.ត.ក វិញ ហើយឲ្យនាំពួកគាត់ទាំងបីរូបមកកាន់បន្ទប់សវនាការនេះ នៅព្រឹកថ្ងៃពុធ ទី៨ ខែកុម្ភៈ ឆ្នាំ២០១២ ឲ្យបានមុនម៉ោងប្រាំបួន។ សម្រាកចុះ៕

*(ចៅក្រមចាកចេញពីបន្ទប់សវនាការ)*

*(សវនាការផ្អាកនៅម៉ោង១៥:០៥នាទី)*